ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
MINISTRY OF COMMERCE

# របាយការណ៍

## បូកសរុបការងារពាណិជ្ជកម្មឆ្នាំ ២០១១
## និង
## ទិសដៅអនុវត្តការងារពាណិជ្ជកម្មឆ្នាំ ២០១២



# ថ្នាក់ដឹកនាំ ក្រសួងពាណិជ្ជកម្ម



**ឯកឧត្តម ចម ប្រសិទ្ធ**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម



ឯកឧត្តម ឈួន ដារ៉ា
រដ្ឋលេខាធិការ



ឯកឧត្តម ទ៉ា ដាង
រដ្ឋលេខាធិការ



ឯកឧត្តម កែច សុខណៃ
រដ្ឋលេខាធិការ



ឯកឧត្តម ឡិក ប៊ុន
រដ្ឋលេខាធិការ



ឯកឧត្តម គីម ស៊ីថន
រដ្ឋលេខាធិការ



ឯកឧត្តម ម៉ាន សុរស័ក្តិ
រដ្ឋលេខាធិការ



ឯកឧត្តម ច័ន្ទ ឌារ៉ា
រដ្ឋលេខាធិការ



ឯកឧត្តម ម៉ៅ ថូរ៉ា
រដ្ឋលេខាធិការ



ឯកឧត្តម ឱត ធីណា
អនុរដ្ឋលេខាធិការ



ឯកឧត្តម កាន ច័ន្ទមេត្តា
អនុរដ្ឋលេខាធិការ



ឯកឧត្តម តាន់ ស៊ុនត
អនុរដ្ឋលេខាធិការ



ឯកឧត្តម ហូ សារ៉ាន់
អនុរដ្ឋលេខាធិការ



ឯកឧត្តម សុខ រុន
អនុរដ្ឋលេខាធិការ



ឯកឧត្តម ឯម សុគំណ្ឌ
អនុរដ្ឋលេខាធិការ



ឯកឧត្តម ចេង សុធី
អនុរដ្ឋលេខាធិការ



លោកជំទាវ តឹករ៉េត កំរង
អនុរដ្ឋលេខាធិការ

# មាតិកា


I. កំណែទម្រង់ដើម្បីអភិបាលកិច្ចល្អ និងការបម្រើសេវាសាធារណៈ .......... 2
1. កំណែទម្រង់ការងារដើម្បីជំរុញអភិបាលកិច្ចល្អ .......... 2
1.1. ការចូលរួមអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ .......... 2
1.2. វិធានការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្ម .......... 2
1.3. សកម្មភាពកសាង និងផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តិ .......... 2
1.3.1. ការងារកសាងច្បាប់ពាណិជ្ជកម្ម .......... 2
1.3.2. ការងារបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម .......... 3
1.3.3. ការងារផ្សព្វផ្សាយច្បាប់ពាណិជ្ជកម្ម .......... 3
1.3.4. ការងារធ្វើបច្ចុប្បន្នភាពអនុក្រឹត្យលេខ២០៩ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ .......... 3
2. ការងារព័ត៌មានពាណិជ្ជកម្ម .......... 4
2.1. ការងារគ្រប់គ្រងព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម .......... 4
2.2. កម្រងសៀវភៅស្ថិតិពាណិជ្ជកម្ម .......... 4
2.3. ការងារគ្រប់គ្រងគេហទំព័រ (Website) របស់ក្រសួងពាណិជ្ជកម្ម .......... 4
2.4. ការងារស្ថិតិពាណិជ្ជកម្ម .......... 4
3. ការបម្រើសេវាសាធារណៈ .......... 4
3.1. ការផ្តល់សេវាកម្មទាក់ទងនឹងម៉ាក .......... 5
3.1.1. ការចុះបញ្ជីម៉ាក .......... 5
3.1.2. ការផ្តល់សេវាកម្មក្រោយចុះបញ្ជី .......... 5
3.1.3. ការងារបោះពុម្ពផ្សាយព្រឹត្តិបត្រផ្លូវការ .......... 5
3.1.4. ការដោះស្រាយវិវាទរំលោភបំពានកម្មសិទ្ធិបញ្ញា និងការលុបម៉ាកចេញពីបញ្ជី .......... 5
3.2. ការងារតម្កល់លិខិតជូនដំណឹងប្រតិបត្តិការដែលមានកិច្ចធានា .......... 5
3.3. ការចុះបញ្ជីពាណិជ្ជកម្ម និងការផ្តល់សេវាពាក់ព័ន្ធ .......... 6
3.4. ការចុះបញ្ជីផ្តល់សិទ្ធិនាំចេញក្រោមប្រព័ន្ធអនុគ្រោះពន្ធ .......... 6
3.5. ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម .......... 7
3.6. សកម្មភាពត្រួតពិនិត្យពាណិជ្ជកម្ម(ភាគីទី៣) .......... 7
II. សកម្មភាពវិស័យពាណិជ្ជកម្មដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណ .......... 7
1. ការងារសមាហរណកម្មសេដ្ឋកិច្ចសកល .......... 7
1.1. ការងារផ្តល់ព័ត៌មាន (Notification) .......... 8
1.2. ការងាររៀបចំការត្រួតពិនិត្យឡើងវិញគោលនយោបាយពាណិជ្ជកម្មកម្ពុជា (TPR) .......... 9
1.3. ការងារផ្ទៀងផ្ទាត់ច្បាប់ (Legal Compliance) .......... 9
1.4. ការងារពិនិត្យឃ្លាំមើលដំណើរការចរចាកញ្ចប់ទីក្រុងដូហា ( Doha Round Negotiation) .......... 10
2. ការងារសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន .......... 10
2.1. កាអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមភាព .......... 10
2.2. ពាណិជ្ជកម្មផ្នែកទំនិញ .......... 10
2.3. ពាណិជ្ជកម្មផ្នែកសេវាកម្ម .......... 11

2.4. ការវិនិយោគ ....11
2.5. សហគ្រាសធុនតូច និងមធ្យម (SMEs)....11
2.6. ទំនាក់ទំនងរវាងវិស័យសាធារណៈ និងឯកជន....12
3. កិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសដៃគូអាស៊ាន....12
3.1. ដំណើរផ្សព្វផ្សាយរបស់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានទៅកាន់ប្រទេសដៃគូ ....12
3.2. កិច្ចប្រជុំពិគ្រោះយោបល់រវាងអាស៊ាន-ចិន....12
3.3. អាស៊ាន និងជប៉ុន....12
3.4. កិច្ចប្រជុំពិគ្រោះយោបល់រវាង អាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់....13
3.5. កិច្ចប្រជុំពិភាក្សាជាមួយអាស៊ាន-ឥណ្ឌា ....13
3.6. អាស៊ាន-អាមេរិក....13
3.7. កិច្ចពិគ្រោះយោបល់រវាងអាស៊ាន និងរុស្ស៊ី....13
3.8. អាស៊ាន - GCC....14
3.9. អាស៊ាន - សហភាពអឺរ៉ុប ....14
4. កិច្ចសហប្រតិបត្តិការអនុតំបន់....14
4.1. កិច្ចប្រជុំរដ្ឋមន្ត្រីស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ាន (AMBDC) ....14
4.2. កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចមេគង្គ-ជប៉ុន ....14
4.3. កិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលចម្រុះស្តីពីតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម (CLV) ....14
4.4. កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចកម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម (CLMV) ....15
5. កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មក្នុងក្របខ័ណ្ឌទ្វេភាគី និងកិច្ចសហប្រតិបត្តិការអន្តរជាតិនានា..15
5.1. កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មកម្ពុជា-វៀតណាម....15
5.1.1. កិច្ចប្រជុំពិភាក្សាកែសម្រួលលើ C/O form S របស់កម្ពុជា ជាមួយនិង C/O form X របស់វៀតណាម ..15
5.1.2. ការចរចាកិច្ចសម្របសម្រួលពាណិជ្ជកម្មទ្វេភាគី....15
5.2. កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយសហគមន៍អឺរ៉ុប....16
5.3. កិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ឡាវ ....16
5.4. កិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-អូស្ត្រាលី ....16
6. ការងារវិស័យកម្មសិទ្ធិបញ្ញា....16
6.1. ការងារគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា និងការរៀបចំច្បាប់-បទបញ្ញត្តិកម្មសិទ្ធិបញ្ញា ..16
6.2. ការងារផ្សព្វផ្សាយ....17
6.3. ការងារសហប្រតិបត្តិការ....17
6.4. ការអនុវត្តគម្រោងអាទិភាពពង្រឹងវិស័យកម្មសិទ្ធិបញ្ញា....18
7. ទំហំពាណិជ្ជកម្មនៃការនាំចេញ-នាំចូលទំនិញ....18
8. ការនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម....18
8.1. ការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក....18
8.2. ការនាំចេញទៅកាន់ទីផ្សារកាណាដា ....18
8.3. ការនាំចេញទៅកាន់ទីផ្សារផ្សេងៗក្នុងទ្វីបអាមេរិក (ក្រៅពីសហរដ្ឋអាមេរិក និងកាណាដា) ....18
8.4. ការនាំចេញទៅកាន់ទ្វីបអឺរ៉ុប ទ្វីបអាហ្វ្រិក និងសាធារណរដ្ឋសង្គមនិយមវៀតណាម....19

8.5. ការនាំចេញទៅកាន់ទ្វីបអាស៊ី និង អូសេអានី ..... 19

8.6. ការងារត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ C/O ..... 19

8.6.1. ការពិនិត្យទំនិញមុន និងក្រោយការស្នើសុំ C/O ..... 19

8.6.2. ការត្រួតពិនិត្យតាមដានពេលវេលាក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ..... 19

9. ការចេញអាជ្ញាប័ណ្ណនាំចេញ-នាំចូលក្រោមបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ ..20

10. សកម្មភាពជំរុញពាណិជ្ជកម្ម ..... 20

10.1. ការរៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ..... 20

10.2. ការតាមដានទីផ្សារ និងរក្សាស្ថេរភាពថ្លៃ ..... 20

10.3. ការងារអភិវឌ្ឍន៍ផលិតផល និងស្វែងរកទីផ្សារជូនពាណិជ្ជករ និងកសិករ ..... 21

10.4. ការងារអភិវឌ្ឍន៍ពាណិជ្ជកម្ម និងសកម្មភាពពង្រឹងដៃគូពាណិជ្ជកម្ម ..... 21

10.4.1. ការងារអភិវឌ្ឍន៍ពាណិជ្ជកម្ម ..... 21

10.4.2. សកម្មភាពពង្រឹងដៃគូពាណិជ្ជកម្ម ..... 22

10.4.3. សកម្មភាពនៃការរៀបចំបោះឆ្នោតសភាពាណិជ្ជកម្ម ..... 22

11. ការងារគ្រប់គ្រងស្បៀង ..... 22

12. ការពង្រឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា ....23

12.1. សកម្មភាពត្រួតពិនិត្យទំនិញ ..... 23

12.1.1. សកម្មភាពឃ្លាំពិនិត្យទីផ្សារ ..... 23

12.1.2. សកម្មភាពត្រួតពិនិត្យទំនិញតាមច្រកព្រំដែន ..... 23

12.2. លទ្ធផលត្រួតពិនិត្យការផ្សាយពាណិជ្ជកម្ម ..... 24

12.3. សកម្មភាពវិភាគគុណភាពទំនិញ ..... 24

12.3.1. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងការបំពាក់ឧបករណ៍មន្ទីរពិសោធន៍ ..... 24

12.3.2. លទ្ធផលវិភាគរបស់មន្ទីរពិសោធន៍ ..... 24

12.4. សកម្មភាពផ្សព្វផ្សាយ និងអប់រំការយល់ដឹងសាធារណៈអំពីបញ្ហាគុណភាព សុវត្ថិភាពផលិតផល និងសិទ្ធរបស់អ្នកប្រើ ..... 24

12.5. ការកសាងបញ្ញត្តិបច្ចេកទេសសម្រាប់អនុវត្ត និងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេស និងស្ថាប័នពាក់ព័ន្ធ ..... 24

12.5.1. ការរៀបចំពង្រាងបទបញ្ញត្តិបច្ចេកទេស ..... 24

12.5.2. ការចូលរួមផ្តល់មតិយោបល់បច្ចេកទេសពាក់ព័ន្ធនឹងសុវត្ថិភាព និងគុណភាពផលិតផល ..... 24

12.5.3. ការស្រាវជ្រាវ និង ជ្រើសរើសទូរសេចក្តីជូនដំណឹងអំពីអនាម័យ និង ភូតគាមអនាម័យ ..... 25

13. ការគ្រប់គ្រងជំនួយបរទេស (Foreign Aid Management) ..... 25

13.1. កម្មវិធីអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម Trade SWAp (Trade Sector Wide Approach) ..... 25

13.1.1. កម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម TDSP (Trade Development Support Program) ..... 25

13.1.2. គម្រោងពង្រឹងសមាហរណកម្មពាណិជ្ជកម្ម EIF (Enhanced Entegrated Framework) ..... 26

13.2. គម្រោងកិច្ចសម្រួលពាណិជ្ជកម្ម និងភាពប្រកួតប្រជែង ..... 26

13.2.1. ផ្នែកកិច្ចសម្រួលពាណិជ្ជកម្ម និងច្រកចេញចូលតែមួយ ..... 26

13.2.2. ផ្នែកមូលនិធិបើកច្រកទីផ្សារនាំចេញ ..... 27

13.2.3. ផ្នែកការចូលរួមរបស់ឯកជនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការជំរុញវិនិយោគ ..... 27

13.2.4. ផ្នែកតម្លាភាពនៃច្បាប់ ....27
14. ការងារបញ្ច្រាបយេនឌ័ររបស់ក្រសួងពាណិជ្ជកម្ម....28
III. សកម្មភាពការងាររដ្ឋបាល ការគ្រប់គ្រងធនធានមនុស្ស និងយន្តការត្រួតពិនិត្យផ្ទៃក្នុង....28
1. ការងាររដ្ឋបាល....28
2. ការងារហិរញ្ញវត្ថុ ....29
3. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស....29
3.1. ការងារគ្រប់គ្រងមន្ត្រីរាជការ....29
3.2. ការងារផ្នែកក្របខ័ណ្ឌ ....30
3.3. ការងារផ្នែកបុគ្គលិក....31
3.4. ការងារផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស ....31
3.4.1. ផ្នែកបណ្តុះបណ្តាលក្នុងប្រទេស....32
3.4.2. ផ្នែកបណ្តុះបណ្តាលក្រៅប្រទេស ....32
4. ការងារសវនកម្ម និងអធិការកិច្ច ....32
4.1. ការងារសវនកម្ម ....32
4.1.1. សវនកម្មលើកិច្ចប្រតិបត្តិការ....32
4.1.2. សវនកម្មលើកិច្ចការងារហិរញ្ញវត្ថុ....33
4.1.3. សវនកម្មលើអនុលោមភាព ....33
4.1.4. ការងារពង្រឹងសមត្ថភាពអង្គភាព....33
4.2. អធិការកិច្ច ....33
IV. ទិសដៅអនុវត្តការងារពាណិជ្ជកម្មបន្ត ....34

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

MINISTRY OF COMMERCE

# របាយការណ៍

## បូកសរុបការងារពាណិជ្ជកម្មឆ្នាំ ២០១១
## និងទិសដៅអនុវត្តការងារពាណិជ្ជកម្មឆ្នាំ ២០១២

ក្នុងការអនុវត្តបន្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ក្រសួងពាណិជ្ជកម្ម ផ្តោតសំខាន់លើការជំរុញបន្ថែមអំពីអ្វីដែលកម្ពុជាត្រូវបំពេញ ដើម្បីជាទំនុកចិត្តដល់វិនិយោគិន។ ការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ តាមយុទ្ធសាស្ត្រពាណិជ្ជូបនីយកម្មកសិកម្ម គឺជារបៀបវារៈអាទិភាពមួយរបស់ក្រសួងពាណិជ្ជកម្ម ហើយជាបណ្តើរៗ ប្រជាពលរដ្ឋកម្ពុជាយើងកំពុងទទួលផលពីការអនុវត្តគោលនយោបាយនេះ។

បច្ចុប្បន្ន ពិភពលោកទាំងមូលបានទទួលស្គាល់ថា ពាណិជ្ជកម្មសេរីអាចចូលរួមផ្តល់វិភាគទានយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រ និង ការលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ។ នៅក្នុងស្មារតីនេះ ក្រសួងនឹងបន្តដំណើរទៅមុខយ៉ាងស្វាហាប់នៅលើមាគ៌ា នៃការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម សំដៅធានាឲ្យទំនិញ និងសេវាគ្រប់ប្រភេទអាចចរាចរបានដោយសេរីនៅទូទាំងប្រទេស រវាងប្រទេសកម្ពុជា និងប្រទេសជាដៃគូសំខាន់ៗ នៅក្នុងតំបន់ និងនៅលើសកលលោក។ ការបើកច្រកឲ្យផលិតផលកម្ពុជាអាចឈានចូលដោយគ្មានរបាំង និងឧបសគ្គនានា ទៅកាន់ទីផ្សារដ៏ធំធេងនៅក្នុងតំបន់ និងពិភពលោក គឺជាការផ្តល់ឲ្យកម្ពុជានូវកាលានុវត្តភាពសេដ្ឋកិច្ចដ៏ធំធេង។ ក្នុងន័យនេះការចូលរួមរបស់កម្ពុជានៅក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន និងនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោកនោះ គឺសុទ្ធតែជាជំហានដែលមានអត្ថន័យជាយុទ្ធសាស្ត្រ និងជាប្រវត្តិសាស្ត្រសម្រាប់ការខិតខំប្រឹងប្រែងស្តារ និងអភិវឌ្ឍប្រទេសជាតិ។

បន្តទៅមុខនៅក្នុងចក្ខុវិស័យពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម បានផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការលើកកម្ពស់ផលិតកម្ម និងការធានាគុណភាព នៃផលិតផលឲ្យសមស្របតាមតម្រូវការរបស់ទីផ្សារ ការការពារកម្មសិទ្ធិបញ្ញា ការទប់ស្កាត់ការក្លែងបន្លំ ការពង្រឹងយន្តការត្រួតពិនិត្យគុណភាពទំនិញ ដើម្បីជំរុញការផលិត និងធានាឲ្យការនាំចេញ ក៏ដូចជាការប្រើប្រាស់ក្នុងស្រុក ជៀសវាងផលប៉ះពាល់ដល់សុវត្ថិភាព និងផលប្រយោជន៍របស់អ្នកប្រើប្រាស់។

អ្វីៗទាំងអស់ គឺដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលរាជរដ្ឋាភិបាលបានចាត់ទុកថា "ពាណិជ្ជកម្ម គឺជាប្រភពនៃកំណើនសេដ្ឋកិច្ច" ។

សមិទ្ធផល និងស្នាដៃ ដែលក្រសួងពាណិជ្ជកម្ម អនុវត្តសម្រេចបានក្នុងឆ្នាំ២០១១ នេះ ត្រូវបានឆ្លុះបញ្ចាំងទៅតាមបណ្តាផ្នែក និងវិស័យការងារដូចខាងក្រោម ៖

## I. កំណែទម្រង់ដើម្បីអភិបាលកិច្ចល្អ និងការបម្រើសេវាសាធារណៈ

### 1. *កំណែទម្រង់ការងារដើម្បីជំរុញអភិបាលកិច្ចល្អ*

#### 1.1. ការចូលរួមអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ

ក្រសួងពាណិជ្ជកម្ម បានចាត់ទុកការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ ជាផ្នែកគន្លឹះមួយនៃការពង្រឹងអភិបាលកិច្ចល្អ។ ក្នុងឆ្នាំ២០១១នេះ ក្រសួងបានចាត់តាំងមន្ត្រីចូលរួមវគ្គផ្សព្វផ្សាយច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ បានចំនួន ៣លើក ដើម្បីពង្រឹងស្មារតីនៃការចូលរួមអនុវត្តច្បាប់នេះ ឲ្យមានប្រសិទ្ធភាព។ មន្ត្រីដឹកនាំចាប់ពីថ្នាក់ប្រធាននាយកដ្ឋានឡើងទៅ បានបំពេញកាតព្វកិច្ច ប្រកាសទ្រព្យសម្បត្តិតាមបទបញ្ញត្តិនៃច្បាប់។ ទន្ទឹមនេះ ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ ត្រូវបានបង្កើតឡើង ដើម្បីធ្វើជាយន្តការសម្របសម្រួល និងជំរុញការអនុវត្តបទដ្ឋានច្បាប់ឲ្យមានលទ្ធផលល្អ។

#### 1.2. វិធានការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្ម

ដើម្បីជួយដល់ការអភិវឌ្ឍន៍វិស័យឯកជន ដែលត្រូវបានចាត់ទុកថាជាក្បាលរថភ្លើង នៃកំណើនសេដ្ឋកិច្ចជាតិ ក្រសួងពាណិជ្ជកម្ម បានបន្តអនុវត្តយ៉ាងយកចិត្តទុកដាក់លើកិច្ចសម្រួលពាណិជ្ជកម្ម សំដៅផ្តល់លទ្ធភាពប្រកួតប្រជែងជាមួយបណ្តាប្រទេសនានា។ កិច្ចការនេះ ផ្តោតទៅលើការបន្ថយបែបបទរដ្ឋបាល និងនីតិវិធីផ្សេងៗដែលជាឧបសគ្គដល់ប្រតិបត្តិការពាណិជ្ជកម្ម ព្រមជាមួយនឹងការរក្សាសោហ៊ុយចំណាយទៅលើការនាំចេញពីកម្ពុជា ឲ្យបានកម្រិតអប្បបរមា ដោយបានប្រមូលផ្តុំលើវិធានការមួយចំនួនដូចខាងក្រោម ៖

- បង្កើតបញ្ជរផ្តល់សេវាសាធារណៈ ដើម្បីលុបបំបាត់ភ្នាក់ងាររត់ការខុសច្បាប់ និងកាត់បន្ថយចំណាយក្រៅផ្លូវការ ដូចដែលបានរៀបចំធ្វើឡើងនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នាយកដ្ឋានពាក់ព័ន្ធដទៃទៀត និងនៅតាមតំបន់សេដ្ឋកិច្ចពិសេស។ បន្តពិនិត្យ និងអនុវត្តការកាត់បន្ថយបែបបទឲ្យនៅក្នុងកម្រិតតិចបំផុត ដូចមានចែងក្នុងឯកសារតម្រូវសម្រាប់ការនាំចេញ ឯកសារបញ្ជាក់ពីប្រភពដើមទំនិញ ឯកសារនៃការចេញអាជ្ញាប័ណ្ណ ឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីក្រុមហ៊ុន ការចុះបញ្ជីម៉ាក និងបែបបទមួយចំនួនទៀត។ គ្រប់ប្រភេទសេវាសាធារណៈ ដែលនឹងត្រូវផ្តល់ជូនប្រជាពលរដ្ឋ ត្រូវបានផ្សព្វផ្សាយដោយតម្លាភាពនៅក្នុងសៀវភៅកម្រងព័ត៌មានសាធារណៈ ដែលរៀបចំឡើង ដោយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល។

- ត្រួតពិនិត្យទំនិញក្នុងនីតិវិធីស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ដើម្បីសម្រួលដល់អ្នកនាំចេញ ក្រសួងមិនតម្រូវឲ្យមកសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញជាមុនទេ។ ការស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ បានអនុវត្តក្រោយពេលដែលនាំទំនិញរួចរាល់ជាស្ថាពរ។

- សម្រួលដល់ការនាំចេញទំនិញសិប្បកម្មគ្រប់ប្រភេទ ។ ការសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ C/O នៃការនាំចេញទំនិញសិប្បកម្ម ពុំមានតម្រូវឲ្យបង់កម្រៃ ឬ សោហ៊ុយរដ្ឋបាលទេ។

- ត្រួតពិនិត្យទំនិញក្នុងក្របខ័ណ្ឌសម្រួលពាណិជ្ជកម្ម : ក្រសួងពាណិជ្ជកម្ម (អគ្គនាយកដ្ឋានកាំកុងត្រូល) និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) បានសហការគ្នាល្អប្រសើរក្នុងការត្រួតពិនិត្យទំនិញរួមគ្នា ក្នុងនោះមានការកាត់បន្ថយឯកសារមិនចាំបាច់មួយចំនួនឲ្យនៅកម្រិតតិចបំផុត។

#### 1.3. សកម្មភាពកសាង និងផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តិ

##### 1.3.1. *ការងារកសាងច្បាប់ពាណិជ្ជកម្ម*

- សេចក្តីព្រាងច្បាប់ ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម មានគោលដៅបង្កើតវិធានពិសេសនៃកិច្ចសន្យាពាណិជ្ជកម្ម ដែលអាចជួយពាណិជ្ជករកម្ពុជាក្នុងការអភិវឌ្ឍន៍ និងបង្កភាពងាយស្រួលក្នុងទំនាក់ទំនង

ពាណិជ្ជកម្ម ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្នកំពុងកែសម្រួលជាមួយក្រុមប្រឹក្សាអ្នកច្បាប់នៅទីស្តីការគណៈរដ្ឋមន្ត្រី។

- ក្រសួងបានចាប់ផ្តើមតាក់តែងសេចក្តីព្រាងច្បាប់ ស្តីពីអ៊ី-ពាណិជ្ជកម្ម តាមរយៈជំនួយបច្ចេកទេសពី "កម្មវិធីគាំទ្រការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម TDSP" អមដោយជំនាញការបរទេស និងខ្មែរ ដែលមានបទពិសោធន៍។

- សេចក្តីព្រាងច្បាប់ ស្តីពីការប្រកួតប្រជែង បានទទួលជំនួយបច្ចេកទេស ADB សម្រាប់អនុវត្តក្នុងឆ្នាំ២០១១ ដល់ឆ្នាំ២០១៣។ សេចក្តីព្រាងដំបូង ត្រូវបានបញ្ចប់រួចរាល់ ដែលមានជាពីរភាសារ អង់គ្លេស និងខ្មែរ និងកំពុងរៀបចំធ្វើសិក្ខាសាលាដើម្បីប្រមូលផ្តុំយោបល់ពីស្ថាប័នពាក់ព័ន្ធនិងផ្នែកឯកជន។

- សេចក្តីព្រាងច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវបានរៀបចំរួចរាល់ជាស្ថាពរ និងត្រូវបញ្ជូនទៅគណៈរដ្ឋមន្ត្រីក្នុងត្រីមាសទី១ ឆ្នាំ២០១២។

- ក្រៅពីនេះ ក្រសួងបានជំរុញការរៀបចំច្បាប់ឧបាស្រ័យពាណិជ្ជកម្ម ដោយធ្វើការពិនិត្យកែសម្រួលឡើងវិញនូវសេចក្តីព្រាងច្បាប់ដែលបានធ្វើកន្លងមក សំដៅធ្វើឲ្យសេចក្តីព្រាងច្បាប់នេះមានលក្ខណៈជាច្បាប់ជាតិ។

### *1.3.2. ការងារបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*

ការបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម បង្ហាញឲ្យឃើញនូវការរីកចម្រើនគួរឲ្យកត់សម្គាល់ថ្មីមួយទៀតក្នុងការអភិវឌ្ឍន៍កម្ពុជា ឲ្យក្លាយទៅជាកន្លែងមួយដែលមានភាពទាក់ទាញសម្រាប់ប្រកបការងារ ការវិនិយោគ និងធ្វើអាជីវកម្ម។ វិធានការដែលក្រសួងពាណិជ្ជកម្មបានអនុវត្ត ដើម្បីលើកកម្ពស់បរិយាកាសអាជីវកម្ម និងពង្រឹងស្ថេរភាពសេដ្ឋកិច្ចកម្ពុជា គឺការអនុម័តច្បាប់ពាណិជ្ជកម្មជាច្រើនក្នុងនោះមានច្បាប់ ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលបម្រើដល់ការអភិវឌ្ឍន៍ប្រព័ន្ធសេដ្ឋកិច្ច និងបង្ហាញពីការទទួលស្គាល់ នូវតួនាទីសំខាន់នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក្នុងប្រព័ន្ធសេដ្ឋកិច្ច និងពាណិជ្ជកម្មទំនើប។

ដោយអនុលោមតាមអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គណៈកម្មការរៀបចំជ្រើសរើសមជ្ឈត្តករដំបូង ត្រូវបានបង្កើតឡើង។ គណៈកម្មការ បានធ្វើការពិនិត្យជ្រើសរើសបេក្ខជនចំនួន ៥៨នាក់ ហើយទទួលការបណ្តុះបណ្តាលក្នុងនោះបេក្ខជន ៤៨នាក់បានប្រឡងបញ្ចប់ដោយជោគជ័យ។

### *1.3.3. ការងារផ្សព្វផ្សាយច្បាប់ពាណិជ្ជកម្ម*

ក្រសួងធ្វើការផ្សព្វផ្សាយច្បាប់ ដែលប្រកាសដោយព្រះរាជក្រម តាមរយៈគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម និងគេហទំព័រដោយឡែករបស់នាយកដ្ឋាននីតិកម្មគឺ www.camcl.org និងតាមរយៈការធ្វើសិក្ខាសាលាផ្សព្វផ្សាយច្បាប់ នៅតាមបណ្តាខេត្តនានាទូទាំងប្រទេស ដោយមានការឧបត្ថម្ភពីគម្រោងអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ ADB។ ច្បាប់ពាណិជ្ជកម្ម ដែលត្រូវបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ រួមមាន ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា បានចំនួន ៩ខេត្ត។

### *1.3.4. ការងារធ្វើបច្ចុប្បន្នភាពអនុក្រឹត្យលេខ២០៩ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់*

ក្រសួងបានរៀបចំកិច្ចប្រជុំអន្តរក្រសួង ស្តីពីការធ្វើបច្ចុប្បន្នភាពអនុក្រឹត្យលេខ ២០៩ អនក្រ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ចំនួន ០២លើក ដើម្បីធ្វើឲ្យស្របទៅតាមកម្មវិធីសកលភាវូបនីយកម្ម និងការធ្វើសមាហរណកម្មរបស់កម្ពុជាទៅក្នុងតំបន់ និងពិភពលោក។ ជាលទ្ធផលក្នុងដំណាក់កាលទី១ ក្រសួងបានរៀបចំអនុក្រឹត្យលេខ ២០៨ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០១១ ស្តីពីការកែសម្រួលលើកំណត់សម្គាល់ II ឧបសម្ព័ន្ធ ២

នៃអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់ទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ ព្រមទាំងបានផ្សព្វផ្សាយជូនក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធដើម្បីអនុវត្ត។

## 2. *ការងារព័ត៌មានពាណិជ្ជកម្ម*

### 2.1. ការងារគ្រប់គ្រងព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម

ក្នុងឆ្នាំ២០១១ នេះ ក្រសួងពាណិជ្ជកម្ម បានបោះពុម្ពផ្សាយព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម ចំនួន ២៤ លេខ ស្មើនឹង ៤៨០០ក្បាល។ ទន្ទឹមនឹងនេះ ក្រសួងពាណិជ្ជកម្មបានខិតខំកែសម្រួលទាំងខ្លឹមសារ និងសោភ័ណភាព ដើម្បីឲ្យព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្មនេះ កាន់តែល្អប្រសើរឡើង។

### 2.2. កម្រងសៀវភៅស្ថិតិពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្ម សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) យកតួលេខស្ថិតិពាណិជ្ជកម្ម មករៀបរៀងចងក្រងជាសៀវភៅស្ថិតិពាណិជ្ជកម្ម ដែលរៀបចំតាមលក្ខណៈពិសេស គឺសរសេរតាមកម្មវិធី PHP+MYSQL បញ្ជ្រាបទិន្នន័យបញ្ចូលគ្នា ទើបស្ថាបនាជាសៀវភៅឡើង។

### 2.3. ការងារគ្រប់គ្រងគេហទំព័រ (Website) របស់ក្រសួងពាណិជ្ជកម្ម

បានបញ្ចូលជាប្រចាំ នូវរាល់សកម្មភាពថ្នាក់ដឹកនាំក្រសួងក្នុងគេហទំព័រ បញ្ចូលឈ្មោះក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុនបង្កើតថ្មី ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន ការបង្កើតសាខាក្នុងស្រុក ការបង្កើតសាខាក្រុមហ៊ុនបរទេស និងការរំលាយក្រុមហ៊ុន និង ស្ថិតិថ្លៃទំនិញប្រើប្រាស់សំខាន់ៗក្នុងស្រុក និងអន្តរជាតិ។

ជាពិសេស បានដាក់បញ្ចូលនូវច្បាប់ពាណិជ្ជកម្ម ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីជូនដំណឹង សេចក្តីសម្រេច សារាចរណែនាំ និងលិខិតបទដ្ឋានផ្សេងៗ។

គេហទំព័រ (Website: www.moc.gov.kh) កំពុងរៀបចំកែលម្អ ដោយរៀបចំមាតិកាគេហទំព័រទៅតាម Menu Sub-menu និងប្រភេទផ្សេងៗ ដើម្បីងាយស្រួលក្នុងការស្វែងរកព័ត៌មាន។ លើសពីនេះទៅទៀត បានបង្កើតប្រព័ន្ធបញ្ចូលព័ត៌មានស្ថិតិ បង្កើតក្រាហ្វិកវិភាគផ្សេងៗ ដោយស្វ័យប្រវត្តិក្នុងគេហទំព័រដើម្បីឲ្យគេហទំព័រមានព័ត៌មានពាណិជ្ជកម្មកាន់តែសម្បូរបែប ហើយគេហទំព័រនេះនឹងត្រូវ Upload ចូលក្នុង Server។

### 2.4. ការងារស្ថិតិពាណិជ្ជកម្ម

រៀបចំឯកសារជារបាយការណ៍ ស្តីពីសភាពការណ៍ថ្លៃទំនិញនៅក្នុងស្រុក និងថ្លៃទំនិញអន្តរជាតិសំខាន់ៗ ផ្ញើជូនឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាលបានចំនួន ៤៨ដង។

## 3. *ការបម្រើសេវាសាធារណៈ*

ការបម្រើសេវាសាធារណៈ ត្រូវបានផ្តោតជាសំខាន់លើការអនុវត្តនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីអភិវឌ្ឍន៍សង្គម និងបម្រើសំណូមពរប្រជាពលរដ្ឋ និងតាមរយៈការបង្រួតសេវារដ្ឋបាលឲ្យនៅជិតប្រជាពលរដ្ឋ ការអនុវត្តបែបបទរដ្ឋបាលតាមយន្តការច្រកចេញ-ចូលតែមួយ (ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ)។

បានដាក់ចេញជាប្រកាស និងសេចក្តីណែនាំថ្មី ស្តីពីការធ្វើប្រតិភូកម្មការងារពាណិជ្ជកម្ម ជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ជំនួសឲ្យលិខិតបទដ្ឋានពីមុន ដើម្បីពង្រឹងប្រសិទ្ធភាព គុណភាព ក្នុងការកែលម្អសេវាសាធារណៈ។ ក្រសួងពាណិជ្ជកម្ម បានចូលរួមកែសម្រួល និងដាក់បញ្ចូលនូវទម្រង់សេវារដ្ឋបាលសាធារណៈ ដែលពាក់ព័ន្ធនឹងផ្នែកពាណិជ្ជកម្ម ដូចជា ការចុះបញ្ជីពាណិជ្ជកម្ម ការចុះបញ្ជីម៉ាក ការសុំ

អាជ្ញាប័ណ្ណនាំចេញ ការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ។ល។ ចូលទៅក្នុងសៀវភៅកម្រងព័ត៌មានសេវារដ្ឋបាលសាធារណៈ ដើម្បីឲ្យមានលក្ខណៈសមស្របតាមឯកសារ ស្តីពីស្តង់ដារសេវាសាធារណៈប្រកបដោយតម្លាភាព ប្រសិទ្ធភាព ហើយដែលត្រូវបានយកទៅផ្សព្វផ្សាយយ៉ាងទូលំទូលាយ។

## 3.1. ការផ្តល់សេវាកម្មទាក់ទងនឹងម៉ាក

### *3.1.1. ការចុះបញ្ជីម៉ាក*

ក្រសួងពាណិជ្ជកម្ម បានឯកភាពចុះបញ្ជីម៉ាកចំនួន ៣.៦៥៩ម៉ាកក្នុងឆ្នាំ២០១១ ក្នុងនោះម៉ាកក្នុងស្រុកមានចំនួន ៦៥៤ និងម៉ាកបរទេសមានចំនួន ៣.០០៥។ បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាឆ្នាំ២០១០ ក្រសួងចុះបញ្ជីបានចំនួន ៣.០៣៦ម៉ាក គឺកើនឡើងចំនួន ៦២៣ម៉ាក ស្មើនឹង ២០,៥%។ ក្នុងឆ្នាំ២០១១នេះ ការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក សរុបមានចំនួន ៤.៤៥៩ម៉ាក។ បើប្រៀបធៀបទៅឆ្នាំ២០១០ ដែលទទួលបានចំនួន ៣.៩៦៩ម៉ាក គឺមានការកើនឡើងចំនួន ៤៩០ម៉ាក ស្មើនឹង ១២,៣% ដែលក្នុងនោះម៉ាកក្នុងស្រុកមានចំនួន ៨០៦ និងម៉ាកបរទេសមានចំនួន ៣.៦៥៣ ។

### *3.1.2. ការផ្តល់សេវាកម្មក្រោយចុះបញ្ជី*

ក្រសួងបានចុះបញ្ជីសាជាថ្មីជូនម្ចាស់ម៉ាកចំនួន ៨៧៨ម៉ាក និងបានកត់ត្រាលើការផ្លាស់ប្តូរផ្សេងៗដូចជាការផ្ទេរសិទ្ធិ ឬ ការប្តូរអាស័យដ្ឋានជាដើមបានចំនួន ១.២៨៩ម៉ាក។ ក្រៅពីនេះក្រសួងបានធ្វើការបញ្ជាក់លើការប្រើប្រាស់ ឬមិនប្រើប្រាស់ ម៉ាកជូនម្ចាស់ម៉ាកចំនួន ១.៦៩១ម៉ាក។

### *3.1.3. ការងារបោះពុម្ពផ្សាយព្រឹត្តិបត្រផ្លូវការ*

ក្រសួងបានផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការចុះបញ្ជីម៉ាកថ្មី និងការផ្លាស់ប្តូរផ្សេងៗ ជូនសាធារណៈជន តាមរយៈព្រឹត្តិប័ត្រផ្លូវការ (Official Gazette)។ ក្នុងឆ្នាំ២០១១ ក្រសួងបានបោះពុម្ពព្រឹត្តិប័ត្រផ្លូវការ សរុបចំនួន ៦០០ច្បាប់ ត្រូវជា ១២លេខ គឺចាប់ពីលេខ ១៣១ ដល់ ១៤២ ។

### *3.1.4. ការដោះស្រាយវិវាទរំលោភបំពានកម្មសិទ្ធិបញ្ញា និងការលុបម៉ាកចេញពីបញ្ជី*

ក្នុងឆ្នាំ២០១១ នេះ បានទទួលពាក្យបណ្តឹងចំនួន ៤២ករណី ស្មើ ៥៧ម៉ាក និងនៅសល់ពីឆ្នាំមុនៗចំនួន ២៣ករណី ស្មើ ៣០ម៉ាក សរុបមានចំនួន ៦៥ ករណី ស្មើ ៨៧ម៉ាក ។ ក្រសួងបានធ្វើការដោះស្រាយចំនួន ៣៣ករណី និងបដិសេធពាក្យបណ្តឹងចំនួន ៣ករណី។ ការដោះស្រាយទាំង ៣៣ករណី នេះ រួមមាន៖ ការលុបម៉ាកចេញពីបញ្ជីចំនួន ១៣ករណី ស្មើ ១៧ម៉ាក ធ្វើការសម្រុះសម្រួលដោយមានកំណត់ហេតុចំនួន ៨ករណី ធ្វើលិខិតបញ្ជាក់ពីភាពស្រដៀង និងសុពលភាពប្រើប្រាស់ម៉ាកមានចំនួន ១០ករណី កែតម្រូវម៉ាកចំនួន ២ករណី ហើយនៅសល់ ២៩ករណីទៀត កំពុងបន្តពិនិត្យ និងដោះស្រាយ។

បើធ្វើការប្រៀបធៀបការទទួលពាក្យបណ្តឹង ក្នុងឆ្នាំ ២០១១ ធៀបនឹងឆ្នាំ ២០១០ គឺមានការថយចុះ ២៨,៨១%។ ដោយឡែក ចំពោះការលុបម៉ាកចេញពីបញ្ជីក្នុងឆ្នាំ២០១១ នេះ មានចំនួន ១៧ម៉ាក បើធៀបនឹងឆ្នាំ២០១០ គឺមានការថយចុះចំនួន ៤៥,៣១%។

## 3.2. ការងារតម្កល់លិខិតជូនដំណឹងប្រតិបត្តិការដែលមានកិច្ចធានា

ការងារតម្កល់លិខិតជូនដំណឹង ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ផ្តល់សេវាតាមរយៈប្រព័ន្ធអ៊ីនធឺណិត គឺមានគេហទំព័រ www.setfo.gov.kh ។ ក្រសួងបានទទួលលិខិតចុះបញ្ជីតម្កល់លិខិតជូនដំណឹងតាមអេឡិចត្រូនិកសរុបចំនួន ៣.១១០ និង លិខិតជូនដំណឹងចំនួន ១.៣៣៨ ដែលក្នុងនោះមានទ្រព្យអរូបីមួយចំនួន និងចលនទ្រព្យរូបីមួយចំនួនជាភាគហ៊ុន។

### 3.3. ការចុះបញ្ជីពាណិជ្ជកម្ម និងការផ្តល់សេវាពាក់ព័ន្ធ

ច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ផ្តល់សារៈសំខាន់ជួយឲ្យរដ្ឋគ្រប់គ្រងបានរាល់សកម្មភាពរបស់សហគ្រាស ក្រុមហ៊ុន និងជួយដល់ការពង្រឹងវិស័យឯកជន ឲ្យទទួលបានការការពារផលប្រយោជន៍ ក្នុងការធ្វើពាណិជ្ជកម្មស្របតាមច្បាប់ បង្កភាពកក់ក្តៅដល់ពាណិជ្ជករ វិនិយោគិនជាតិ-អន្តរជាតិ ដែលជាផ្នែកមួយនៃការរួមចំណែកអភិវឌ្ឍន៍វិស័យឯកជន។ សេវាចុះបញ្ជីពាណិជ្ជកម្ម ត្រូវបានកែលម្អគុណភាពឲ្យសមស្របទៅតាមកាលៈទេសៈ និងស្ថានភាពសេដ្ឋកិច្ច ក៏ដូចជាតម្រូវការរបស់ម្ចាស់សហគ្រាស ក្រុមហ៊ុន សំខាន់គឺកាត់បន្ថយបែបបទ ពេលវេលា និងតម្លៃសេវា។

បណ្តាក្រុមហ៊ុន និងសហគ្រាសឯកបុគ្គល ដែលបានទទួលសេវាចុះបញ្ជីពាណិជ្ជកម្ម ពីក្រសួងពាណិជ្ជកម្ម មានដូចខាងក្រោម ៖

- ការចុះបញ្ជីរថ្មីរបស់ក្រុមហ៊ុន ការិយាល័យតំណាងពាណិជ្ជកម្ម និងសាខាក្រុមហ៊ុនបរទេស ក្នុងឆ្នាំ២០១១ មានចំនួន ៣.១៩០ ក្នុងនោះមានក្រុមហ៊ុនវិនិយោគចំនួន ១៩១ក្រុមហ៊ុន កើនឡើង ២០,៣៨%
- ការចុះបញ្ជីសហគ្រាសឯកបុគ្គលថ្មីមានចំនួន ៦២៩
- ការធ្វើវិសោធនកម្មក្រុមហ៊ុន ការិយាល័យតំណាងពាណិជ្ជកម្ម និងសាខាក្រុមហ៊ុនបរទេស មានចំនួន ២.៣១០ កើនឡើង ១១%
- ការធ្វើវិសោធនកម្មសហគ្រាសឯកបុគ្គលមានចំនួន ៧៧ កើនឡើង ១១,៥៩%
- ការលុបឈ្មោះក្រុមហ៊ុនមានចំនួន ៣៧ កើនឡើង ២,៧៨%
- និងការលុបឈ្មោះសហគ្រាសឯកបុគ្គលមានចំនួន ១។

<u>ការបំពេញប្រតិវេទន៍</u>

ក្រុមហ៊ុនដែលបានបំពេញប្រតិវេទន៍ឆ្នាំ២០១០ និងយកមកតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម ក្នុងឆ្នាំ២០១១ មានចំនួន ៣.៤៩០ ក្រុមហ៊ុន បើប្រៀបធៀបនឹងការបំពេញប្រតិវេទន៍ សម្រាប់ឆ្នាំ២០០៩ (តម្កល់ទុកក្នុងឆ្នាំ២០១០) មានចំនួន ២.៥៨០ក្រុមហ៊ុន ឃើញថាមានការកើនឡើង ៣៥,២៧%។

### 3.4. ការចុះបញ្ជីផ្តល់សិទ្ធិនាំចេញក្រោមប្រព័ន្ធអនុគ្រោះពន្ធ

ក្នុងឆ្នាំ២០១១ នេះ ក្រសួងបានផ្តល់សេវាចុះបញ្ជីផ្តល់សិទ្ធិនាំចេញក្រោមគម្រោងអនុគ្រោះពន្ធ សម្រាប់ក្រុមហ៊ុនថ្មី មានដូចតទៅ ៖

- ក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ចំនួន : ៥៧ ក្រុមហ៊ុន
- រោងចក្រផលិតស្បែកជើងចំនួន : ០៤ ក្រុមហ៊ុន
- រោងចក្រផ្សេងៗ ក្រៅពីសំលៀកបំពាក់ និងស្បែកជើងចំនួន : ១៣ ក្រុមហ៊ុន
- ក្រុមហ៊ុននាំចេញកសិផល និងសិប្បកម្មចំនួន : ៨៥ ក្រុមហ៊ុន

បច្ចុប្បន្នរោងចក្រកាត់ដេរសំលៀកបំពាក់ ផលិតស្បែកជើង ផលិតទោចក្រយាន និងរោងចក្រផលិតមុខទំនិញផ្សេងៗ កំពុងដំណើរការមានចំនួន ៣៧៨ រោងចក្រ ដែលមានកម្លាំងកម្មករបម្រើការងារសរុបចំនួន ៤០៤.១២២ នាក់ (កម្មការិនីចំនួន ៣៦៤.៥១៨ នាក់) ស្រូបបាននូវរូបិយប័ណ្ណជាសាច់ប្រាក់ប្រមាណ ៤០លានដុល្លារក្នុងមួយខែ។ ក្នុងនោះ រោងចក្រសំខាន់ៗមាន៖

- រោងចក្រកាត់ដេរសំលៀកបំពាក់ និងវាយនភ័ណ្ឌមានចំនួន ៣០៩ រោងចក្រ ដែលមានកម្លាំងកម្មករ បម្រើការងារសរុបចំនួន ៣៣៥.៨៣២ នាក់ (កម្មការិនីចំនួន ៣០៥.១៦៧ នាក់) ស្រូបបាននូវរូបិយប័ណ្ណ ជាសាច់ប្រាក់ប្រមាណ ៣៤ លានដុល្លារក្នុងមួយខែ ។
- រោងចក្រផលិតស្បែកជើងមានចំនួន ៤០ រោងចក្រ ដែលមានកម្លាំងកម្មករបម្រើការងារសរុប

ចំនួន ៦២.៨៧០ នាក់ (កម្មការិនីចំនួន ៥៦.១០៨ នាក់) ស្រូបបាននូវរូបបិយប័ណ្ណជាសាច់ប្រាក់ប្រមាណ ៥ លានដុល្លារក្នុងមួយខែ។

3.5. ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម

- ចេញលិខិតអនុញ្ញាត ប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ បានចំនួន ២.៣៣០ច្បាប់។

- ចេញលិខិតអនុញ្ញាតបិទស្លាកថ្លៃ ជារូបិយវត្ថុបរទេសជូនពាណិជ្ជករ និងអាជីវករនៅតាមរាជធានី-ខេត្ត បានចំនួន ២៥១ច្បាប់។

- មន្ទីរពាណិជ្ជកម្មរាជធានី និងខេត្តបានចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មចំនួន ១៨.៨៦២ច្បាប់ ស្មើនឹង ៨៥,៦២% នៃឆ្នាំ២០១០។

3.6. សកម្មភាពត្រួតពិនិត្យពាណិជ្ជកម្ម(ភាគីទី៣)

ក្នុងឆ្នាំ២០១១នេះ ក្រសួងពាណិជ្ជកម្ម (អគ្គនាយកដ្ឋានកាំកុងត្រូល) បានទទួលសំណើផ្តល់សេវាកម្មត្រួតពិនិត្យពាណិជ្ជកម្ម ចំនួន ១៦៨សំណើ ក្នុងនោះមាន អង្គការស្បៀងអាហារពិភពលោក ចំនួន ៨១សំណើ ក្រុមហ៊ុន SGS THAILAND ចំនួន ៦៨សំណើ និងបណ្តាក្រុមហ៊ុនឯកជនដទៃទៀតចំនួន ១៥សំណើ។

## II. សកម្មភាពទស្សនៈពាណិជ្ជកម្មដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណ

### 1. *ការងារសមាហរណកម្មសេដ្ឋកិច្ចសកល*

បន្ទាប់ពីកម្ពុជា បានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនៅខែ តុលា ឆ្នាំ២០០៤ ក្រសួងពាណិជ្ជកម្ម បានបន្តដើរតួនាទីយ៉ាងសកម្មនៅក្នុងគណ:កម្មាធិការអនុវត្តកាតព្វកិច្ច និងការសន្យារបស់កម្ពុជានៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក ដែលមានសមាជិកមកពីក្រសួង/ស្ថាប័នពាក់ព័ន្ធ ចំនួន ៣០ ចូលរួម។ កាតព្វកិច្ចទាំងនោះរួមមាន៖

- ការធ្វើកំណែទម្រង់ក្របខណ្ឌច្បាប់ ឲ្យស្របទៅនឹងកិច្ចព្រមព្រៀង និងបញ្ញត្តិទាំងឡាយរបស់អង្គការពាណិជ្ជកម្មពិភពលោក។

- ការរៀបចំគោលនយោបាយពាណិជ្ជកម្ម ដែលរួមមានការកែសម្រួលពន្ធគយ ដែលជាគោលនយោបាយពាណិជ្ជកម្មសំខាន់របស់កម្ពុជា និងការសម្រួលពាណិជ្ជកម្ម តាមរយ:ការកែសម្រួលនីតិវិធីនាំចេញនាំចូល និងតម្រូវការផ្នែកឯកសារនានាសំដៅបើកច្រកទីផ្សារសម្រាប់ទំនិញនាំចូល និងទទួលបានច្រកទីផ្សារបរទេសសម្រាប់ទំនិញនាំចេញរបស់កម្ពុជា រួមទាំងការបើកច្រកទីផ្សារសម្រាប់សេវាកម្មផង។

- ការអភិវឌ្ឍន៍គោលនយោបាយតាមវិស័យ ដែលពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មជាអន្តរជាតិ រួមមាន ការបង្កើតបទដ្ឋាន និងវិធានផ្សេងៗ រួមទាំងការការពារកម្មសិទ្ធិបញ្ញាផង ដើម្បីធ្វើឲ្យកម្ពុជាអាចឈរជើងក្នុងលក្ខណ:ស្មើភាពជាមួយប្រទេសជាសមាជិកដទៃទៀត។

- ការជំរុញកំណើនតាមរយ:ការលើកស្ទួយ និងជំរុញផ្នែកឯកជនឲ្យចូលរួមក្នុងការអភិវឌ្ឍន៍ និងការវិនិយោគដោយលើកទឹកចិត្តឲ្យមានតម្លាភាព និងការធានាផ្សេងៗនៅក្នុងផ្នែកវិនិយោគ និងការធ្វើពាណិជ្ជកម្ម។

នៅក្នុងឆ្នាំ២០១១កន្លងមកនេះ ដែលជារបត់សំខាន់មួយរបស់កម្ពុជា ក្នុងនាមជាប្រទេសអភិវឌ្ឍន៍តិចតួច ដែលក្រោយពីក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកអស់រយ:ពេល ៦ឆ្នាំ ចាំបាច់ត្រូវធ្វើការត្រួតពិនិត្យឡើងវិញនូវគោលនយោបាយពាណិជ្ជកម្ម និងការប្រតិបត្តិនានារបស់ខ្លួនដើម្បីឲ្យមាន

អនុលោមភាពទៅនឹងការបញ្ញត្តិនានា និងឆ្លើយតបតាមការសន្យារបស់ខ្លួន ដែលបានធ្វើឡើងកាលពីចរចាចូលជាសមាជិកអង្គការអន្តរជាតិនេះ។

ក្នុងឆ្នាំ២០១១ក្រសួងពាណិជ្ជកម្ម ក្នុងទិសដៅជំរុញសមាហរណកម្មសេដ្ឋកិច្ចសកលឲ្យដើរស្របគ្នានឹងសមាហរណកម្មសេដ្ឋកិច្ចតំបន់បានសម្រេចនូវសមិទ្ធិផលមួយចំនួនដូចខាងក្រោម:

### 1.1. ការងារផ្តល់ព័ត៌មាន (Notification)

ការងារផ្តល់ព័ត៌មានទៅអង្គការពាណិជ្ជកម្មពិភពលោក គឺជាផ្នែកមួយនៃគោលការណ៍តម្លាភាពដែលតម្រូវឲ្យបំពេញជាកាតព្វកិច្ចដោយប្រទេសជាសមាជិកទាំងអស់។ ក្នុងឆ្នាំ២០១១ ក្រសួងពាណិជ្ជកម្មបានធ្វើការផ្តល់ព័ត៌មានចំនួន ០៧ករណី តាមការតម្រូវរបស់អង្គការពាណិជ្ជកម្មពិភពលោកដែលរួមមាន៖

- ការផ្តល់ព័ត៌មានអំពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម (Technical Barrier to Trade) ដែលក្នុងនោះយើងបានប្រមូលផ្តុំនូវបញ្ញត្តិទាំងឡាយដែលបានចងក្រងឡើងក្នុងពេលថ្មីៗដោយវិទ្យាស្ថានស្តង់ដារកម្ពុជា ទាក់ទងនឹងលក្ខខណ្ឌតម្រូវសម្រាប់ផលិតកម្មឧស្សាហកម្មក្នុងស្រុក និងផលិតផលនាំចូលមួយចំនួនដើម្បីផ្ញើជូនទៅឲ្យលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក។
- ការផ្តល់ព័ត៌មានអំពីវិស័យកម្មសិទ្ធិបញ្ញា (Intellectual Property Rights) ដែលរួមមានការវិវឌ្ឍន៍ថ្មីៗ ទាក់ទងនឹងការបង្កើតច្បាប់ និងបញ្ញត្តិផ្សេងៗ ក្នុងវិស័យកម្មសិទ្ធិបញ្ញាដែលបានធ្វើឡើងទៅតាមការតម្រូវរបស់អង្គការពាណិជ្ជកម្មពិភពលោក ព្រមទាំងបានផ្តល់ព័ត៌មានឆ្លើយតបទៅនឹងកម្រងសំណួរ អំពីការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញានៅក្នុងប្រទេសកម្ពុជា។
- ការផ្តល់ព័ត៌មានអំពីការផ្តល់អាជ្ញាប័ណ្ណនាំចូល (Import Licensing) ដែលតម្រូវចំពោះផលិតផលមួយចំនួនរួមមាន ផលិតផលគីមី ផលិតផលឱសថ ផលិតផលនេសាទ/ត្រី និងផលិតផលទាក់ទងនឹងព្រៃឈើ។
- ការផ្តល់ព័ត៌មានអំពីការគាំទ្រចំពោះវិស័យកសិកម្ម (State Support of Agriculture) ដែលជាផ្នែកមួយគោរពតាមកិច្ចព្រមព្រៀងអំពីកសិកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោកដែលអនុញ្ញាតឲ្យមានការឧបត្ថម្ភធនមួយចំនួន ប៉ុន្តែតម្រូវឲ្យមានការផ្តល់ព័ត៌មានជាក់លាក់អំពីសកម្មភាពនេះ។
- ការផ្តល់ព័ត៌មានអំពីការចងក្រងបញ្ញត្តិច្បាប់ ស្តីពីឧបាស្រ័យពាណិជ្ជកម្ម (Trade Remedies) ដែលក្នុងនោះរួមមាន ការរៀបចំបញ្ញត្តិអំពីការលក់បង្ខូចថ្លៃ វិធានការប្រឆាំងតបវិញ និងវិធានការការពារដែលកម្ពុជាកំពុងតែរៀបចំឲ្យបានសមស្របទៅតាមការតម្រូវរបស់អង្គការពាណិជ្ជកម្មពិភពលោក។
- ការផ្តល់ព័ត៌មានអំពីការវាយតម្លៃពន្ធគយ (Customs Valuation) ដែលក្នុងនោះរួមមាននីតិវិធី និងការកំណត់តម្លៃគិតពន្ធសម្រាប់ទំនិញនាំចូល ព្រមទាំងបញ្ញត្តិច្បាប់នានា ដែលទាក់ទងនឹងការវាយតម្លៃពន្ធគយនេះ។
- ការផ្តល់ព័ត៌មានអំពីការត្រួតពិនិត្យទំនិញមុនពេលផ្ទុក (Pre Shipment Inspection) ដែលរួមមាននីតិវិធី រយៈពេល ព្រមទាំងបញ្ញត្តិពាក់ព័ន្ធផ្សេងៗ និងកិច្ចសម្រួលពាណិជ្ជកម្មដែលបច្ចុប្បន្ននេះកំពុងបានអនុវត្តនៅក្នុងប្រទេសកម្ពុជាចំពោះទំនិញនាំចូល និងទំនិញនាំចេញ។

ទន្ទឹមនឹងនេះ ក្រសួងក៏បានធ្វើការសិក្សាទៅលើ ការផ្តល់ព័ត៌មានចូលមកវិញ ពីសំណាក់លេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីតាមដានចំពោះការអនុវត្តរបស់ប្រទេសជាសមាជិកនានា មកលើរបបពាណិជ្ជកម្មអន្តរជាតិ ក្នុងគោលបំណងផ្តល់អនុសាសន៍ឲ្យទាន់ពេលវេលាករណីមានផលប៉ះពាល់ចំពោះទីផ្សារនាំចេញរបស់កម្ពុជា។

## 1.2. ការងាររៀបចំការត្រួតពិនិត្យឡើងវិញគោលនយោបាយពាណិជ្ជកម្មកម្ពុជា (TPR)

ការត្រួតពិនិត្យឡើងវិញនូវគោលនយោបាយពាណិជ្ជកម្ម (Trade Policy Review) គឺជាផ្នែកមួយនៃកាតព្វកិច្ច ដែលប្រទេសសមាជិកនីមួយៗ ត្រូវធ្វើជាមួយលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីផ្ទៀងផ្ទាត់ឡើងវិញ នូវការប្រព្រឹត្តធៀបទៅនឹងកិច្ចសន្យា ដែលបានធ្វើឡើងក្នុងការចរចាពហុភាគី។ ឆ្នាំ២០១១ គឺជាឆ្នាំទី៦ ដែលកម្ពុជាក្នុងនាមជាប្រទេសអភិវឌ្ឍន៍តិចតួច ចាំបាច់ត្រូវបំពេញកាតព្វកិច្ចនេះ។ ដើម្បីឲ្យសម្រេចបាននូវគោលដៅនេះ ក្រសួងពាណិជ្ជកម្មរួមសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ព្រមទាំងលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក បានរៀបចំឯកសារចាំបាច់ សម្រាប់ចងក្រងជាអត្ថបទរបាយការណ៍ពិស្តារមួយ អំពីគោលនយោបាយពាណិជ្ជកម្មកម្ពុជា និងទិដ្ឋភាពសេដ្ឋកិច្ចទូទៅ ដោយរួមបញ្ចូលទាំងទិសដៅសម្រាប់ការអនុវត្តក្នុងពេលអនាគតផង ដើម្បីដាក់ជូនទៅឲ្យសមាជិកទាំងអស់របស់អង្គការពាណិជ្ជកម្មពិភពលោក ពិនិត្យ និងធ្វើការវាយតម្លៃ។ បន្ទាប់ពីបានបញ្ជូនឯកសារទាំងនេះទៅឲ្យប្រទេសជាសមាជិកទាំងអស់ កម្ពុជាយើងបានទទួលសំណួរត្រឡប់វិញប្រហែលជាង ១០០ សំណួរ ហើយយើងបានផ្តល់ចម្លើយចំពោះសំណួរទាំងនេះ ដោយទទួលបានការពេញចិត្តពីសំណាក់ម្ចាស់សំណួរទាំងអស់។ នៅដើមខែវិច្ឆិកា ឆ្នាំ២០១១ ក្រោមការអនុញ្ញាតដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា គណៈប្រតិភូអន្តរក្រសួងមួយក្រុម ដែលដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានទៅចូលរួមបកស្រាយ និងការពារគោលនយោបាយពាណិជ្ជកម្មកម្ពុជា នៅលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោកនាទីក្រុងហ្សឺណែវ ប្រទេសស្វីស ដោយទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ នាំមកនូវការកោតសរសើរ និងការវាយតម្លៃខ្ពស់ពីសំណាក់ប្រទេសជាសមាជិកទាំងអស់របស់អង្គការពាណិជ្ជកម្មពិភពលោក ចំពោះការខិតខំប្រឹងប្រែង និងសមិទ្ធផលនានាដែលកម្ពុជាទទួលបាន បន្ទាប់ពីក្លាយជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក។

នៅចុងឆ្នាំ២០១១នេះដែរ ដើម្បីឆ្លើយតបទៅនឹងអនុសាសន៍មួយចំនួន ដែលទទួលបានពីសមាជិកទាំងអស់ នៅក្នុងដំណើរការត្រួតពិនិត្យឡើងវិញនៃគោលនយោបាយពាណិជ្ជកម្មកម្ពុជា ក្រសួងពាណិជ្ជកម្មបានរៀបចំកម្មវិធីការងារ (Work Program) មួយដែលមាន ១០០ចំណុច សម្រាប់បំពេញកាតព្វកិច្ចរបស់កម្ពុជានៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក។ កម្មវិធីការងារនេះ នឹងត្រូវដាក់ជូនទៅស្នើសុំការសម្រេចពីគណៈរដ្ឋមន្ត្រីក្នុងពេលឆាប់ៗនេះ ដើម្បីឲ្យក្លាយទៅជាកម្មវិធីការងាររបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងអង្គការពាណិជ្ជកម្មពិភពលោក។

## 1.3. ការងារផ្ទៀងផ្ទាត់ច្បាប់ (Legal Compliance)

ការងារផ្ទៀងផ្ទាត់ច្បាប់ ធ្វើឡើងដើម្បីធានានូវអនុលោមភាពទៅនឹងវិធាន និងកិច្ចព្រមព្រៀងទាំងឡាយរបស់អង្គការពាណិជ្ជកម្មពិភពលោក។ ដើម្បីសម្រេចបាននូវកាតព្វកិច្ចនេះ ក្នុងឆ្នាំ២០១១ ក្រសួងពាណិជ្ជកម្ម បានជំរុញការរៀបចំច្បាប់ឧបាស្រ័យពាណិជ្ជកម្ម ដោយធ្វើការពិនិត្យកែសម្រួលឡើងវិញនូវសេចក្តីព្រាងច្បាប់ ដែលបានធ្វើកន្លងមក សំដៅធ្វើឲ្យសេចក្តីព្រាងច្បាប់នេះ មានលក្ខណៈជាច្បាប់ជាតិ ដោយរក្សាទុកតែគោលការណ៍សំខាន់ៗ ដែលតម្រូវដោយកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ហើយដកចេញនូវនីតិវិធីនៃការអនុវត្តសម្រាប់បញ្ចូលទៅក្នុងអនុក្រឹត្យវិញ។ ទន្ទឹមនឹងនេះដើម្បីរក្សាបាននូវការអនុវត្តល្អ (Best Practices) នៅក្នុងការចងក្រងច្បាប់ និងបញ្ញត្តិផ្សេងៗ ក្រសួងពាណិជ្ជកម្ម ក៏បានចូលរួមនៅក្នុងគម្រោងសាកល្បងការសិក្សាផលប៉ះពាល់របស់ច្បាប់-បញ្ញត្តិផ្សេងៗដែលជាគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី សហការជាមួយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបំពេញកិច្ចការនេះ ជាមួយនឹងក្រសួង៣ទៀត គឺក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន និងក្រសួង

ឧស្សាហកម្ម រ៉ែ និងថាមពល។ នៅក្នុងឆ្នាំ២០១១នេះដែរ ក្រសួងពាណិជ្ជកម្មបានធ្វើការសិក្សាផ្ទៀងផ្ទាត់ឡើងវិញ ចំពោះបញ្ញត្តិផ្សេងៗ ទាក់ទងនឹងវិស័យធានារ៉ាប់រង អាជីវកម្មអាកាសចរណ៍ស៊ីវិល ការធ្វើអាជីវកម្មខ្សាច់ ការគ្រប់គ្រង និងបែងចែកប្រព័ន្ធប្រេកង់ទូរគមនាគមន៍ និងការកែសម្រួលបញ្ញត្តិមួយចំនួនក្នុងការបើចំហរទីផ្សារសេវាក្នុងស្រុកដូចជា បញ្ញត្តិ ស្តីពីការងាររបស់គណៈមេធាវី ការអនុវត្តច្បាប់ការងារកម្ពុជាចំពោះកម្មករ ដែលបម្រើការងារនៅលើនាវាដែលមានបង្គោទង់ជាតិកម្ពុជា និងបានចុះបញ្ជីនៅកម្ពុជា។ល។

## 1.4. ការងារពិនិត្យឃ្លាំមើលដំណើរការចរចាកញ្ចប់ទីក្រុងដូហា ( Doha Round Negotiation)

ការចរចាទីក្រុងដូហា និងការអនុវត្តរបៀបវារៈរបស់ទីក្រុងដូហា គឺជាការផ្តល់អត្ថប្រយោជន៍មួយចំពោះប្រទេសអភិវឌ្ឍន៍តិចតួចដូចជាកម្ពុជា។ ក្រសួងពាណិជ្ជកម្មបានធ្វើការតាមដាន ចូលរួមយ៉ាងសកម្មក្នុងការចរចានេះ តាមរយៈស្ថានបេសកកម្មអចិន្ត្រៃយ៍របស់កម្ពុជា ប្រចាំនៅទីក្រុងហ្សឺណែវ ដើម្បីកំណត់គោលដៅអាទិភាពរួម ជាមួយនឹងបណ្តាប្រទេសអភិវឌ្ឍន៍តិចតួចដទៃទៀត សំដៅទទួលបាននូវការរួចពន្ធនាំចូលទាំងស្រុង និងការគ្មានកំណត់កូតា ចំពោះទំនិញរបស់ប្រទេសអភិវឌ្ឍន៍តិចតួចនាំចូលទៅកាន់ទីផ្សាររបស់ប្រទេសអភិវឌ្ឍន៍ ព្រមទាំងការបើកច្រកទីផ្សារសេវាកម្មរបស់ប្រទេសទាំងនោះ ដើម្បីទទួលយកការនាំចេញកម្លាំងពលកម្មរបស់ប្រទេសអភិវឌ្ឍន៍តិចតួច។ ក្រសួងពាណិជ្ជកម្មរៀបចំការបំពេញបែបបទជាផ្លូវការ ក្នុងការទទួលយកពិធីសារ ស្តីពីការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មទាក់ទងនឹងវិស័យកម្មសិទ្ធិបញ្ញា (TRIPS) ដើម្បីទទួលបានអត្ថប្រយោជន៍ដូចមានចែងក្នុង សេចក្តីប្រកាសទីក្រុងដូហា ស្តីពីកិច្ចព្រមព្រៀង TRIPS និងបញ្ហាសុខភាពសាធារណៈ ដែលបើកផ្លូវឲ្យកាន់តែងាយស្រួលឡើងចំពោះការនាំចេញ-នាំចូល និងការផលិតឱសថចាំបាច់សម្រាប់ព្យាបាលជំងឺឆ្លងនានា តាមរយៈយន្តការផ្តល់អាជ្ញាប័ណ្ណដោយបង្ខំ (Compulsory Licensing)។

# 2. *ការងារសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន*

## 2.1. ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមភាព

ក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី១៩ បានប្រកាសឲ្យប្រើក្របខណ្ឌអាស៊ាន សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយសមភាព (AFEED) និងបានឯកភាព ឲ្យក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន ជាអង្គភាពសមស្របក្នុងការត្រួតពិនិត្យ ការអនុវត្តទូទៅនៃ AFEED និងបានឯកភាពបន្ថែមទៀតលើជំហានដូចខាងក្រោម:

ក-លេខាធិការអាស៊ានពិចារណាលើកម្មវិធីការងារបច្ចុប្បន្ន និងគំនិតផ្តួចផ្តើមកសាងសមត្ថភាពនៅតាមផ្នែក រួមទាំងផ្នែកដែលចំណុះក្រុមការងារជាន់ខ្ពស់ និងកម្មវិធីសហប្រតិបត្តិការអនុតំបន់ និងការតភ្ជាប់អាស៊ាន ដើម្បីខិតខំប្រឹងប្រែងរួមគ្នា និងកាត់បន្ថយជាអតិបរិមានូវការងារដែលជាន់គ្នា។

ខ-ដោយឈរលើមូលដ្ឋាននេះ ឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន កំណត់គម្លាត និងគូសវាសផែនការការងារ ទាក់ទងនឹងគម្លាតឆ្ពោះទៅឆ្នាំ២០១៥ និងធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃលំហាត់នេះ ជូនក្រុមប្រឹក្សា សហគមន៍សេដ្ឋកិច្ចអាស៊ានសម្រាប់ការណែនាំ និងពន្យល់បន្ថែមទៀត។

គ- ការអនុវត្តជាក់ស្តែង និងអនុសាសន៍គោលនយោបាយនានា ចាំបាច់ត្រូវធ្វើឲ្យស្របទៅនឹងស្ថានភាពមួយចំនួន និងតម្រូវការរបស់ប្រទេស CLMV នីមួយៗ។

## 2.2. ពាណិជ្ជកម្មផ្នែកទំនិញ

លេខាធិការដ្ឋានអាស៊ាន បង្កើតឯកសារគោលនយោបាយ ស្តីពីប្រភពផ្តល់ព័ត៌មានពាណិជ្ជកម្ម

អាស៊ាន (ATR) រួមបញ្ចូលព័ត៌មាន ដែលផ្តល់ដោយប្រទេសសមាជិកអាស៊ាន ដើម្បីផ្តល់ការជ្រើសរើសដំណោះស្រាយដែលអាចទៅរួចឆ្ពោះទៅរកការបង្កើត ATR។ ឯកសារគោលនយោបាយនោះ នឹងត្រូវដាក់ជូនឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ានពិចារណា ក្នុងកំឡុងពេល កិច្ចប្រជុំចង្កៀតរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន នៅខែកុម្ភៈ ឆ្នាំ២០១២ ។

ការបញ្ជាក់វិញ្ញាបនប័ត្រប្រភពដើមទំនិញដោយខ្លួនឯង ជាគម្រោងសាកល្បង ក្រោមវិធាន និងលក្ខខណ្ឌដែលខុសគ្នា បង្កើតដោយឥណ្ឌូណេស៊ី ហ្វីលីពីន និងវៀតណាម។

ការលុបបំបាត់របាំងមិនមែនពន្ធគយ បានបញ្ជាក់ពីភាពចាំបាច់សម្រាប់តម្លាភាព ការផ្តល់សេចក្តីជូនដំណឹងឲ្យបានត្រឹមត្រូវ និងកិច្ចពិភាក្សា មុននឹងអនុវត្តវិធានការ ដែលមិនសម្រួលពាណិជ្ជកម្ម ហើយបានអនុម័ត ការណែនាំនីតិវិធីចេញអាជ្ញាប័ណ្ណនាំចូលអាស៊ាន ដែលមានគោលបំណងលុបបំបាត់ផ្នែករបាំងនៃនីតិវិធីចេញអាជ្ញាប័ណ្ណនាំចូលអាស៊ាន ដែលបានប្រើប្រាស់ដោយរដ្ឋសមាជិក។

ក្នុងការងារ CCA ត្រូវតែផ្តល់អាទិភាពដល់ការងាររបស់ខ្លួន ដើម្បីផ្តោតការយកចិត្តទុកដាក់ឲ្យកាន់តែទូលំទូលាយលើៈ (ក) ការអនុវត្តការសន្យា ATIGA (ខ) វិធានការមិនមែនពន្ធគយ (គ) ការលើកតម្កើងនីតិវិធីបញ្ជាក់វិញ្ញាបនប័ត្រប្រភពដើមទំនិញដោយខ្លួនឯង (ឃ) អនុវត្តបញ្ហាដែលលើកឡើងដោយប្រទេសសមាជិក និង (ង) បញ្ហាជាតុចូលដែលលើកឡើងដោយវិស័យឯកជន ដើម្បីលើកតម្កើងពាណិជ្ជកម្មនៅក្នុងតំបន់អាស៊ាន។

អនុលោមភាពគុណភាព និងស្តង់ដារ បានជំរុញឲ្យ ACCSQ បញ្ចប់ឲ្យបានឆាប់ នូវគំនិតផ្តួចផ្តើមវិធានការក្រោមការគ្រប់គ្រងរបស់ ACCSQ អនុលោមតាមពេលវេលាដែលមានក្នុង AEC Scorecard និងស្នើឲ្យប្រធាន ACCSQ រាយការណ៍ពីវឌ្ឍនភាព ការប្រឈមរបស់ខ្លួន នាកិច្ចប្រជុំ SEOM លើកក្រោយ។

### 2.3. ពាណិជ្ជកម្មផ្នែកសេវាកម្ម

សេរីភាវូបនីយកម្មវិស័យសេវាកម្ម ជាបញ្ហាលំបាកសម្រាប់ប្រទេសសមាជិកអាស៊ានទាំងអស់។ ទិសដៅដើម្បីបញ្ចប់កញ្ចប់សន្យាទី៩ នៅឆ្នាំ២០១២ បានជំរុញឲ្យប្រទេសសមាជិកខិតខំពុះពារធ្វើយ៉ាងណា និងយ៉ាងហោចណាស់ផ្តល់ជាបឋមនូវកញ្ចប់សន្យានេះ នៅត្រឹមបំណាច់ឆ្នាំ២០១២។

ក្នុងកិច្ចប្រជុំ បានប្រគល់ភារកិច្ចឲ្យប្រទេសសមាជិកនីមួយៗ ធ្វើការវាយតម្លៃដោយខ្លួនឯង និងបង្កើតផែនការសកម្មភាព ដើម្បីដោះស្រាយការលំបាករបស់ពួកគេ ក្នុងការឈានទៅសម្រេចទិសដៅ AFAS ឆ្នាំ២០១៥ ហើយត្រូវចែករំលែកទៅឲ្យ CCS យ៉ាងយូរបំផុតពីរសប្តាហ៍ មុនពេលឯកសារទាំងនេះប្រគល់ជូន AEM Retreat លើកទី ១៨ នៅខែ កុម្ភៈ ឆ្នាំ ២០១២។

### 2.4. ការវិនិយោគ

កាលបរិច្ឆេទពិតប្រាកដនៃការចូលជាធរមាននៃ ACIA ជាកាលបរិច្ឆេទ ដែលលេខាធិការដ្ឋានអាស៊ាន ទទួលបានលិខិតចុងក្រោយនៃការប្រកាស ឲ្យប្រើដោយប្រទេសជាសមាជិក។ នៅពេលទទួលបានការបញ្ជាក់ពី CCI ចំពោះបញ្ជីនេះ អគ្គលេខាធិការអាស៊ាននឹងសរសេរទៅកាន់ក្រុមប្រឹក្សា AIA ដើម្បីស្វែងរកការប្រកាស ឲ្យប្រើប្រាស់បញ្ជីកក់ ដោយ AEM Retreat នៅខែ កុម្ភៈ ឆ្នាំ២០១២។

អនុវត្តតាមផែនការលម្អិតរបស់អាស៊ាន ត្រូវខិតខំធ្វើយ៉ាងណា លុបបំបាត់ឧបសគ្គចំពោះការវិនិយោគ ដើម្បីធ្វើឲ្យប្រសើរឡើងនូវបរិយាកាសវិនិយោគក្នុងតំបន់។

### 2.5. សហគ្រាសធុនតូច និងមធ្យម (SMEs)

បញ្ជាក់ពីតួនាទីជាយុទ្ធសាស្ត្ររបស់ SMEs ក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចឲ្យបានស៊ីជម្រៅ

តាមរយៈ វិភាគទានដើម្បីឆ្ពោះទៅរកលំហូរពាណិជ្ជកម្ម និងវិនិយោគកាន់តែស៊ីជម្រៅក្នុងអាស៊ាន រដ្ឋមន្ត្រីបានអំពាវនាវឲ្យអនុវត្តទាន់ពេលវេលា គ្រប់សកម្មភាពនៅក្នុងផែនការសកម្មភាពយុទ្ធសាស្ត្រអាស៊ាន សម្រាប់អភិវឌ្ឍន៍ SMEs ២០១០-២០១៥ ។

អង្គប្រជុំ បានទទួលស្គាល់អំពីសារៈសំខាន់នៃការអភិវឌ្ឍន៍សេដ្ឋកិច្ចដែលមានសមភាព ដើម្បីធានាផលប្រយោជន៍ពីសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ត្រូវបានចែករំលែកក្នុងចំណោម SMEs និងប្រទេសអភិវឌ្ឍន៍តិចតួចក្នុងអាស៊ាន។

### 2.6. ទំនាក់ទំនងរវាងវិស័យសាធារណៈ និងឯកជន

គូសបញ្ជាក់អំពីសារៈសំខាន់នៃកិច្ចប្រជុំពិគ្រោះយោបល់ និងការសន្ទនាជាមួយវិស័យឯកជនជាទៀងទាត់ ដើម្បីជួយអាស៊ាននៅក្នុងដំណើរការសមាហរណកម្ម កិច្ចប្រជុំបានអនុម័តនូវវិធាន នៃនីតិវិធីសម្រាប់ទាក់ទងជាមួយវិស័យឯកជន ដើម្បីធានាបាននូវកិច្ចសហការរវាងវិស័យសាធារណៈ និងឯកជនឲ្យកាន់តែមានប្រសិទ្ធិភាពថែមទៀត។

## 3. *កិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសដៃគូអាស៊ាន*

### 3.1. ដំណើរផ្សព្វផ្សាយរបស់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានទៅកាន់ប្រទេសដៃគូ

គោលបំណងនៃការរៀបចំដំណើរផ្សព្វផ្សាយ របស់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានទៅកាន់ប្រទេសដៃគូ ដើម្បីទាក់ទាញវិនិយោគពីប្រទេសទាំងនោះ ឲ្យមកវិនិយោគនៅក្នុងតំបន់អាស៊ាន រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានបានឯកភាពរៀបចំដំណើរផ្សព្វផ្សាយទី១ ទៅកាន់ប្រទេសជប៉ុន គឺពីថ្ងៃទី ២៥-២៨ ខែ មេសា ឆ្នាំ២០១២ ` បន្ទាប់មកនឹងរកពេលវេលារៀបចំ ដំណើរផ្សព្វផ្សាយទី២ ទៅកាន់សហរដ្ឋអាមេរិក និងទី៣ ទៅកាន់សហភាពអឺរ៉ុប។

### 3.2. កិច្ចប្រជុំពិគ្រោះយោបល់រវាងអាស៊ាន-ចិន

យោងឯកសាររបស់លេខាធិការដ្ឋានអាស៊ាន ស្តីពីសំណើរបស់ហុងកុង សុំចូលរួមនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន និងដោយពិចារណាលើទស្សនៈដែលបានលើកឡើង ដោយសមាជិក លេខាធិការដ្ឋានអាស៊ាន ត្រូវធ្វើការសិក្សាដ៏ទូលំទូលាយ និងដោយឯករាជ្យ (មានន័យថា សិក្សាលើពាណិជ្ជកម្មទំនិញ សេវា និងវិនិយោគ) ដែលនឹងវិភាគពីការជះឥទ្ធិពល បញ្ហាពាក់ព័ន្ធ និងប្រឈមនានានៃការចូលរួម ACFTA របស់ហុងកុង។ ក្នុងកិច្ចប្រជុំក៏បានឯកភាពលើសំណើ ឲ្យហុងកុង ផ្តល់នូវព័ត៌មានលម្អិត ស្តីពីរបបពាណិជ្ជកម្ម និងសេដ្ឋកិច្ចរបស់ខ្លួន ដោយរួមបញ្ចូលទាំងទិន្នន័យពាណិជ្ជកម្ម និងវិនិយោគផងដែរ។ សំណើរបស់ហុងនឹងត្រូវសម្រេចអនុម័តនៅកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន (AEM) លើកទី៤៤ ក្នុងខែ សីហា ឆ្នាំ២០១២ នេះ។

### 3.3. អាស៊ាន និងជប៉ុន

បញ្ហានៅសេសសល់លើការចរចាពាណិជ្ជកម្មសេវាកម្ម និងវិនិយោគ នៅក្រោមកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលាយអាស៊ាន-ជប៉ុន (AJCEP) អាស៊ាននឹងប្រកាន់ជំហរម៉ឺងម៉ាត់ បន្តការចរចាតាមវិធីសាស្ត្របញ្ជីវិជ្ជមាន ក្នុងការធ្វើសេរីភាវូបនីយកម្មសេវាកម្ម ដូចដែលអាស៊ាន បានធ្វើជាមួយដៃគូនានារបស់ខ្លួនកន្លងមក។ ដោយសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការបញ្ចប់ការចរចាសេវាកម្ម និងវិនិយោគ កិច្ចប្រជុំបានស្នើឲ្យសហប្រធាន AJCEP អាស៊ាន នាំពាក្យប្រាប់ទៅសហប្រធាន AJCEP ជប៉ុន អំពីជំហររបស់អាស៊ានថា ការចរចាទាំងសេវាកម្ម និងវិនិយោគ នឹងត្រូវព្យួរហូតដល់បញ្ហាវិធីសាស្ត្រ

ធ្វើសេរីភាវូបនីយកម្មសេវាកម្ម ត្រូវបានដោះស្រាយប្រកបដោយការពេញចិត្ត។

### 3.4. កិច្ចប្រជុំពិគ្រោះយោបល់រវាង អាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់

កម្មវិធីឧបត្ថម្ភកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ AANZFTA សម្រាប់រយៈពេល ៥ឆ្នាំ (២០១០-២០១៤) មានថវិកាសរុបប្រមាណ ២០-២៥ លានដុល្លារអូស្ត្រាលី។ រហូតមកដល់ពេលនេះ ការចំណាយសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអស់ចំនួន ៣,២ លានដុល្លារអូស្ត្រាលី ហើយទឹកប្រាក់ចំនួន ៥,៨ លានដុល្លារអូស្ត្រាលី នឹងត្រូវចំណាយលើគម្រោងថ្មីៗ ដែលបានឯកភាពជាគោលការណ៍ សម្រាប់អនុវត្តនៅក្នុងឆ្នាំ២០១១-២០១២។

### 3.5. កិច្ចប្រជុំពិភាក្សាជាមួយអាស៊ាន-ឥណ្ឌា

ម៉ាឡេស៊ីជាប្រទេសសម្របសម្រួល AIFTA បានរៀបចំឯកសារចរចាដោយរំលេចនូវកញ្ចប់នៃជំហរ និងសម្បទាននានាដែលអាស៊ានអាចបញ្ជូនទៅឲ្យឥណ្ឌា ដើម្បីឲ្យឥណ្ឌាអាចទទួលយកសំណើរបស់អាស៊ាននៅក្នុងវិស័យមួយចំនួន ដែលមិនសូវលំបាកក្នុងការចរចា AIFTA។ ឯកសារនេះ នឹងត្រូវដាក់ជូនគណៈកម្មាធិការចរចាពាណិជ្ជកម្មអាស៊ាន-ឥណ្ឌា (AITNC) ដោយចម្លងជូន SEOM យ៉ាងយូរត្រឹមថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១២។

### 3.6. អាស៊ាន-អាមេរិក

- បានផ្លាស់ប្តូរយោបល់អំពីសកម្មភាពដែលនឹងត្រូវអនុវត្តបន្ត ដោយមានការអនុម័តផែនការសកម្មភាពឆ្នាំ២០១២ សម្រាប់កិច្ចព្រមព្រៀងក្របខ័ណ្ឌពាណិជ្ជកម្ម និងវិនិយោគអាស៊ាន-អាមេរិក រាប់បញ្ចូលទាំងការរៀបចំវេទិកាពាណិជ្ជកម្ម និង បរិស្ថានអាស៊ាន-អាមេរិក ទស្សនកិច្ចការងាររបស់អាស៊ានទៅសហរដ្ឋអាមេរិក វេទិកាចរចារនីជីថលអាស៊ាន-អាមេរិក និងវេទិកាសេវាកម្មគាំពារសុខភាពអាស៊ាន-អាមេរិក។

- បានជំរុញឲ្យឥណ្ឌូនេស៊ី បន្តធ្វើការជាមួយអាមេរិក ស្តីពីការអនុវត្តផែនការការងារនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌពាណិជ្ជកម្ម និងវិនិយោគអាស៊ាន-អាមេរិក ដោយពិចារណានូវយោបល់ទាំងឡាយ ដែលបានលើកឡើងក្នុងការពិភាក្សាលើសារៈសំខាន់ (១) ការកសាងសមត្ថភាពអាស៊ាន អំពីសេវាគាំពារសុខភាព (២) ការកើនឡើងនៃការយកចិត្តទុកដាក់របស់វិស័យឯកជន ក្នុងការបង្កើនចំណេះដឹង និង (៣) ការយល់ដឹងចំពោះ Cloud computing និងការរិះរកលទ្ធភាពរៀបចំដំណើរផ្សព្វផ្សាយរបស់អាស៊ានទៅកាន់សហរដ្ឋអាមេរិក នៅត្រីមាសទី៣ ក្នុងឆ្នាំ២០១២ ប្រសិនបើមិនអាចបាន គឺនៅក្នុងឆ្នាំ២០១៣។

កិច្ចប្រជុំបានទទួលស្គាល់ពីសារៈសំខាន់នៃពាណិជ្ជកម្ម និងបរិស្ថាន។ ប៉ុន្តែប្រសិនបើ អាមេរិកបន្តជំរុញឲ្យអាស៊ានចូលរួមក្នុងវេទិកាពាណិជ្ជកម្ម និងបរិស្ថាន ការចូលរួមគួរតែបង្កើននូវចំណេះដឹង អំពីទំនាក់ទំនងរវាងពាណិជ្ជកម្ម និងបរិស្ថាន។ កិច្ចប្រជុំក៏បានព្រមព្រៀងថា ការចូលរួមនៅក្នុងវេទិកាពាណិជ្ជកម្ម និងវិនិយោគនៅពេលខាងមុខ មិនគួរកម្រិតត្រឹមតែ SEOM និង ASOEN ទេ មន្ត្រីពីស្ថាប័នពាក់ព័ន្ធ ដូចជា កសិកម្ម និងនេសាទ គួរត្រូវអញ្ជើញឲ្យចូលរួមដែរ។

### 3.7. កិច្ចពិគ្រោះយោបល់រវាងអាស៊ាន និងរុស្ស៊ី

ក្នុងខណៈពេលដែលមានការឯកភាពឲ្យបញ្ចប់ផែនទីវិថីអាស៊ាន-រុស្ស៊ី រុស្ស៊ីបែរជាលើក ឡើងនូវសំណើ ឲ្យបញ្ចូលប្រទេសបេឡារុស និងកាហ្សាក់ស្តង់ ហើយស្នើប្តូរឈ្មោះផែនទីវិថី អាស៊ាន-រុស្ស៊ី ឲ្យទៅជាផែនទីវិថីអាស៊ាន-លំហរសេដ្ឋកិច្ចរួម (Common Economic Space-CES)។ រដ្ឋសមាជិកទាំងអស់ នឹងពិគ្រោះយោបល់ជាមួយក្រសួងការបរទេស ចំពោះសំណើរបស់ រុស្ស៊ី ជាពិសេស បេឡារុស និង

កាហ្សាក់ស្តង់ ដែលគ្មានឋានៈផ្លូវការនៅក្នុងភាពជាដៃគូសន្ទនារបស់អាស៊ាន។

3.8. អាស៊ាន - GCC

កិច្ចប្រជុំបានព្រមព្រៀង អញ្ជើញក្រុមប្រឹក្សាសហប្រតិបត្តិឈូងសមុទ្រពែក (GCC) ឲ្យចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ SEOM-GCC ដែលធ្វើឡើងបន្តបន្ទាប់ និងកិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ច SEOM 2/43 សំដៅរៀបចំធ្វើជាផ្លូវការនូវការលើកកម្ពស់ទំនាក់ទំនងពាណិជ្ជកម្ម និងសេដ្ឋកិច្ចអាស៊ាន និង GCC។

3.9. អាស៊ាន - សហភាពអឺរ៉ុប

បានអនុម័តរៀបចំកិច្ចប្រជុំកំពូលធុរកិច្ចអាស៊ាន-សហភាពអឺរ៉ុបលើកទី២ នៅរាជធានីភ្នំពេញក្នុងខែមេសា ឆ្នាំ២០១២។

4. *កិច្ចសហប្រតិបត្តិការអនុតំបន់*

4.1. កិច្ចប្រជុំរដ្ឋមន្ត្រីស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ាន (AMBDC)

បានកត់សំគាល់ពីស្ថានការណ៍អនុវត្តគម្រោង AMBDC ដែលមានចំនួន ៥១ គម្រោង រាប់ទាំងគម្រោងតភ្ជាប់ផ្លូវដែកសឹង្ហបូរី-គុនមីង (SKRL) ពាក់ព័ន្ធលើវិស័យសំខាន់ៗ ដូចជាៈ វិស័យហេដ្ឋារចនាសម្ព័ន្ធពាណិជ្ជកម្ម និងវិនិយោគ កសិកម្ម ព្រៃឈើ ឧស្សាហកម្ម ទេសចរណ៍ អភិវឌ្ឍន៍ធនធានមនុស្ស និងវិទ្យាសាស្ត្របច្ចេកទេស។ ភាគីចិនបានសម្តែងនូវឆន្ទៈល្អក្នុងការជំរុញឲ្យគម្រោង SKRL ឲ្យមានដំណើរការទៅមុខបន្ត និងឲ្យតម្លៃទៅលើហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ក្នុងតំបន់ និងអនុតំបន់។

4.2. កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចមេគង្គ-ជប៉ុន

បានពិនិត្យលើ "ផែនការសកម្មភាពនៃគំនិតផ្តួចផ្តើមកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ឧស្សាហកម្មមេគង្គ-ជប៉ុន" ហើយបានវាយតម្លៃខ្ពស់ ចំពោះការអនុវត្តដោយរលូននូវផែនការសកម្មភាពនេះ ក្នុងការអភិវឌ្ឍន៍នូវសសរស្តម្ភទាំង៤ ខាងលើ ជាពិសេសវិស័យហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង ដូចជា ការអភិវឌ្ឍន៍កំពង់ផែ Cai Mep-Thi Vai ស្ពានអ្នកលឿង និងស្ពានមេគង្គទី៣ ការអនុវត្តលើការអង្កេតទូលំទូលាយ ទៅលើសក្តានុពលនៃកសិកម្ម និងអាជីវកម្មកែច្នៃម្ហូបអាហារ។

ឯកភាព អភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង និងកិច្ចសម្រួលពាណិជ្ជកម្មឲ្យមានប្រសិទ្ធភាពដោយផ្សារភ្ជាប់ កិច្ចសហប្រតិបត្តិការជាមួយគំនិតផ្តួចផ្តើមទាំងឡាយក្នុងអាស៊ាន និងអាស៊ីខាងកើត ដូចជា កម្មវិធី GMS ផែនការមេស្តីពីការតភ្ជាប់អាស៊ាន ផែនការអភិវឌ្ឍន៍អាស៊ានទូលំទូលាយ និង Asia Cargo Highway Initiative។ កិច្ចប្រជុំបានផ្តល់ឯនុសាសន៍ឲ្យពង្រឹង និងធ្វើឲ្យប្រសើរឡើងថែមទៀត នូវវិស័យសេវាកម្មខ្នាតតូច និងមធ្យម ក៏ដូចជាវិស័យសេវាកម្ម និងឧស្សាហកម្មថ្មី។

4.3. កិច្ចប្រជុំនៃគណៈកម្មធិការសម្របសម្រួលចម្រុះស្តីពីតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម (CLV)

បានចុះហត្ថលេខា លើការព្រមព្រៀងសហប្រតិបត្តិការគ្រប់គ្រង និងដំណើរការគេហទំព័រ សម្រាប់តំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម និងបានឯកភាពពង្រឹងនូវកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងបី លើវិស័យសន្តិសុខ សុវត្ថិភាព ស្ថេរភាពសង្គមក្នុងតំបន់ ដោយបង្កើតប្រព័ន្ធទំនាក់ទំនងទាន់ហេតុការណ៍ ទៅតាមកម្រិតក្នុងប្រទេសនីមួយៗ ដើម្បីសហការបង្ក្រាបការរត់ពន្ធគ្រឿងញៀន ការជួញដូរមនុស្ស អំពើភាវរកម្មឆ្លងតំបន់ ក៏ដូចជាការស្នើសុំជំនួយសង្គ្រោះបន្ទាន់លើសេវាសុខាភិបាលជាដើម ។

ឧត្តមមន្ត្រីជាអ្នកសម្របសម្រួល និងសហការគ្នារៀបចំដំណើរផ្សព្វផ្សាយ ទៅកាន់ប្រទេស មួយចំនួន ដើម្បីផ្សព្វផ្សាយគោលនយោបាយអនុគ្រោះ ពិសេសផែនការមេ ស្តីពីការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ក្នុងតំបន់ត្រីកោណ ក្នុងគោលដៅទាក់ទាញជំនួយ និងលំហូរពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ឲ្យចូលមកក្នុងតំបន់ត្រីកោណ។

## 4.4. កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចកម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម (CLMV)

ការអនុវត្តផែនការសកម្មភាពរបស់ CLMV ឆ្នាំ២០១១ បានផ្តោតសំខាន់លើវិស័យសេដ្ឋកិច្ច-ពាណិជ្ជកម្ម ការអភិវឌ្ឍន៍ធនធានមនុស្ស និងដំណើរការនៃកិច្ចសហប្រតិបត្តិការ។

កម្ពុជាបានបញ្ជូនឈ្មោះ Focal Point ពីររូប ជូនប្រទេសជាសមាជិក និងតំណាងលេខាធិការដ្ឋានអាស៊ាន។

ប្រទេសជាសមាជិកត្រូវបង្កើតគម្រោង ដែលនៅក្រោមផែនការសកម្មភាពឆ្នាំ២០១២ ដោយប្រើនូវទម្រង់ដែលបានសម្រេចដោយរដ្ឋមន្ត្រីសេដ្ឋកិច្ច CLMV កាលពីកិច្ចប្រជុំរដ្ឋមន្ត្រី CLMV លើកទី៣ នៅម៉ាណាដូ។

## 5. *កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មក្នុងក្របខ័ណ្ឌទ្វេភាគី និងកិច្ចសហប្រតិបត្តិការអន្តរជាតិនានា*

## 5.1. កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មកម្ពុជា-វៀតណាម

ក្រុមការងារក្រសួងពាណិជ្ជកម្មកម្ពុជា និងក្រុមការងារក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មវៀតណាម បានចុះហត្ថលេខាលើកំណត់ហេតុការងារចំនួន ០៣លើក ស្តីពីការសិក្សាស្រាវជ្រាវ និងចងក្រងផែនការមេអភិវឌ្ឍន៍បណ្តាញផ្សារពាណិជ្ជកម្មតាមព្រំដែនកម្ពុជា-វៀតណាមឆ្នាំ ២០១០-២០២០ និងគម្រោងសាងសង់ផ្សារសាកល្បងព្រំដែនកម្ពុជា-វៀតណាម នៅតំបន់សេដ្ឋកិច្ចពិសេសថាវីកំពង់ចាម។

បានរៀបចំកិច្ចប្រជុំលើកទី៨ ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ពាណិជ្ជកម្មតាមព្រំដែន តាមការគ្រោងទុកប្រកបដោយជោគជ័យ នៅទីក្រុងកំពង់ចាម ខេត្តកំពង់ចាមពីថ្ងៃទី២៨ ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ដោយមានការអញ្ជើញចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្រុមហ៊ុន និងពាណិជ្ជករនៃប្រទេសទាំងពីរប្រមាណ ២៧៨នាក់។ ក្នុងអំឡុងពេលកិច្ចប្រជុំភាគីកម្ពុជា និងវៀតណាម បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ពាណិជ្ជកម្ម តាមព្រំដែនកម្ពុជា-វៀតណាម និងបានរៀបចំវេទិកាធុរៈកិច្ចពាណិជ្ជកម្ម និងវេទិកាពិគ្រោះយោបល់លើផែនការមេអភិវឌ្ឍន៍បណ្តាញផ្សារពាណិជ្ជកម្មតាមព្រំដែនកម្ពុជា-វៀតណាម ឆ្នាំ២០១០-២០២០។

### *5.1.1. កិច្ចប្រជុំពិភាក្សាកែសម្រួលលើ C/O form S របស់កម្ពុជា ជាមួយនិង C/O form X របស់វៀតណាម*

ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម នៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានឯកភាពលើគំរូវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទម្រង់ អេស (C/O Form S) សម្រាប់ប្រើប្រាស់ទំនិញ និងផលិតផលស្ថិតក្រោមភាពអនុគ្រោះពន្ធសូន្យភាគរយរបស់កម្ពុជានាំចូលទៅវៀតណាម និងគំរូវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទម្រង់អិច (C/O Form X) សម្រាប់ប្រើប្រាស់ទំនិញ និងផលិតផលស្ថិតក្រោមភាពអនុគ្រោះពន្ធសូន្យភាគរយរបស់វៀតណាម នាំចូលមកកម្ពុជា។

### *5.1.2. ការចរចាកិច្ចសម្របសម្រួលពាណិជ្ជកម្មទ្វេភាគី*

ក្រុមការងារក្រសួងពាណិជ្ជកម្មកម្ពុជា និងក្រុមការងារក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មវៀតណាម បានចុះហត្ថលេខាលើកំណត់ហេតុការងារចំនួន ០២ ស្តីពីការធ្វើបច្ចុប្បន្នភាពលើកិច្ចសម្រប

សម្រួលពាណិជ្ជកម្មទ្វេភាគីរវាងក្រសួងពាណិជ្ជកម្មនៃកម្ពុជា និងក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មនៃវៀតណាម សម្រាប់អនុវត្តឆ្នាំ២០១០-២០១១។

ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានធ្វើការចរចាស្តីពី កិច្ចសម្របសម្រួលជំរុញពាណិជ្ជកម្មទ្វេភាគី ដែលក្នុងនោះ កម្ពុជាគ្រោងផ្តល់ភាពអនុគ្រោះពន្ធនាំចូលស្មើសូន្យភាគរយ "0%" ដល់ភាគីវៀតណាម ចំនួន ១៨បន្ទាត់ពន្ធគយ និងភាគីវៀតណាមគ្រោងផ្តល់ភាពអនុគ្រោះពន្ធនាំចូលស្មើសូន្យភាគរយ "0%" ចំនួន ៣៩បន្ទាត់ពន្ធគយ ដល់ភាគីកម្ពុជាសម្រាប់អនុវត្តឆ្នាំ ២០១២-២០១៣។

### 5.2. កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយសហគមន៍អឺរ៉ុប

បានធ្វើកិច្ចសហប្រតិបត្តិការជាមួយតំណាងសហគមន៍អឺរ៉ុបប្រចាំនៅភ្នំពេញ និងបានបញ្ជូនទិន្នន័យការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញនាំចេញជាប្រចាំទៅសហគមន៍អឺរ៉ុបជូន SIGL ដែលមានស្នាក់ការនៅប្រទេសបែលហ្ស៊ិក។

បានសហការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ វិធានប្រភពដើមទំនិញថ្មីរបស់សហគមន៍អឺរ៉ុប នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដើម្បីផ្សព្វផ្សាយវិធាន បទបញ្ញត្តិ និងក្រមថ្មីៗ របស់សហគមន៍អឺរ៉ុប ជូនដល់ក្រុមហ៊ុន រោងចក្រ សិប្បកម្ម និងស្ថាប័នពាក់ព័ន្ធដែលធ្វើការនាំចេញទំនិញទៅបណ្តាប្រទេសទ្វីបអឺរ៉ុប។

### 5.3. កិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ឡាវ

កិច្ចប្រជុំទ្វេភាគីជាមួយរដ្ឋមន្ត្រីឧស្សាហកម្ម និងពាណិជ្ជកម្មឡាវ ដោយភាគីទាំងពីរបានផ្តោតលើការពិភាក្សា:

- ការពង្រឹង និងពង្រីកទំហំពាណិជ្ជកម្មទ្វេភាគី
- ការពង្រឹងទំនាក់ទំនងពាណិជ្ជកម្មតាមព្រំដែន
- កិច្ចសហការលើវិស័យដឹកជញ្ជូនទំនិញឆ្លងកាត់
- កិច្ចសហការរៀបចំ និងការចូលរួមពិព័រណ៍ពាណិជ្ជកម្មប្រចាំឆ្នាំ
- ការកែសម្រួលកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និងការរៀបចំកិច្ចប្រជុំគណៈកម្មការចម្រុះ។

### 5.4. កិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-អូស្ត្រាលី

នៅកិច្ចប្រជុំ G20 ប្រធានាធិបតីចិនបានប្រកាសផ្តល់ DFQF ចំនួន ៩៧% ដល់ LDCs។ កម្ពុជាបានស្នើអូស្ត្រាលីថា នៅកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី WTO លើកទី៨ ចុងឆ្នាំ២០១១ ជួយជំរុញសហរដ្ឋអាមេរិកឲ្យផ្តល់ DFQF ចំនួន ៩៨% ដល់ LDCs ដូចបានសន្យានៅហុងកុង កាលពីឆ្នាំ ២០០៥។

## 6. *ការងារវិស័យកម្មសិទ្ធិបញ្ញា*

### 6.1. ការងារគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា និងការរៀបចំច្បាប់-បទបញ្ញត្តិកម្មសិទ្ធិបញ្ញា

- បានរៀបចំប្រកាសស្តីពី "ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ក្នុងព្រះរាជាណាចក្រកម្ពុជា" ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១១។

- បានបញ្ចប់សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតអនុគណៈកម្មាធិការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា និងអនុគណៈកម្មាធិការអប់រំ និងផ្សព្វផ្សាយ ដែលនឹងត្រូវដាក់ជូនគណៈរដ្ឋមន្ត្រីនៅត្រីមាសទី១ ឆ្នាំ២០១២។

- សិក្សាស្រាវជ្រាវដោយសហការជាមួយ WIPO រៀបចំអនុក្រឹត្យស្តីពី «វិធានការណ៍តាមព្រំដែន» ដែលចែងលម្អិត អំពីនីតិវិធីអនុវត្តការទប់ស្កាត់ការរំលោភបំពានកម្មសិទ្ធិបញ្ញាតាមព្រំដែន ដោយអនុញ្ញាត

ឲ្យម្ចាស់សិទ្ធិ ដាក់ពាក្យទៅអាជ្ញាធរគយ ឬកាំកុងត្រួលជាមុន ដើម្បីផ្អាកការនាំចូលទំនិញដែលសង្ស័យ ឬមានការរំលោភបំពានកម្មសិទ្ធិបញ្ញា។

- រៀបចំអនុក្រឹត្យស្តីពី "ការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ( Sub-Decree on Enforcement of IPRs)" ក្នុងគោលបំណងចាត់វិធានការណ៍ឲ្យមានប្រសិទ្ធិភាពជាងមុន ដោយកិច្ចសហការរវាងអង្គភាពពាក់ព័ន្ធដូចជា តុលាការ ព្រះរាជអាជ្ញា នគរបាលសេដ្ឋកិច្ច និងនាយកដ្ឋានទទួលបន្ទុកកម្មសិទ្ធិបញ្ញានៃស្ថាប័នផ្សេងៗ។

- បានបញ្ចប់សេចក្តីព្រាងច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលនឹងត្រូវដាក់ជូនគណៈរដ្ឋមន្ត្រីនៅត្រីមាសទី១ ឆ្នាំ២០១២។

- សិក្សាពីផលចំណេញ និងផលប៉ះពាល់ក្នុងការចូលពិធិសារទីក្រុងម៉ាឌ្រីត ស្តីពីការចុះបញ្ជីម៉ាកជាអន្តរជាតិ និងសន្ធិសញ្ញាស្តីពីម៉ាក។

## 6.2. ការងារផ្សព្វផ្សាយ

បានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងពាក់ព័ន្ធ និងអង្គការអន្តរជាតិដែលជាដៃគូ ធ្វើការរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលបានចំនួន ០៨វគ្គ ក្នុងនោះមានសិក្ខាសាលាថ្នាក់តំបន់ចំនួន ០១វគ្គ មានសិក្ខាកាមសរុបចំនួន ៨២០ នាក់។ បន្ថែមលើនេះទៅទៀត ក្រសួងក្នុងនាមជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា បានធ្វើការចាត់បញ្ជូនសិក្ខាកាមទៅចូលរួមសិក្ខាសាលាក្រៅប្រទេស ចំនួន ៥០លើក ដែលរួមមានសិក្ខាកាមសរុប ៩៨នាក់ ក្នុងនោះមានសិក្ខាកាមមកពីក្រសួងពាណិជ្ជកម្មចំនួន ៥០នាក់ សិក្ខាកាមមកពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលចំនួន ១៦នាក់ និងសិក្ខាកាមមកពីក្រសួង និងស្ថាប័ននានា ចំនួន ២៨នាក់។

## 6.3. ការងារសហប្រតិបត្តិការ

គណៈកម្មាធិការជាតិ គ្រប់គ្រងកម្មសិទ្ធិបញ្ញា បានយកចិត្តទុកដាក់យ៉ាងខ្លាំង លើការងារសហប្រតិបត្តិការជាតិ និងអន្តរជាតិ ដោយពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយអង្គភាពកម្មសិទ្ធិបញ្ញាបរទេស អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកការឧបត្ថម្ភទាំងសម្ភារៈ បច្ចេកទេស និងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពមន្ត្រី និងអង្គភាពកម្មសិទ្ធិបញ្ញា បានទទួលលទ្ធផលដូចខាងក្រោម៖

- នៅក្នុងបរិបទអាស៊ាន (AWGIPC) កម្ពុជាបានចូលរួមរៀបចំផែនការការងារកម្មសិទ្ធិបញ្ញាអាស៊ានសម្រាប់ឆ្នាំ ២០១១-២០១៥ និងកម្មវិធីការងារកម្មសិទ្ធិបញ្ញាអាស៊ាន ២០១២-២០១៥ ដែលបច្ចុប្បន្ន កម្ពុជាកំពុងរៀបចំផែនការសកម្មភាព និងជាអ្នកដឹកនាំ ដើម្បីឲ្យប្រទេសជាសមាជិកអាស៊ានអនុវត្តឲ្យមានប្រសិទ្ធភាពលើគម្រោងចំនួន ៣ គឺៈ (១) គម្រោងកាត់បន្ថយពេលវេលាការចុះបញ្ជីការពារម៉ាកឲ្យមកនៅត្រឹមរយៈពេលប្រាំមួយខែ ក្នុងករណីគ្មានការជំទាស់ (២) គម្រោងផ្សព្វផ្សាយព័ត៌មានប្រកាសនីយបត្រតក្កកម្ម (៣) គម្រោងគាំទ្រចំណេះដឹងប្រពៃណី (Traditional Knowledge)។

- ក្នុងក្របខ័ណ្ឌការងារសហប្រតិបត្តិការកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ជាមួយការិយាល័យកម្មសិទ្ធិបញ្ញារដ្ឋនៃសាធារណៈរដ្ឋប្រជាមានិតចិន (SIPO) នាថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០១១។ អនុស្សរណៈនេះ មានគោលបំណងទទួលស្គាល់សារៈប្រយោជន៍ពីការលើកកម្ពស់ទំនាក់ទំនងកិច្ចសហប្រតិបត្តិការ ក្នុងវិស័យកម្មសិទ្ធិបញ្ញា ដើម្បីជំរុញសេដ្ឋកិច្ច ពាណិជ្ជកម្ម វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា រវាងសាធារណៈរដ្ឋប្រជាមានិតចិន និងព្រះរាជាណាចក្រកម្ពុជា នៅក្រសួងពាណិជ្ជកម្ម។

- ក្នុងក្របខ័ណ្ឌគម្រោងអតិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (TDSP) គណៈកម្មាធិការជាតិ

គ្រប់គ្រងកម្មសិទ្ធិបញ្ញាកំពុងអនុវត្តគម្រោង ស្តីពីការលើកតម្កើងការបណ្តុះបណ្តាល និងបង្រៀនកម្មសិទ្ធិបញ្ញា ក្រោមគម្រោង TDSP ដែលមានទឹកប្រាក់ចំនួន ១១០.០០០ ដុល្លារអាមេរិក។ បច្ចុប្បន្នការអនុវត្តគម្រោងនេះ សម្រេចបានប្រមាណ ៨០% ដែលនឹងគ្រោងបញ្ចប់នៅខែ មីនា ឆ្នាំ ២០១២ ខាងមុខ។

### 6.4. ការអនុវត្តគម្រោងអាទិភាពពង្រឹងវិស័យកម្មសិទ្ធិបញ្ញា

ក្នុងចំណោមគម្រោងអាទិភាពទាំង ៣៩ ក្រសួងបានអនុវត្តចប់គម្រោងចំនួន ១២ និងកំពុងអនុវត្តគម្រោងចំនួន ១២ទៀត ដែលគ្រោងនឹងបញ្ចប់នៅឆ្នាំ២០១២។ ចំណែកឯគម្រោងដែលមិនទាន់បានអនុវត្តមានចំនួន ១៥ ក្រសួងគ្រោងអនុវត្តនៅ ៣ឆ្នាំ ខាងមុខ។

## 7. *ទំហំពាណិជ្ជកម្មនៃការនាំចេញ-នាំចូលទំនិញ*

ក្នុងឆ្នាំ២០១១ សកម្មភាពពាណិជ្ជកម្ម មានការវិវត្តន៍ទៅល្អប្រសើរជាងឆ្នាំ២០១០ លើគ្រប់វិស័យពិសេសការនាំចេញផលិតផលកម្ពុជា ទៅកាន់បណ្តាប្រទេសក្នុងតំបន់ និងពិភពលោក។ ជាក់ស្តែងទំហំពាណិជ្ជកម្មកម្ពុជា សម្រេចបាន ១១.៥៧៨ លានដុល្លារអាមេរិក ក្នុងនោះការនាំចេញសម្រេចបាន ៤.៨៧៦ លានដុល្លារអាមេរិក កើនឡើងលើសឆ្នាំ២០១០ ចំនួន ២៧,១៥% គិតជាទឹកប្រាក់កើន ១.៣៨២ លានដុល្លារអាមេរិក។ រីឯការនាំចូលមានទឹកប្រាក់ ៦.៦០២លានដុល្លារអាមេរិក កើនឡើងចំនួន ២៧,៦២% គិតជាទឹកប្រាក់កើន ១.៨២៤ លានដុល្លារអាមេរិក។

ដោយឡែកទំហំពាណិជ្ជកម្មរវាងកម្ពុជា និងវៀតណាម សម្រេចបានក្នុងរង្វង់ទឹកប្រាក់ ២.៨០០ លានដុល្លារអាមេរិក លើសពីការព្យាករណ៍ពីមុនដែលមានកម្រិតត្រឹម ២.៥០០ លានដុល្លារអាមេរិក។

## 8. *ការនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម*

ក្នុងឆ្នាំ២០១១នេះ ក្រសួងពាណិជ្ជកម្ម បានចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ និងអាជ្ញាប័ណ្ណនាំចេញ ជូនបណ្តាក្រុមហ៊ុន សហគ្រាស និងសមាគមអ្នកនាំចេញផលិតផលទៅកាន់ទីផ្សារទ្វីបអឺរ៉ុប ទ្វីបអាមេរិក ទ្វីបអាហ្វ្រិក ទ្វីបអាស៊ី ទ្វីបអូសេអានី និងទីផ្សារប្រទេសផ្សេងៗទៀត គិតជាទឹកប្រាក់សរុបប្រមាណ ៥.៨០២.១៨៥.១៤៥ ដុល្លារអាមេរិក ប្រើប្រៀបធៀបឆ្នាំ២០១០ មានទឹកប្រាក់នាំចេញ ៣.៨៣៥.៦៣២.៣៥០ ដុល្លារអាមេរិក មានការកើនឡើងប្រមាណ ១.៣៦៦.៥៥២.៧៩៤ ដុល្លារអាមេរិក ស្មើនឹង ៣៩,៧៨%។

### 8.1. ការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក

តាមការប៉ាន់ប្រមាណក្នុងឆ្នាំ២០១១នេះ កម្ពុជាធ្វើការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក មានទឹកប្រាក់សរុបប្រមាណ ២.១២២.០៧៩.៧៦១ ដុល្លារអាមេរិក បើធៀបនឹងឆ្នាំ ២០១០ ទឹកប្រាក់នាំចេញមានការកើនឡើងប្រមាណ ២៦៣.៣៤១.៨៨៥ ដុល្លារអាមេរិក ស្មើនឹង ១៤,១៧%។

### 8.2. ការនាំចេញទៅកាន់ទីផ្សារកាណាដា

តាមការប៉ាន់ប្រមាណក្នុងឆ្នាំ២០១១នេះ កម្ពុជាធ្វើការនាំចេញទៅកាន់ទីផ្សារកាណាដា មានទឹកប្រាក់សរុបប្រមាណ ៣៩៤.៧៥០.៨១៣ ដុល្លារអាមេរិក បើធៀបនឹងឆ្នាំ២០១០ ទឹកប្រាក់នាំចេញមានការកើនឡើង ១១១.២០៤.៦៦៥ ដុល្លារអាមេរិក ស្មើនឹង ៣៩,២២%។

### 8.3. ការនាំចេញទៅកាន់ទីផ្សារផ្សេងៗក្នុងទ្វីបអាមេរិក (ក្រៅពីសហរដ្ឋអាមេរិក និងកាណាដា)

តាមការប៉ាន់ប្រមាណក្នុងឆ្នាំ២០១១នេះ កម្ពុជាធ្វើការនាំចេញទៅកាន់ទីផ្សារផ្សេងៗ ក្នុងទ្វីប

អាមេរិក (ក្រៅពីសហរដ្ឋអាមេរិក និងកាណាដា) មានទឹកប្រាក់សរុបប្រមាណ ១០៩ លានដុល្លារអាមេរិក បើធៀបនឹងឆ្នាំ២០១០ ទឹកប្រាក់នាំចេញមានការកើនឡើងប្រមាណ ៤៧លានដុល្លារ ស្មើនឹង ៧៦,១១%។

### 8.4. ការនាំចេញទៅកាន់ទ្វីបអឺរ៉ុប ទ្វីបអាហ្វ្រិក និងសាធារណរដ្ឋសង្គមនិយមវៀតណាម

បានចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ A N & S ជូនក្រុមហ៊ុន រោងចក្រ សហគ្រាស និងសិប្បកម្ម ដែលបាននាំចេញទំនិញ ទៅកាន់បណ្តាប្រទេសស្ថិតក្នុង ទ្វីបអឺរ៉ុប (សហគមន៍អឺរ៉ុប និងក្រៅសហគមន៍អឺរ៉ុប) ទ្វីបអាហ្វ្រិក និងសាធារណរដ្ឋសង្គមនិយមវៀតណាមសម្រាប់ឆ្នាំ២០១១ មានទឹកប្រាក់សរុបចំនួន ១.៥៤៧.០៧៧.៩៩៣ ដុល្លារអាមេរិក បើប្រៀបធៀបនឹងឆ្នាំ២០១០ មានទឹកប្រាក់ចំនួន ៩០២.២៧២.០៩៣ ដុល្លារអាមេរិក គឺកើនឡើង ៧១,៤៦%។

តួលេខនាំចេញទៅកាន់សហគមន៍អឺរ៉ុប មានទឹកប្រាក់សរុបចំនួន ១.៣៩៤.៧៣៥.៦០៨ ដុល្លារអាមេរិក បើប្រៀបធៀបនឹងឆ្នាំ២០១០ មានទឹកប្រាក់ចំនួន ៨៤២.៥១៩.៥៦៧ ដុល្លារអាមេរិក គឺកើនឡើង ៦៥,៥៤%។

តួលេខនាំចេញទៅកាន់ទីផ្សារក្រៅសហគមន៍អឺរ៉ុប (NON EU) មានទឹកប្រាក់សរុប ចំនួន ៨៧.៧២០.២៥៨ ដុល្លារអាមេរិក បើប្រៀបធៀបនឹងឆ្នាំ២០១០ ដែលមានទឹកប្រាក់ចំនួន ៤៧.០៤៩.៦៧៥ ដុល្លារអាមេរិក គឺកើនឡើង ៨៦,៤៤%។

តួលេខនាំចេញទៅកាន់ទីផ្សារទ្វីបអាហ្វ្រិក មានទឹកប្រាក់ចំនួន ១១.១២៧.៦៦១ ដុល្លារអាមេរិក បើប្រៀបធៀបនឹងឆ្នាំ២០១០ មានទឹកប្រាក់ចំនួន ៥.៣៩២.៨៥១ដុល្លារអាមេរិក គឺកើនឡើង ១០៦,៣៤%។

តួលេខនាំចេញទៅកាន់ទីផ្សារសាធារណរដ្ឋសង្គមនិយមវៀតណាម (C/O Form S ) ដោយស្ថិតក្រោមភាពអនុគ្រោះពន្ធអត្រាសូន្យភាគរយ មានទឹកប្រាក់ចំនួន ៥៣.៤៩៤.៤៦៦,០៤ ដុល្លារអាមេរិក បើប្រៀបធៀបនឹងឆ្នាំ២០១០ មានទឹកប្រាក់ចំនួន ៧.៣១៥.០០០ដុល្លារអាមេរិក គឺកើនឡើង ៦៣១,៣០%។

### 8.5. ការនាំចេញទៅកាន់ទ្វីបអាស៊ី និង អូសេអានី

បានចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញតាមទម្រង់ផ្សេងៗជូន ក្រុមហ៊ុន សហគ្រាស ដែលនាំចេញទៅទ្វីបអាស៊ី និងអូសេអានី មានទឹកប្រាក់សរុប ៩៧៧.២១៦.៣០០ដុល្លារអាមេរិក បើប្រៀបធៀបទៅនឹងឆ្នាំ២០១០ កើនឡើង ៥០%។

### 8.6. ការងារត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ C/O

#### *8.6.1. ការពិនិត្យទំនិញមុន និងក្រោយការស្នើសុំ C/O*

បានចុះត្រួតពិនិត្យសង្វាក់ផលិតកម្ម និងលទ្ធភាពផលិតកម្មតាមរោងចក្រ សហគ្រាស និងក្រុមហ៊ុន ដែលនាំចេញ ផលិតផលសំលៀកបំពាក់ ផលិតផលស្បែកជើង និងផលិតផលផ្សេងៗទៀត ទៅកាន់ទ្វីបអាមេរិក ទ្វីបអឺរ៉ុប ទ្វីបអាហ្វ្រិក ទ្វីបអាស៊ី និងទ្វីបអូសេអានី។

#### *8.6.2. ការត្រួតពិនិត្យតាមដានពេលវេលាក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ*

បានធ្វើការតាមដានត្រួតពិនិត្យពេលវេលានៃការចេញ C/O ជូនបណ្តាក្រុមហ៊ុនដែលបានស្នើសុំនាំចេញសំលៀកបំពាក់ និងស្បែកជើង ព្រមទាំងផលិតផលកសិកម្មផ្សេងៗទៀត ដើម្បីស្វែងរកចំណុចខ្លាំង ចំណុចខ្សោយ របស់មន្ត្រីជំនាញ ព្រមទាំងមន្ត្រីពាក់ព័ន្ធ ដើម្បីចេញ C/O បានទាន់ពេលវេលា និងមានសុក្រឹត្យភាព។

## 9. *ការចេញអាជ្ញាប័ណ្ណនាំចេញ-នាំចូលក្រោមបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់*

ទំនិញស្ថិតនៅក្រោមបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ របស់រាជរដ្ឋាភិបាល មានដូចជា ផលអនុផលព្រៃឈើ ផលិតផលឈើកៅស៊ូកែច្នៃ និងផលិតផលមួយចំនួនទៀតស្ថិតក្នុងរបបអាជ្ញាប័ណ្ណនាំចេញនាំចូល។

ក្នុងបរិបទនេះ ក្រសួងបានចេញអាជ្ញាប័ណ្ណនាំចេញទំនិញ ជូនក្រុមហ៊ុនតាមការកំណត់របស់រាជរដ្ឋាភិបាលដែលមានទឹកប្រាក់សរុបចំនួន ៣៦.១០៩.៩៨២ដុល្លារអាមេរិក បើប្រៀបធៀបនឹងឆ្នាំ២០១០ មានទឹកប្រាក់ចំនួន ២៤.៦៦៩.១៣៨ ដុល្លារអាមេរិក គឺមានការកើនឡើង ៨៦,៣៧%។ ទំនិញដែលនាំមុខគេមាន ឈើកែច្នៃ ឈើកៅស៊ូកែច្នៃ ឈើស្វាយចន្ទីកែច្នៃ ឈើដើមអាកាស្យាកែច្នៃ និងផលិតផលគ្រឿងសង្ហារឹមធ្វើពីឈើកៅស៊ូ។

ក្រសួងក៏បានចេញអាជ្ញាប័ណ្ណនាំចូលទំនិញ ជូនក្រុមហ៊ុនដែលមានទឹកប្រាក់សរុប ចំនួន ១១៨.០០០ ដុល្លារអាមេរិក បើប្រៀបធៀបនឹងឆ្នាំ២០១០ មានចំនួន ៣៣២.១២០ ដុល្លារអាមេរិក មានការថយចុះស្មើនឹង ៦៥,៦៧%។ ផលិតផលដែលបាននាំចូលមានដូចជា ឈើអារ Chanfuta និងឈើអារ Swartzia Madagaccariaenis។

## 10. *សកម្មភាពជំរុញពាណិជ្ជកម្ម*

### 10.1. ការរៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្មក្នុង និងក្រៅប្រទេស

នៅក្នុងឆ្នាំ២០១១កន្លងមក ក្រសួងបានខិតខំរៀបចំ និងចូលរួមពិព័រណ៍ក្នុង និងក្រៅប្រទេស ដែលក្នុងនោះ ការចូលរួមពិព័រណ៍នៅក្រៅប្រទេសបានចំនួន ៣៩លើក បានរៀបចំពិព័រណ៍ក្នុងប្រទេសចំនួន ០៧លើក ជាពិសេសបានរួមសហការជាមួយក្រុមហ៊ុនក្នុងស្រុក និងក្រៅប្រទេស ក្នុងការរៀបចំពិព័រណ៍ពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជា ដែលការរៀបចំពិព័រណ៍នេះមានចំនួន ៥៨លើក។

តាមរយៈនៃការចូលរួម និងរៀបចំពិព័រណ៍ក្នុង និងក្រៅប្រទេស ក្រសួងពាណិជ្ជកម្ម បានលើកមុខមាត់ប្រទេសជាតិដោយៈ

- ធ្វើឲ្យសាធារណជនបានស្គាល់អំពីទិដ្ឋភាពទូទៅនៃប្រទេសកម្ពុជា ជាពិសេស ពីសក្តានុពលផ្នែកវិនិយោគ និងពាណិជ្ជកម្ម។
- បង្ហាញពីវប្បធម៌ និងសិល្បៈខ្មែរ
- បង្កើតវេទិកាពាណិជ្ជកម្ម និងវិនិយោគ កម្រិតអន្តរជាតិ
- បើកទូលាយទីផ្សារក្នុងក្របខ័ណ្ឌសមាហរណកម្មតំបន់ និងពិភពលោក
- បង្កលក្ខណៈឲ្យប្រជាជន និងផលិតករ មានឱកាសរៀនសូត្រ និងដកបទពិសោធន៍អំពីផលិតផលថ្មីៗ និងរបៀបធ្វើសេវា ក៏ដូចជាធ្វើពាណិជ្ជកម្មជាមួយបរទេស។
- ជំរុញសកម្មភាពពាណិជ្ជកម្មក្នុងស្រុក រវាងខេត្ត និងខេត្ត រវាងខេត្ត និងក្រុង ក្នុងយុទ្ធសាស្រ្តស្វែងរកទីផ្សារតាមរបៀបនាំចេញនៅហ្នឹងកន្លែង។
- បានសម្របសម្រួលឲ្យមានការចុះកិច្ចសន្យាពាណិជ្ជកម្ម និងវិនិយោគ ចុះហត្ថលេខារវាងពាណិជ្ជករកម្ពុជា និងបរទេស មានទឹកប្រាក់សរុប ៨២៣.៥០០.០០០ដុល្លារអាមេរិក។

### 10.2. ការតាមដានទីផ្សារ និងរក្សាស្ថេរភាពថ្លៃ

ក្រសួងបានរៀបចំការងារតាមដានស្ថានភាពតម្លៃនៅទីផ្សារ បានជំរុញឲ្យអនុវត្តការបិទស្លាកថ្លៃលើទំនិញ និងសេវាកម្មគ្រប់ប្រភេទ និងបានអនុវត្តការងារគ្រប់គ្រងអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃ

ជាគ្រឿងអលង្ការ។ ដើម្បីរក្សាស្ថេរភាពថ្លៃ ក្រសួងបាន ៖

- តាមដានជាប្រចាំនូវថ្លៃលក់ដុំតាមតំបន់ទីផ្សារគោលដៅ និងថ្លៃលក់រាយនូវទំនិញយុទ្ធសាស្ត្រសំខាន់ៗចំនួន ៥៥មុខ មានដូចជា ស្រូវ-អង្ករ ពោត សណ្តែក និងអគ្រាប្តូរប្រាក់ជាដើម ដើម្បីលើកទិសដៅជាវិធានការចាំបាច់ទប់ទល់ ក្នុងករណីដែលទំនិញទាំងនេះ មានការប្រែប្រួលថ្លៃខ្លាំង ដែលអាចប៉ះពាល់ដល់ជីវភាពរបស់ប្រជាជន។

- តាមដានស្តុកប្រេងឥន្ធនៈ និងហ្គាស់ របស់ក្រុមហ៊ុនអាជីវកម្មប្រេងឥន្ធនៈនៅកម្ពុជា

- បញ្ចូលទិន្នន័យទីផ្សារទាន់ហេតុការណ៍ ក្នុងប្រព័ន្ធព័ត៌មានទីផ្សារអេឡិចត្រូនិច EMCS

## 10.3. ការងារអភិវឌ្ឍន៍ផលិតផល និងស្វែងរកទីផ្សារជូនពាណិជ្ជករ និងកសិករ

ក្រសួង បានបន្តជំរុញឲ្យបងប្អូនផលិតករ សិប្បករ ចូលរួមចងក្រងជាសមាគមផលិត ដើម្បីងាយស្រួលប្រមូលផ្តុំផលិតផល និងសេវាកម្ម និងស្វែងរកទីផ្សារសម្រាប់ផលិតផលដែលពួកគាត់ផលិតបានម្យ៉ាងទៀត ដើម្បីងាយស្រួលស្វែងរកជំនួយឧបត្ថម្ភពីដៃគូអភិវឌ្ឍនានា ដែលកំពុងមាននិន្នាការជួយទ្រទ្រង់វិស័យឯកជន។ ក្រសួងបានរៀបចំឲ្យមានដាក់តាំងបង្ហាញផលិតផល ដែលមានសក្តានុពលជូនភ្ញៀវទស្សនា និងការរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ដើម្បីណែនាំ និងតម្រង់ទិសផលិតករ សិប្បករ អ្នកនាំចេញឲ្យគិតគូរអំពីការធ្វើឲ្យប្រសើរឡើងនូវគុណភាព សោភ័ណភាពលើផលិតផល និងសេវាកម្ម ដើម្បីងាយស្រួលបញ្ជាបចូលទីផ្សារ។

ផលិតផលអង្ករ ៖ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលកំពុងយកចិត្តទុកដាក់ខ្លាំង និងមានផែនការនាំចេញអង្ករកម្ពុជាឆ្ពោះទៅកាន់គោលដៅទីផ្សារថ្មីៗឲ្យបាន ១លានតោន នៅឆ្នាំ២០១៥ ក្រសួងបានរៀបចំការងារមួយចំនួនដូចខាងក្រោម៖

១. បង្កើតសម្ព័ន្ធនាំចេញអង្ករកម្ពុជា ដោយមានការចូលរួមពីគ្រប់សមាសភាពដូចជា ៖ ក្រុមហ៊ុនម៉ាស៊ីនកិនស្រូវ អ្នកនាំចេញ ធនាគារ ក្រុមហ៊ុនដឹកជញ្ជូន ។ល។

២. ចូលរួមរៀបចំច្រកចេញចូលតែមួយ ជាមួយក្រុមការងារផ្នែកស្រូវអង្ករ នៃវេទិកាពរាជរដ្ឋាភិបាលផ្នែកឯកជន ដើម្បីជួយសម្រួលបែបបទនាំចេញអង្ករ។

៣.រៀបចំបេសកកម្មពាណិជ្ជកម្ម ជូនពាណិជ្ជករម៉ាស៊ីនកិនស្រូវកម្ពុជា ទៅចូលរួមពិព័រណ៌អន្តរជាតិស្រូវ-អង្ករនៅទីក្រុងឌុយបៃ ប្រទេសអារ៉ាប់អេមីរ៉េត។ បេសកកម្មពាណិជ្ជកម្មនេះ បានផ្តល់ឱកាសឲ្យអ្នកនាំចេញអង្ករកម្ពុជា បានជួបចរចាដោយផ្ទាល់ជាមួយឈ្មួញអង្ករធំៗ នៅអឺរ៉ុប អារ៉ាប់ និងមួយចំនួនមកពីអាហ្វ្រិក។ ជាលទ្ធផលជាក់ស្តែងនៅឆ្នាំ២០១១ កន្លងមកនេះ កម្ពុជាបានធ្វើការនាំចេញអង្ករបាន ១៧៣.១៨០ តោន គិតជាទឹកប្រាក់មានចំនួន ១០៧,៣០លានដុល្លារ ទៅកាន់ទីផ្សារអន្តរជាតិពិសេសទីផ្សារអឺរ៉ុប ដែលមានបរិមាណហូតដល់ ១៣០.៨០៥ តោន បើប្រៀបជាមួយឆ្នាំ២០១០ ដែលនាំចេញបានតែ ៥៩-៨១៥តោន គិតជាទឹកប្រាក់បាន ៣៦លានដុល្លារ ឃើញថា មានការកើនឡើង ១៩៦%។

## 10.4. ការងារអភិវឌ្ឍន៍ពាណិជ្ជកម្ម និងសកម្មភាពពង្រឹងដៃគូពាណិជ្ជកម្ម

### *10.4.1. ការងារអភិវឌ្ឍន៍ពាណិជ្ជកម្ម*

ដើម្បីចូលរួមអនុវត្តកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម ក្រសួងបាននឹងកំពុងបន្តអនុវត្តនូវគម្រោងចំនួន ៣ គឺ៖

- គម្រោងផ្តល់ព័ត៌មានពីផលិតផលសក្តានុពល១០មុខ ដល់បណ្តារាជធានី-ខេត្ត ទូទាំងប្រទេស ដើម្បីរៀបចំការនាំចេញ។

- គម្រោងកសាងសមត្ថភាពជំនាញស្តីពីនីតិវិធីនាំចេញ ដើម្បីផ្តល់ឱកាសឲ្យផលិតករ ពាណិជ្ជករ

អ្នកនាំចេញ-នាំចូល សមាគមអាជីវកម្ម បានយល់ដឹងពីការរៀបចំបែបបទនាំចេញ សំដៅចូលរួមកាត់បន្ថយការចំណាយមិនចាំបាច់ ជាពិសេសបានណែនាំដៃគូពាក់ព័ន្ធឲ្យធ្វើការនាំចេញដោយស្របច្បាប់។

- គម្រោងសិក្សាស្រាវជ្រាវខ្សែចង្វាក់ផលិតកម្ម Value Chain លើផលិតផលតាមផ្នែករួមមាន : កៅស៊ូ ម្រេច ព្រមទាំងបន្តទៅផលិតផលផ្សេងៗទៀត ដូចបានកំណត់ដោយ DTIS-2007 ដោយបានចុះផ្ទាល់ដល់មូលដ្ឋានផលិតកម្ម។

### *10.4.2. សកម្មភាពពង្រឹងដៃគូពាណិជ្ជកម្ម*

បានបន្តរួមសហការជាមួយដៃគូពាណិជ្ជកម្ម ក្នុងតំបន់អាស៊ីអាគ្នេយ៍ ដើម្បីជំរុញពាណិជ្ជកម្ម និងវិនិយោគពីបរទេសមកកម្ពុជា។ ដៃគូពាណិជ្ជកម្មទាំងនោះមាន៖

- មជ្ឈមណ្ឌលអាស៊ាន-ជប៉ុន ASEAN-Japan Centre
- មជ្ឈមណ្ឌលអាស៊ាន-កូរ៉េ ASEAN-Korea Centre
- មជ្ឈមណ្ឌលអាស៊ាន-ចិន ASEAN-China Centre
- វេទិកាជំរុញពាណិជ្ជកម្មអាស៊ីអាគ្នេយ៍ Asia Trade Promotion Forum-ATPF
- អង្គការ JETRO (Japan External Trade Organization)
- អង្គការ KOTRA ភ្នំពេញ

### *10.4.3. សកម្មភាពនៃការរៀបចំបោះឆ្នោតសភាពាណិជ្ជកម្ម*

ក្រោយពីបានចេញច្បាប់ និងអនុក្រឹត្យជាច្រើន ព្រមទាំងយន្តការនានា ក្នុងការរៀបចំបោះឆ្នោតសភាពាណិជ្ជកម្ម ក្រសួងបានរៀបចំសភាពាណិជ្ជកម្មរាជធានី-ខេត្ត ចំនួន ១២ គឺសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ពោធិ៍សាត់ បាត់ដំបង សៀមរាប ព្រះសីហនុ កំពត កំពង់ចាម កំពង់ស្ពឺ បន្ទាយមានជ័យ កណ្តាល កោះកុង និងខេត្តព្រៃវែង (ថ្មី) តាមរយៈការបោះឆ្នោត។ ព្រមជាមួយគ្នានេះ ក្រសួងបានរៀបចំការបោះឆ្នោតជ្រើសរើសប្រធានសភាពាណិជ្ជកម្មកម្ពុជាអាណត្តិទី២ ផងដែរ។ ដើម្បីជំរុញសភាពាណិជ្ជកម្មឲ្យកាន់តែប្រសើរថែមទៀត ក្រសួងពាណិជ្ជកម្មបានរៀបចំអនុក្រឹត្យ បញ្ចូលមណ្ឌលសភាពាណិជ្ជកម្មខេត្តមួយចំនួន ឲ្យទៅជាមណ្ឌលសភាពាណិជ្ជកម្មតែមួយមានចំនួន ៧មណ្ឌល គឺមណ្ឌលសភាពាណិជ្ជកម្មខេត្តកំពត (ខេត្តកំពត កែប និងតាកែវ) មណ្ឌលសភាពាណិជ្ជកម្មខេត្តបាត់ដំបង (ខេត្តបាត់ដំបង និងប៉ៃលិន) មណ្ឌលសភាពាណិជ្ជកម្មខេត្តសៀមរាប (ខេត្តសៀមរាប និងឧត្តរមានជ័យ) មណ្ឌលសភាពាណិជ្ជកម្មខេត្តកំពង់ធំ (ខេត្តកំពង់ធំ និងព្រះវិហារ) មណ្ឌលសភាពាណិជ្ជកម្មខេត្តក្រចេះ (ខេត្តក្រចេះ ស្ទឹងត្រែង និងរតនគិរី) មណ្ឌលសភាពាណិជ្ជកម្មខេត្តកំពង់ចាម (ខេត្តកំពង់ចាម និងមណ្ឌលគិរី) និងមណ្ឌលសភាពាណិជ្ជកម្មខេត្តកណ្តាល (ខេត្តកណ្តាល និងកំពង់ឆ្នាំង)។

## 11. *ការងារគ្រប់គ្រងស្បៀង*

ផ្នែកការងារគ្រប់គ្រងស្បៀងត្រៀមបម្រុងរដ្ឋ ក្រសួងពាណិជ្ជកម្ម មានអង្ករស្តុកត្រៀមបម្រុងរដ្ឋចំនួន ១១.៩០៦ តោន សម្រាប់បញ្ចេញធ្វើអន្តរាគមន៍ ពេលដែលប្រទេសជាតិមានបញ្ហាជាយថាហេតុណាមួយ។ ជាក់ស្តែងនៅពេលមានទឹកជំនន់កន្លងមកនេះ រាជរដ្ឋាភិបាល បានធ្វើអន្តរាគមន៍ចំណាយអង្ករអស់ ៨.២១៦ តោន និងនៅសល់ស្តុកអង្ករចុងគ្រាសរុបបរិមាណមានចំនួន ៣.៦៨៩ តោន។

នៅចុងខែ កញ្ញា ឆ្នាំ២០១១នេះ ស្ថានភាពទឹកជំនន់មានលក្ខណៈធ្ងន់ធ្ងរ បាននាំមកនូវការលិចលង់ផ្ទះសំបែង ស្រែចំការ របស់ប្រជាជនចំនួន ១៥ ខេត្ត។ តាមការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួងពាណិជ្ជកម្ម (ក្រុមហ៊ុនគ្រីនត្រេដ) បានដោះស្រាយជាបន្ទាន់នូវអង្ករត្រៀមបម្រុងរដ្ឋចំនួន ៧.៩០០ តោន

ដោយប្រគល់ជូនអាជ្ញាធរខេត្ត និងសមាគមជាតិកាកបាទក្រហមកម្ពុជា ហើយដឹកជញ្ជូនទៅតាមគោលដៅដែលកាកបាទក្រហមកម្ពុជាបានកំណត់ ដើម្បីសមាគមជាតិកាកបាទក្រហមកម្ពុជា មានលទ្ធភាពដោះស្រាយស្បៀងជូនប្រជាពលរដ្ឋ ដែលរងគ្រោះបានទាន់ពេល។

## 12. *ការពង្រឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា*

### 12.1. សកម្មភាពត្រួតពិនិត្យទំនិញ

សកម្មភាពត្រួតពិនិត្យទំនិញមានគោលដៅជាក់លាក់ ដើម្បីធានាថាទំនិញនាំចូល និងទំនិញលក់នៅលើទីផ្សារ អនុលោមទៅនឹងលក្ខខណ្ឌតម្រូវការ សម្រាប់ការពារសុខុមាលភាពសាធារណៈ និងសុវត្ថិភាព។ កិច្ចការការពារផលប្រយោជន៍របស់អ្នកប្រើក៏ត្រូវមានការធានាផងដែរ តាមរយៈសកម្មភាពបង្ក្រាបការក្លែងបន្លំពាណិជ្ជកម្ម។ សកម្មភាពទាំងនោះ ដំណើរការនៅតាមព្រំដែន (ការនាំចូល-នាំចេញ) និងនៅលើទីផ្សារ ក្នុងស្រុក ។

#### *12.1.1. សកម្មភាពឃ្លាំពិនិត្យទីផ្សារ*

- ចុះត្រួតពិនិត្យបណ្តាផ្សារនៅទូទាំងប្រទេស បានចំនួន ៩៦៦ផ្សារ ដោយបានដកហូតនិង កំទេចចោលផលិតផលក្លែងក្លាយ ឬ ខូចគុណភាពចំនួន ១៥មុខ ស្មើ ១៣.៥២៧ គីឡូក្រាម។

- រកឃើញផលិតផលចាហួយដែលផលិតនៅតៃវ៉ាន់ មានផ្ទុកនូវសារធាតុគីមី Di-(2-ethylhexyl) Phthalate (DEHP) ចំនួន ៧.១៣៨ គីឡូក្រាម ។

- សហការស្រាវជ្រាវ និងបង្ក្រាបការចរាចរណ៍ផលិតផល រំលោភសិទ្ធិនាំចូលផ្តាច់មុខបានចំនួន ០៧ ករណី ការផលិតនិងចរាចរណ៍ផលិតផលក្លែងក្លាយបានចំនួន ០៥ ករណី។

- ចុះត្រួតពិនិត្យបណ្តាស្ថានីយ៍ចែកចាយប្រេងឥន្ធនៈ នៅទូទាំងប្រទេសបានចំនួន ២២៥ស្ថានីយ៍ ក្នុងនោះមានស្ថានីយ៍ចំនួន ៤៩ ដាក់លក់ប្រេងដែលមានកម្រិតអុកតានទាបជាងបទដ្ឋានកំណត់ និង ស្ថានីយ៍ចំនួន ១៨៦ លក់ប្រេងជូនអតិថិជនមានកម្រិតលំអៀង (បាត់បង់) ក្នុងចន្លោះពី ០,២១ លីត្រ ទៅ ១,២១ លីត្រ ក្នុងបរិមាណចំណុះប្រេង ២០លីត្រ។

#### *12.1.2. សកម្មភាពត្រួតពិនិត្យទំនិញតាមច្រកព្រំដែន*

ការត្រួតពិនិត្យទំនិញនាំចូល-នាំចេញ នៅតាមគ្រប់ច្រកព្រំដែន មានគោលបំណងធានាឲ្យការធ្វើពាណិជ្ជកម្មផលិតផល ពិសេសម្ហូបអាហារ និងកសិ-ម្ហូបអាហារនាំចូល ឬនាំចេញ មានគុណភាព និងត្រឹមត្រូវតាមស្តង់ដារ របស់ផលិតផល ។ ជាលទ្ធផល ៖

- បានរកឃើញទំនិញខូចគុណភាព ឬ ទំនិញពុំត្រឹមត្រូវតាមបញ្ញត្តិបច្ចេកទេសនាំចូល ហើយត្រូវបាន ដកហូតមកបំផ្លាញចោលចំនួន ១៦មុខ ស្មើ ៨៣.២៥២ គីឡូក្រាម ។

- បានសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ត្រួតពិនិត្យឃើញការប៉ុនប៉ងនាំយកគ្រឿងញៀនចេញទៅក្រៅប្រទេសបាន៣ករណី ឃាត់ខ្លួនជនសង្ស័យដែលជាជនបរទេសចំនួន៤រូប និងរឹបអូសសារធាតុញៀន ទំងន់សរុប ៩.៣៧៩,៧០ ក្រាម បញ្ជូនទៅតុលាការចាត់ចែងតាមនីតិវិធី ។

- បានកសាងកំណត់ហេតុបទល្មើសបញ្ជូនទៅតុលាការ ដើម្បីធ្វើការចោទប្រកាន់ចំនួន ២១ ករណី ក្នុងនោះ សំណុំរឿងចំនួន ១០ ត្រូវបានតុលាការសម្រេចក្តី ឲ្យជនល្មើសចំនួន ៥ នាក់ស្ថិតក្រោមការត្រួតពិនិត្យផ្លូវតុលាការ ជនល្មើស ២នាក់ ត្រូវពិន័យឲ្យជាប់ពន្ធនាគាររយៈពេល ១ឆ្នាំ និងជនល្មើស ៩នាក់ ត្រូវបានសម្រេចពិន័យជាប្រាក់ចំនួន ៤៥,០០០,០០០៛ (សែសិបប្រាំលានរៀល) បង់ចូលថវិការដ្ឋ។

## 12.2. លទ្ធផលត្រួតពិនិត្យការផ្សាយពាណិជ្ជកម្ម

បានរកឃើញការផ្សព្វផ្សាយពាណិជ្ជកម្ម ដែលមានលក្ខណៈភូតកុហក ប្រាសចាកការពិត ធ្វើឲ្យអ្នកប្រើប្រាស់យល់ច្រឡំលើគុណភាព សុវត្ថិភាពផលិតផលទំនិញនិងសេវា ហើយបានស្នើសុំឲ្យ ផ្អាកការផ្សព្វផ្សាយជាផ្លូវការបានចំនួន ៥ ករណី និងផ្អាកដោយលក្ខណៈស្ម័គ្រចិត្តចំនួន ៣ ករណី ។

## 12.3. សកម្មភាពវិភាគគុណភាពទំនិញ

### *12.3.1. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងការបំពាក់ឧបករណ៍មន្ទីរពិសោធន៍*

ទន្ទឹមនឹងការរៀបចំ និងកែសម្រួល ទីតាំងសម្រាប់ដាក់ឧបករណ៍វិភាគឲ្យបានសមស្រប និងត្រឹមត្រូវតាមការតម្រូវផ្នែកបច្ចេកទេស សម្រាប់មន្ទីរពិសោធន៍ ក្រសួងពាណិជ្ជកម្ម ក៏បានបំពាក់ឧបករណ៍វិភាគទំនើប ដើម្បីមានលទ្ធភាពវិភាគរកសារធាតុមេឡាមីន ក្នុងផលិតផលទឹកដោះគោផងដែរ ។

### *12.3.2. លទ្ធផលវិភាគរបស់មន្ទីរពិសោធន៍*

មន្ទីរពិសោធន៍ក្រសួងពាណិជ្ជកម្ម បានធ្វើការវិភាគ គុណភាពទំនិញបានចំនួន ២.៧៥៨ គំរូ ក្នុងនោះការវិភាគផ្នែករូប-គីមីសាស្ត្រមានចំនួន ១.៣៣៨ គំរូ ផ្នែកមីក្រូជីវសាស្ត្រមានចំនួន ២៦៩ គំរូ និងផ្នែកប្រេងឥន្ធនៈមានចំនួន ១.១៥១គំរូ ដោយរកឃើញផលិតផលមិនសមស្របតាមស្តង់ដារតម្រូវចំនួន ១៨៣គំរូ។

## 12.4. សកម្មភាពផ្សព្វផ្សាយ និងអប់រំការយល់ដឹងសាធារណៈអំពីបញ្ហាគុណភាព សុវត្ថិភាពផលិតផល និងសិទ្ធរបស់អ្នកប្រើ

ដើម្បីជំរុញឲ្យមានការប្រើប្រាស់ម្ហូបអាហារ ប្រកបដោយសុវត្ថិភាព និងមានអនាម័យត្រឹមត្រូវ ក្រសួងពាណិជ្ជកម្មបានរៀបចំកម្មវិធីចុះអប់រំ និងផ្សព្វផ្សាយ អំពីរបៀបជ្រើសរើសផលិតផលម្ហូបអាហារដែលមានសុវត្ថិភាព ផលប្រយោជន៍នៃការបរិភោគអំបិលមានជាតិអ៊ីយ៉ូដ គោលការណ៍សំខាន់ៗ នៃកិច្ចការការពារអ្នកប្រើប្រាស់ និងផលប៉ះពាល់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន ដោយមានកិច្ចសហការពីមន្ទីរអប់រំខេត្ត-រាជធានី បានចំនួន ១៦ លើក (រាជធានីភ្នំពេញ ១៣ លើកខេត្តកំពង់ចាម ០១ លើកខេត្តកំពង់ឆ្នាំង ០១លើក និងខេត្តព្រះសីហនុ ០១លើក) ដែលមានសិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ អាជីវករ និងប្រជាពលរដ្ឋ ចូលរួមសរុបចំនួន ៨,១៨៦ នាក់។

## 12.5. ការកសាងបញ្ញត្តិបច្ចេកទេសសម្រាប់អនុវត្ត និងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេស និងស្ថាប័នពាក់ព័ន្ធ

### *12.5.1. ការរៀបចំពង្រាងបទបញ្ញត្តិបច្ចេកទេស*

ផ្តួចផ្តើមគំនិតរៀបចំពង្រាង កែសម្រួលឧបសម្ពន្ធទី១ អំពីកម្រិតសីតុណ្ហភាពអតិបរមាសម្រាប់ផលិតផលម្ហូបអាហារបង្កក និងដាក់ឲ្យត្រជាក់ និងឧបសម្ពន្ធទី២ អំពីចារីកលក្ខណៈវិនិច្ឆ័យមីក្រូជីវសាស្ត្រចំពោះផលិតផលម្ហូបអាហារ នៃអនុក្រឹត្យលេខ៨៧ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០០៣ ស្តីពីអនាម័យនៃម្ហូបអាហារសម្រាប់មនុស្ស ដើម្បីឲ្យខ្លឹមសារនៃឧបសម្ព័ន្ធទាំងពីរនេះ មានលក្ខណៈសមស្របទៅនឹងបច្ចុប្បន្នភាពនៃបទបញ្ញត្តិ គោលការណ៍ណែនាំការអនុវត្តនៃបណ្តាប្រទេសជឿនលឿន និងប្រទេសក្នុងតំបន់។

### *12.5.2. ការចូលរួមផ្តល់មតិយោបល់បច្ចេកទេសពាក់ព័ន្ធនឹងសុវត្ថិភាព និងគុណភាពផលិតផល*

- បានផ្តល់មតិយោបល់ពាក់ព័ន្ធនឹងចារីកលក្ខណៈគុណភាព និងសុវត្ថិភាពផលិតផលមី ដែល

SME បានលើកជាបញ្ហាសហគ្រាសផលិតមីទទួលរងគ្រោះ ដោយការប្រកួតប្រជែងមិនស្មោះត្រង់ជាមួយ ទំនិញផលិតផលមីនាំចូល ដោយសារគុណភាពទំនិញនាំចូលមិនសមស្រប និងការរត់គេចពន្ធ ដែលធ្វើឲ្យផលិតផលក្នុងស្រុក ពិបាកធ្វើការប្រកួតប្រជែង។

- បានផ្តល់មតិយោបល់ ចំពោះគម្រោង FSP មេគង្គនៃគណៈកម្មាធិការកណ្តាលប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់ខ្លាំងដល់សុខភាព។

- បានផ្តល់មតិយោបល់ចំពោះឧបករណ៍មន្ទីរពិសោធន៍កំណត់រោគវិនិច្ឆ័យនៃជម្ងឺ និងសមាសភាពចង្រៃចំពោះដំណាំរុក្ខជាតិ ដែលជាជំនួយរបស់ប្រទេសអូស្ត្រាលី ។

- បានផ្តល់មតិយោបល់ចំពោះការលើកឡើងផ្នែកឯកជន នូវបញ្ហាពាក់ព័ន្ធនឹងការអនុវត្តន៍ការកិច្ចរបស់អគ្គនាយកដ្ឋានកាំកុងត្រូល នៅក្នុងបញ្ហាទី៣ ជំរុញផលិតកម្មក្នុងស្រុក និងចំណុចទី៤ ស្តីពីស្តង់ដារនៅក្នុងបញ្ហា និងអនុសាសន៍ដែល SME បានស្នើឡើង។

*12.5.3. ការស្រាវជ្រាវ និង ជ្រើសរើសនូវសេចក្តីជូនដំណឹងអំពីអនាម័យ និង ភូតគាមអនាម័យ*

ស្រាវជ្រាវ និងជ្រើសរើសសេចក្តីជូនដំណឹងអំពីវិធានអនាម័យ និងភូតគាមអនាម័យដែល រៀបចំឡើងដោយប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ដែលមាន ឬ អាចមានសក្តានុពលពាណិជ្ជកម្មជាមួយកម្ពុជានាពេលអនាគត។ សេចក្តីជូនដំណឹងចំនួន ៥២៧ ច្បាប់ ដែលពិនិត្យឃើញថាអាចមានផលប៉ះពាល់ជាវិជ្ជមាន ឬអវិជ្ជមាន ដល់សេដ្ឋកិច្ចប្រទេសកម្ពុជា ត្រូវបានផ្ញើជូនបណ្តាក្រសួង ឬស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យនិងផ្តល់មតិ។

## 13. *ការគ្រប់គ្រងជំនួយបរទេស (Foreign Aid Management)*

### 13.1. កម្មវិធីអតិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម Trade SWAp (Trade Sector Wide Approach)

- នៅក្នុង ឆ្នាំ២០១១ នេះ បានរៀបចំកិច្ចប្រជុំរបស់អនុគណៈកម្មការអនុវត្តន៍ ស្តីពីការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងពាណិជ្ជកម្ម SSC-TD-TRI (Sub-Steering Committee on Trade Development and Trade Related Investment) ចំនួន ៣ លើក និងកិច្ចប្រជុំគណៈកម្មការអនុវត្តគម្រោង IC (Implementation Committee) ចំនួ ១០ លើក។

- កិច្ចប្រជុំខាងលើបានអនុម័តជាឯកច្ឆ័ន្ទនូវផែនទីបង្ហាញផ្លូវរបស់សសរស្តម្ភទាំងបី: (១) សសរស្តម្ភទី១: ការកែទម្រង់ច្បាប់ និងបញ្ហាអន្តរវិស័យ, (២) សសរស្តម្ភទី២: ការអភិវឌ្ឍន៍សេវាកម្ម និងផលិតផលសម្រាប់នាំចេញ, (៣) សសរស្តម្ភទី៣: ការអភិវឌ្ឍន៍ធនធានមនុស្ស ។

*13.1.1. កម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម TDSP (Trade Development Support Program)*

- រដ្ឋាភិបាលកម្ពុជាបានចុះកិច្ចព្រមព្រៀងជំនួយហិរញ្ញប្បទានជាមួយធនាគារពិភពលោកកាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០០៩ ក្នុងទឹកប្រាក់ចំនួន ១២,៣៥លានដុល្លារ សម្រាប់រយៈពេលបីឆ្នាំ។ គិតមកដល់ដំណាច់ឆ្នាំ២០១១ យើងបានធ្វើការចំណាយចំនួន ២,៤លានដុល្លារ គិតជាភាគរយមានចំនួន ១៩,៥% នៃទឹកប្រាក់ហិរញ្ញប្បទានសរុប។ គម្រោងនេះ នឹងត្រូវបានបន្តរយៈពេលពីរឆ្នាំបន្ថែមទៀត រហូតដល់ឆ្នាំ២០១៤ ។

- បេសកកម្មត្រួតពិនិត្យរបស់ធនាគារពិភពលោក បានវាយតម្លៃការអនុវត្តន៍គម្រោង TDSP បានឡើងដល់កម្រិតខ្ពស់បំផុត (Satisfactory Level) ពីកម្រិត Moderately Unsatisfactory នៅក្នុងឆ្នាំ២០១០ ។

- រហូតដល់ឆ្នាំ ២០១១ TDSP បានអនុវត្តគម្រោងចំនួន ២១ ដែលមានទឹកប្រាក់សរុបចំនួន ៦,៦លានដុល្លារ ក្នុងនោះមានគម្រោងចំនួន ៥ ត្រូវបានអនុម័តនៅក្នុងឆ្នាំ២០១១ ដែលមានទឹកប្រាក់ចំនួន

៨,៣លានដុល្លារ។ ទោះបីជាមានការយឺតយ៉ាវក្នុងការចាប់ផ្តើមអនុវត្តគម្រោងពីដំបូង ប៉ុន្តែជារួមការអនុវត្តគម្រោងកំពុងមានដំណើរការប្រព្រឹត្តទៅយ៉ាងសកម្ម។

*13.1.2. គម្រោងពង្រឹងសមាហរណកម្មពាណិជ្ជកម្ម EIF (Enhanced Entegrated Framework)*

រដ្ឋាភិបាលកម្ពុជាបានចុះកិច្ចព្រមព្រៀងជំនួយហិរញ្ញប្បទាន ជាមួយអង្គការសហប្រជាជាតិទទួលបន្ទុកសេវាកម្មគម្រោង (UNOPS) កាលពីថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១០ ដែលមានទឹកប្រាក់ចំនួន ១,៥លានដុល្លារ សម្រាប់រយៈពេល ៥ ឆ្នាំ។ គិតក្នុងឆ្នាំ២០១១ យើងបានធ្វើការចំណាយចំនួន ១៩២.៩៩១ ដុល្លារ គិតជាភាគរយមានចំនួន ៨៣,៣% នៃថវិកាប្រចាំឆ្នាំ។ បើគិតពីពេលគម្រោង ចាប់ផ្តើមមកដល់ចុងឆ្នាំ២០១១ យើងបានធ្វើការចំណាយចំនួន ០,២លានដុល្លារ ឬ ១៣% នៃទឹកប្រាក់ហិរញ្ញប្បទានសរុប ។

- EIF Tier 1: ផ្តោតទៅលើការយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស និងពង្រឹងស្ថាប័នអនុវត្តគម្រោង NIU (National Implementation Unit) ។ យើងបានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ៦ លើក និងផ្សព្វផ្សាយបទពិសោធន៍នៃការអនុវត្តតាមវិស័យចំនួន៥ រួមមានៈ អង្ករ សូត្រ កិច្ចសម្រួលពាណិជ្ជកម្ម សង្វាក់ផលិតផល (Value Chain) និងការ កែទម្រង់ច្បាប់ នៅកិច្ចប្រជុំសាកលលើកទី៣ ស្តីពីជំនួយពាណិជ្ជកម្ម នៅទីក្រុង Geneva ។

- EIF Tier 2: ផ្តោតការយកចិត្តទុកដាក់ទៅលើ ការអភិវឌ្ឍន៍ទៅតាមវិស័យ (Sectoral Approach) ដែលវិស័យទាំងនេះ មានចែងនៅក្នុងយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ២០០៨ CTIS (Cambodia Trade Integration Strategy 2008) ជាពិសេសគឺនៅក្នុងសសរស្តម្ភទី ២ របស់ Trade SWAp។ គម្រោងជំហានទី១ ផ្តោតលើការជំរុញការនាំចេញអង្ករ សូត្រ និងពង្រឹងផ្នែកត្រួតពិនិត្យ និងវាយតម្លៃ M&E (Monitoring and Evaluation) របស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងពាណិជ្ជកម្ម ។

## 13.2. គម្រោងកិច្ចសម្រួលពាណិជ្ជកម្ម និងភាពប្រកួតប្រជែង

គម្រោងនេះជាជំនួយឥតសំណងរបស់ធនាគារពិភពលោក ដែលមានទឹកប្រាក់សរុបចំនួន ១០ (ដប់) លានដុល្លារអាមេរិក។ គោលបំណងនៃគម្រោងនេះគឺជួយលើកកម្ពស់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា កាត់បន្ថយចំណាយប្រតិបត្តិការពាណិជ្ជកម្ម និងវិនិយោគ លើកកម្ពស់តម្លាភាពនៃដំណើរការវិនិយោគ និងជួយសម្រួលដល់ក្រុមហ៊ុនក្នុងស្រុកក្នុងការស្វែងរកទីផ្សារក្រៅប្រទេស។

គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១១ គម្រោងបានចំណាយថវិកាសរុបចំនួន ៧.៥៤៧.៥៦៧ ដុល្លារ ស្មើនឹង ៧៥.៥% នៃទឹកប្រាក់ ១០លានដុល្លារ។

គម្រោងនេះរួមមានផ្នែកសំខាន់ៗចំនួនបួនគឺ៖

*13.2.1. ផ្នែកកិច្ចសម្រួលពាណិជ្ជកម្ម និងច្រកចេញចូលតែមួយ*

ផ្នែកនេះអនុវត្តរួមគ្នាដោយក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ដោយបានប្រើថវិកាអស់ចំនួន ៣.៨៤៧.៨៣៧ ដុល្លារ ទៅលើសមិទ្ធិផលសំខាន់ៗដូចខាងក្រោម៖

- បានបង្កើតនិងដាក់ឲ្យដំណើរការនូវប្រព័ន្ធស្វ័យប្រវត្តិកម្មគយ (ASYCUDA) ដើម្បីកែលម្អនីតិវិធីនាំចេញ នាំចូលទំនិញនៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករ និងតាមមាត់ច្រកសំខាន់ៗចំនួន ១៥ ដូចជា កំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ព្រលានយន្តហោះអន្តរជាតិភ្នំពេញ ដៃស្ងួត តិចស្រ៊ុន តេងឡាយ ម៉េងស្រ៊ាង (SME-KPM) សួរង្វន កំពង់ផែភ្នំពេញ បាវិត ប៉ោយប៉ែត ត្រពាំងផ្លុង ត្រពាំងស្រែ ភ្នំដិន ជ្រៃធំ ស្រែអំបិល ចាំយាម។

- បានផ្គត់ផ្គង់ នូវម៉ាស៊ីនភ្លើងធុនមធ្យមចំនួន ២៥គ្រឿង ដល់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ

ដើម្បីធានានូវនិរន្តរភាពនៃប្រព័ន្ធ ASYCUDA ទាំង១៦ កន្លែងខាងលើ និងមាត់ច្រកថ្មី ចំនួន ៦កន្លែងទៀត ដែលនឹងដាក់ឲ្យដំណើរការនៅក្នុងឆ្នាំ ២០១២នេះ។

- បានផ្គត់ផ្គង់ម៉ាស៊ីនភ្លើងធុន ១០០០KVA មួយគ្រឿងដល់ក្រសួងពាណិជ្ជកម្ម សម្រាប់ធានានូវនិរន្តរភាពនៅមជ្ឈមណ្ឌលទិន្នន័យក្រសួងពាណិជ្ជកម្ម (MoC Data Center)។

### *13.2.2. ផ្នែកមូលនិធិបើកច្រកទីផ្សារនាំចេញ*

ផ្នែកនេះអនុវត្តដោយក្រសួងពាណិជ្ជកម្ម។ មូលនិធិនេះសម្រាប់ជួយឧស្សាហករ ផលិតកររបស់យើង រកទីផ្សារសម្រាប់នាំចេញផលិតផលរបស់គេទៅបរទេស តាមរយៈការជួយផ្តល់មូលនិធិ មិនមានសំណងចំនួន ៥០% (Matching Grant)។ គិតមកត្រឹមដំណាច់ឆ្នាំ ២០១១ ផ្នែកនេះបាន ប្រើប្រាស់ថវិកាសរុបចំនួន ២.១១៨.៥៥២ ដុល្លារ។ លទ្ធផលដែលអនុវត្តបានគឺ÷

- បានផ្តល់មូលនិធិទៅអង្គការពលកម្មអន្តរជាតិ ចំនួន ១.៣០០.០០០ដុល្លារ សម្រាប់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO Better Factory Cambodia Project) ដើម្បីពង្រឹងការនាំចេញ ដោយផ្សារភ្ជាប់នឹងការគោរពលក្ខខណ្ឌការងារ និងការគោរពសិទ្ធិ កម្មករ នៅតាមបណ្តារោងចក្រកាត់ដេរ

- បានផ្តល់មូលនិធិដល់ឧស្សាហករ និងផលិតករ ចំនួន ២០ នៅជំហានទី១ មានទឹកប្រាក់ ១៥៥.៥៨០ ដុល្លារ

- បានចុះកិច្ចសន្យាផ្តល់មូលនិធិ ៥០% ជំហានទី២ ជាមួយក្រុមហ៊ុនក្នុងស្រុកចំនួន ២៧ មានទឹកប្រាក់សរុប ៣២០.៦៨៧ ដុល្លារ។

### *13.2.3. ផ្នែកការចូលរួមរបស់ឯកជនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការជំរុញវិនិយោគ*

ផ្នែកនេះអនុវត្តដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីជួយទ្រទ្រង់ការអនុវត្តន៍ច្បាប់វិនិយោគ និងច្បាប់សម្បទាន ឲ្យមានតម្លាភាព និងភាពប្រកួតប្រជែង។

គិតមកដល់ដំណាច់ឆ្នាំ ២០១១ ផ្នែកនេះបានប្រើប្រាស់ថវិកាសរុបចំនួន ៦៦៧.១០២ ដុល្លារ លើការងារដូចខាងក្រោម÷

- បានធ្វើការបណ្តុះបណ្តាលដល់មន្ត្រី នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងមន្ត្រីនៃស្ថាប័ន ពាក់ព័ន្ធ អំពីការជំរុញវិនិយោគ និងការគាំទ្រអនុវត្តយុទ្ធសាស្ត្រ ចំនួនបីលើក។

- បានធ្វើការបណ្តុះបណ្តាលដល់មន្ត្រី នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងមន្ត្រីនៃស្ថាប័ន ពាក់ព័ន្ធ តាមបណ្តាខេត្ត រាជធានី ចំនួន ១០ លើក អំពីការចូលរួមរបស់ផ្នែកឯកជនក្នុង ហេដ្ឋារចនាសម្ព័ន្ធ។

- បានផ្គត់ផ្គង់ និងដាក់ឲ្យដំណើរការនូវប្រព័ន្ធតាមដានវិនិយោគិន (Investors Tracking System) នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

- បានជួលក្រុមហ៊ុន Engineering Market Consulting Co.,Ltd. ដើម្បីធ្វើការស្ទាបស្ទង់ការយល់ឃើញរបស់វិនិយោគិនបរទេសនៅកម្ពុជា (Foreign Investors Perception Survey Within Cambodia)។

### *13.2.4. ផ្នែកតម្លាភាពនៃច្បាប់*

ផ្នែកនេះអនុវត្តដោយក្រសួងយុត្តិធម៌ ដែលបានប្រើប្រាស់ថវិកាសរុបចំនួន ៣៧៨.០៩៥ ដុល្លារ លើសមិទ្ធិផលដូចខាងក្រោម÷

- បានបង្កើត និងដាក់ឲ្យដំណើរការនូវគេហទំព័រចំនួនពីរជាភាសាខ្មែរ នៅក្រសួងយុត្តិធម៌ និងតុលាការកំពូល ដើម្បីផ្សព្វផ្សាយដល់សាធារណជន ឲ្យបានយល់ដឹងអំពីកម្រងសាលដីកាបញ្ចប់រឿងក្តីនៅតុលាការកំពូល ព្រមទាំងផ្សព្វផ្សាយ នូវច្បាប់ទាំងឡាយរបស់កម្ពុជា និងបទបញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀត។

- បានបណ្តុះបណ្តាលថៅក្រម ព្រះរាជអាជ្ញារ និងមន្ត្រីសំខាន់ៗមួយចំនួនមកពីគ្រប់ខេត្ត រាជធានីទូទាំងប្រទេសចំនួន ២៥០នាក់ អំពីការប្រើប្រាស់ និងគ្រប់គ្រងគេហទំព័រចំនួន ១០លើក ដែលមួយលើកៗមានរយៈពេលបីថ្ងៃ។

14. *ការងារបញ្ជ្រាបយេនឌ័ររបស់ក្រសួងពាណិជ្ជកម្ម*

- បើកវគ្គបណ្តុះបណ្តាលដល់ក្រុមការងារយេនឌ័រថ្នាក់ក្រសួង អំពីគោលគំនិតយេនឌ័រ មានអ្នកចូលរួមចំនួន ១៣០នាក់។

- បើកវគ្គបណ្តុះបណ្តាលជំនាញសម្របសម្រួលដល់ក្រុមការងារយេនឌ័រ និងផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ដល់ក្រុមការងារយេឌ័រទាំង ២៤ រាជធានី-ខេត្ត។

- បើកវគ្គផ្សព្វផ្សាយ ស្តីពីអនុសញ្ញាលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងនារីភេទបាន ២វគ្គ មានអ្នកចូមរួមចំនួន ១៨០នាក់។

- រៀបចំសិក្ខាសាលាពង្រឹងសមត្ថភាព ស្តីពីការគ្រប់គ្រងដើម្បីលទ្ធផលដោយផ្តោតទៅលើការងារយេនឌ័រក្នុងពាណិជ្ជកម្ម។

- បានរៀបចំក្រុមការងារយេនឌ័រ តាមមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ទាំង ២៤ ដើម្បីសម្របសម្រួល និងសហការជាមួយក្រុមការងារយេនឌ័រក្រសួង អនុវត្តឲ្យសម្រេចជោគជ័យផែនការបញ្ជ្រាបយេនឌ័រ ក្នុងវិស័យពាណិជ្ជកម្ម

- បានផ្សព្វផ្សាយ បណ្តុះបណ្តាលជូនដល់សមាជិកក្រុមការងារយេនឌ័រក្រសួងពាណិជ្ជកម្ម មន្ត្រីមន្ទីរពាណិជ្ជកម្ម និងក្រុមនារីសិប្បកម្មតម្បាញ បានចំនួន ០១លើក ដែលមានអ្នកចូលរួមសរុប ៨០នាក់ នៅខេត្តសៀមរាប។

- បានសហការជាមួយក្រសួងកិច្ចការនារី និងអង្គការ JICA រៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្រសួងពាណិជ្ជកម្មជំហានទី២ សម្រាប់ឆ្នាំ២០១២-២០១៦។

## III. សកម្មភាពការងាររដ្ឋបាល ការគ្រប់គ្រងធនធានមនុស្ស និងយន្តការត្រួតពិនិត្យផ្ទៃក្នុង

1. *ការងាររដ្ឋបាល*

អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រសួងពាណិជ្ជកម្មបានខិតខំប្រឹងប្រែងធ្វើការសម្របសម្រួលរាល់ការងារក្នុង និងក្រៅក្រសួង ដើម្បីការប្រព្រឹត្តទៅនៃសកម្មភាពការងារទូទៅ។ ជាក់ស្តែងក្នុងឆ្នាំ២០១១ នេះយើងអនុវត្តបានៈ

- ចូលរួមយ៉ាងសកម្មក្នុងការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដោយអនុវត្តបានត្រឹមត្រូវ នូវនីតិវិធីចំណូល-ចំណាយ (សក្ខីប័ត្រគ្រប់គ្រាន់)

- អនុវត្តផែនការថវិកា សម្រាប់ដោះស្រាយសេចក្តីត្រូវការខាងផ្នែកសម្ភារៈ ឬ ថវិកាជូនដល់គ្រប់អង្គភាព គ្រប់ផ្នែករបស់ក្រសួង ដើម្បីមានលទ្ធភាព បំពេញនូវតួនាទី និងធ្វើប្រតិបត្តិការប្រចាំថ្ងៃ។

- គ្រប់គ្រងឯកសារស្រាវជ្រាវនៅក្នុងបណ្ណាល័យ តាមប្រព័ន្ធកុំព្យូទ័រ។

- រៀបចំទទួលគណៈប្រតិភូជាតិ និង អន្តរជាតិ ដោយធានាបានសុវត្ថិភាព បានចំនួន ៣០លើក។

- រៀបចំកិច្ចប្រជុំ និង សិក្ខាសាលាបានចំនួន ៣៦០លើក។

- យកចិត្តទុកដាក់ទទួលលិខិតចូលសរុបចំនួន ៩.០៩៦ច្បាប់ និងលិខិតចេញចំនួន ១៨.៥៨៥ច្បាប់

- រៀបចំចងក្រងរាល់របាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ដើម្បីរំលេចឲ្យឃើញពីសកម្មភាពដែលបានអនុវត្តតាមដំណាក់កាលនីមួយៗ និងចងក្រងជារបាយការណ៍ នូវខ្លឹមសារនៃ

កិច្ចប្រជុំប្រចាំសប្តាហ៍។

2. *ការងារហិរញ្ញវត្ថុ*

ក.ស្ថានភាពចំណូល

ផែនការចំណូលបង់ចូលថវិការដ្ឋឆ្នាំ២០១១ មានចំនួន ៖ ១២០.៧៩១.៨០០.០០០ រៀល

សរុបចំណូលជាក់ស្តែងមានចំនួន ៖ ១៦០.៩៩៨.៩៩០.២៩៨ រៀល

ស្មើនឹង ១៣៣.២៨% នៃផែនការចំណូលប្រចាំឆ្នាំ។

ខ.ស្ថានភាពឥណទានថវិកា

ឥណទានឆ្នាំ២០១១ មានចំនួន ៖ ៣៧.៩៩៩.៦០០.០០០ រៀល

សំណើចំណាយក្នុងឆ្នាំមានចំនួន ៖ ៨០.៩៩៣.១៦៧.៨៩៩ រៀល

អាណត្តិបោះផ្សាយក្នុងឆ្នាំមានចំនួន ៖ ៣៦.០៨៨.៧១៣.៧៦៣ រៀល

ថវិកាបានផ្តល់តាមអាណត្តិមានចំនួន ៖ ៣៥.១១១.២៣៨.៩១៣ រៀល

ស្មើនឹង ៩២,៨០% នៃឥណទានថវិកាដែលបានផ្តល់។

ក្នុងការអនុវត្តគម្រោងឥណទានថវិកា ក្រសួងតែងបានសហការជាមួយប្រតិភូអធិការកិច្ចនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យផ្ទៀតផ្ទាត់ឡើងវិញរាល់ឯកសារ សក្ខីប័ត្រចំណូល-ចំណាយ ព្រមទាំងបែបបទអនុវត្តនីតិវិធីចំណាយនៅគ្រប់អង្គភាព (រាប់ទាំងនៅតាមមន្ទីរពាណិជ្ជកម្ម) ដើម្បីជាបណ្តើរៗកែសម្រួល និងប្រតិបត្តិទៅតាមសំណូមពរនៃការងារអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។

3. *ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស*

3.1. ការងារគ្រប់គ្រងមន្ត្រីរាជការ

- ដោយផ្អែកលើគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល ក្រសួងពាណិជ្ជកម្ម បានសហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដំណើរការយកវត្តមានក្នុងជំហានសាកល្បងតាមរយៈការយកស្នាមក្រយៅដៃតាមប្រព័ន្ធអេឡិចត្រូនិក។ ក្នុងដំណាក់កាលដំបូង ការគ្រប់គ្រងមានភាពហ្មត់ចត់ល្អ។ មន្ត្រីតាមនាយកដ្ឋាននានា បានភ្ជាប់លើកស្តែនក្រយៅដៃវត្តមានជាប្រចាំ ប៉ុន្តែដោយសារនេះជាកិច្ចការបច្ចេកទេសថ្មី និងលើកដំបូង ការគ្រប់គ្រងតាមម៉ាស៊ីនស្កេនក្រយៅម្រាមដៃតែមួយកន្លែងបែបនេះ មានឧបសគ្គជាអន្លើ ដោយសារម៉ាស៊ីនស្តែនបានខូចជាញឹកញាប់ ហើយទីបំផុតមិនអាចដំណើរបានទាំងស្រុង។ បច្ចុប្បន្ន អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល បានទទួលយកសំណូមពររបស់ក្រសួង ក្នុងការស្នើសុំផ្លាស់ប្តូរ និងបង្កើនចំនួនទីតាំងម៉ាស៊ីនស្កេនក្រយៅម្រាមដៃរួចហើយ ប៉ុន្តែមិនទាន់មានលទ្ធភាពដោះស្រាយបានទាន់ពេលវេលានៅឡើយ ក្នុងនោះម៉ាស៊ីនស្តែនអាចមានចំនួន ៥គ្រឿង: ទីស្តីការក្រសួង ២គ្រឿង នៅអគ្គនាយកដ្ឋានកាំកុងត្រូល ២គ្រឿង និងនៅនាយកដ្ឋានជំរុញពាណិជ្ជកម្ម ចំនួន១គ្រឿង។

- ធ្វើការផ្សព្វផ្សាយតាមរយៈសារអេឡិចត្រូនិក ទៅតាមបណ្តាអង្គភាពក្រោមឱវាទ ស្តីពីការធ្វើនិយ័តកម្មជំរឿន និងរៀបចំឡើងវិញ តារាងបច្ចុប្បន្នភាព ការគ្រប់គ្រងមន្ត្រីតាមអង្គភាពប្រចាំឆ្នាំ២០១១។ ដោយឡែកចំពោះមន្ត្រីរាជការដែលអវត្តមានពេលធ្វើជំរឿន នៅតាមមន្ទីរពាណិជ្ជកម្ម ក្រុមការងារនឹងបន្តធ្វើនៅលើកក្រោយទៀតក្នុងឆ្នាំ២០១២នេះ។

- បានបន្តពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យ ក្នុងការគ្រប់គ្រងការប្រឡងប្តូរក្របខ័ណ្ឌ ដើម្បីផ្តល់ឱកាសដល់មន្ត្រីរាជការ ដែលមានលក្ខណៈសម្បត្តិសមស្រប មានបទពិសោធន៍ការងារច្រើនឆ្នាំ ហើយខិតខំបំពេញការសិក្សាលើកកម្ពស់សមត្ថភាពរបស់ខ្លួនចុះឈ្មោះប្រឡងសុំប្តូរក្របខ័ណ្ឌបាន។ ប៉ុន្តែ

សេចក្តីព្រាងនេះ ទោះបីប្រើរយៈពេលពិភាក្សាជាងមួយឆ្នាំពិតមែន តែនៅមិនទាន់ទទួលបានការអនុម័តនៅឡើយ។ ក្រសួងកំពុងរៀបចំបែបបទ ស្នើសុំគោលការណ៍នៃការប្រឡងប្តូរក្របខ័ណ្ឌជូនមន្ត្រីរាជការសម្រាប់ក្រសួងនីមួយៗ ដោយឡែកវិញក្នុងពេលរង់ចាំការដាក់ចេញព្រះរាជក្រឹត្យ។

- ចូលរួមជាមួយអន្តរក្រសួង និងអគ្គលេខាក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ក្នុងការរៀបចំឯកសារគោលនយោបាយសំខាន់ៗមួយចំនួនដែលទាក់ទងទៅនឹង ៖

+ឯកសារស្តីពីស្តង់ដារសេវាសាធារណៈ ដែលក្នុងនោះគូសបញ្ជាក់ពីការធ្វើកំណែទម្រង់នីតិវិធីកិច្ចសម្រួលរាល់ប្រតិបត្តិការ ដែលពាក់ព័ន្ធដល់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ជាពិសេសទីកន្លែង ពេលវេលា តម្លៃ និងបែបបទ។ ក្រសួងពាណិជ្ជកម្ម បានចាត់តាំងនាយកដ្ឋានកម្មសិទ្ធិបញ្ញាចូលរួមធ្វើបទបង្ហាញជាគំរូដល់អន្តរក្រសួងដទៃ តាមការស្នើសុំពីអគ្គលេខាធិការក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដែលត្រូវបានចាត់ទុកថា អ្វីដែលក្រសួងបានអនុវត្តកន្លងមក មានលក្ខណៈស្តង់ដារក្នុងកម្រិតសមស្របភាគច្រើនទៅតាមសំណូមពរចង់បាន របស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល។

+ឯកសារណែនាំសម្រាប់អនុវត្តការពិនិត្យមើលឡើងវិញនូវប្រតិបត្តិការ

+ឯកសារវិធីសាស្ត្រនៃការពិនិត្យមើលឡើងវិញនូវអភិក្រម

+ឯកសារវិធីសាស្ត្រនៃការពិនិត្យមើលឡើងវិញនូវរចនាសម្ព័ន្ធ

+ឯកសារវិធីសាស្ត្រនៃការពិនិត្យមើលឡើងវិញនូវមុខងារ

- បន្តចូលរួមដំណើរការរៀបចំការកែសម្រួល និងបំពេញបន្ថែមកម្រងព័ត៌មានសេវាសាធារណៈ ដែលរៀបចំឡើងដោយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីត្រៀមរៀបចំបោះពុម្ពជាថ្មីសម្រាប់ដាក់ឲ្យអនុវត្តទូទាំងប្រទេស។

- បានអនុវត្តបញ្ចប់ដោយជោគជ័យ ការធ្វើសមាហរណកម្មអតីតបុគ្គលិក និយោជិត ក្រុមហ៊ុនកាំប៊ិចស៊ីម បញ្ចូលទៅក្រុមហ៊ុនគ្រឿនគ្រេដ តាមការសម្រេចរបស់រាជរដ្ឋាភិបាល ដោយបានបញ្ចប់ទាំងស្រុងបញ្ហារ៉ាំរ៉ៃមិនច្បាស់លាស់នៃជីវភាពរស់នៅ និងអាជីពរបស់អតីតបុគ្គលិក និយោជិតក្រុមហ៊ុនកាំប៊ិចស៊ីម ដែលនៅសេសសល់ចំនួន ២២៨នាក់។ ក្នុងនេះមានការបើកប្រាក់រំលឹកបៀវត្សជូនឡើងវិញក្រោយការអាក់ខានកន្លងមកចំនួន ១៦ខែ ការដោះស្រាយថវិកាឧបត្ថម្ភគោលនយោបាយ ដល់អ្នកសុំឈប់ចំនួន ២៩នាក់ សម្រួលបែបបទ និងផ្ទេរឲ្យទៅទទួលរបបសោធននិវត្តន៍នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន១៧៧នាក់ និងអនុញ្ញាតឲ្យបន្តការងារជាធម្មតាក្នុងក្រុមហ៊ុនគ្រឿនគ្រេដចំនួន ១៣នាក់ (មិនរាប់បញ្ចូលអ្នកទទួលមរណភាព ៥នាក់ និងអ្នកអវត្តមានស្ថាពរចំនួន ៨នាក់)។ ដំណោះស្រាយនេះ បានញ៉ាំងឲ្យអតីតបុគ្គលិក និយោជិត ក្រុមហ៊ុនកាំប៊ិចស៊ីមទាំងអស់មានក្តីរំភើបរីករាយជាខ្លាំង និងសម្តែងការគោរពដឹងគុណជាអនេកចំពោះក្រសួង និងរាជរដ្ឋាភិបាល។

### 3.2. ការងារផ្នែកក្របខ័ណ្ឌ

-ក្របខ័ណ្ឌគិតត្រឹមខែធ្នូ ឆ្នាំ២០១១ នេះ មានចំនួន ១.៦៦៦ នាក់

| | | |
|---|---|---|
| ក.<u>ថ្នាក់កណ្តាល</u> | : | ១.១៣៧ នាក់ |
| - ក្របខ័ណ្ឌជាក់ស្តែង | : | ១.០៧០ នាក់ |
| - នៅក្រៅក្របខ័ណ្ឌដើម | : | ០៤ នាក់ |
| - មន្ត្រីស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស | : | ២០ នាក់ |
| - មន្ត្រីស្ថានតំណាងពាណិជ្ជកម្ម | : | ១១ នាក់ |
| - មន្ត្រីពុំទាន់បញ្ចូលក្នុងតារាងបៀវត្ស | : | ៣២ នាក់ |
| ខ.<u>ថ្នាក់រាជធានី-ខេត្ត</u> | : | ៥២៩ នាក់ |

- ក្របខ័ណ្ឌជាក់ស្តែង : ៥០៨ នាក់

- មន្ត្រីពុំទាន់បញ្ចូលក្នុងតារាងបៀវត្ស : ២១ នាក់

បើប្រៀបធៀបនឹងឆ្នាំ២០១០ ដែលមានចំនួន ១.៧០៣ នាក់ គឺថយចុះចំនួន ៣៧ នាក់ ដែលក្នុងនោះ នៅរដ្ឋបាលថ្នាក់កណ្តាលចំនួន ៣ នាក់ និងនៅរាជធានី-ខេត្តមានចំនួន ៣៤ នាក់ ការប្រែប្រួលនេះអាស្រ័យដោយ ៖

<u>ថ្នាក់កណ្តាល</u> : ចូលនិវត្តន៍ ១៧នាក់ ផ្ទេរចេញ ៨នាក់ ផ្ទេរចូល ៥នាក់ លុបឈ្មោះ ១៤នាក់ និងមន្ត្រីពុំទាន់បញ្ចូលក្នុងតារាងបៀវត្សចំនួន ៣២នាក់។

<u>ថ្នាក់រាជធានី-ខេត្ត</u> : ចូលនិវត្តន៍ចំនួន ៥១នាក់ (គិតទាំងអ្នកចូលនិវត្តន៍នៅចុងត្រីមាសទី៤ ឆ្នាំ២០១០ ចំនួន ៣នាក់) ស្លាប់ ៣នាក់ លុបឈ្មោះ ១នាក់ និងមន្ត្រីពុំទាន់បញ្ចូលក្នុងតារាងបៀវត្សចំនួន ២១នាក់។

- បញ្ចូលក្របខ័ណ្ឌតាមប្រព័ន្ធព័ត៌មានវិទ្យានូវមន្ត្រីថ្មីចំនួន ៩០នាក់ ថ្នាក់កណ្តាលចំនួន ២២នាក់ និងថ្នាក់រាជធានី-ខេត្តចំនួន ៦៨នាក់ (តាមរយៈការប្រឡងចំនួន ៨៨នាក់)។

- ការប្រើប្រាស់បុគ្គលិកជាប់កិច្ចសន្យាចំនួន ៧៦នាក់ នៅថ្នាក់កណ្តាល មានចំនួន ៤៣នាក់ និងរាជធានី-ខេត្តមានចំនួន ៣៣នាក់ និងពលករអណ្តែតចំនួន ៧៥នាក់ នៅថ្នាក់កណ្តាល មានចំនួន ៤៥នាក់ និងនៅរាជធានី-ខេត្ត មានចំនួន ៣០នាក់សរុប (បុគ្គលិកជាប់កិច្ចសន្យា និងពលករអណ្តែតមានចំនួន ១៥ នាក់)។

- ដំឡើងថ្នាក់សម្រាប់ឆ្នាំ២០១១ ជូនមន្ត្រីរាជការចំនួន ៨១៨នាក់ គ្រោងស្នើសុំដំឡើងថ្នាក់នៅឆ្នាំ២០១២ សម្រាប់វេនអតីតភាព និងវេនជ្រើសរើសដែលនៅសេសសល់ពីឆ្នាំមុន ចំនួន ៦៥០នាក់។

- បានជ្រើសរើសក្របខ័ណ្ឌថ្មីសម្រាប់ឆ្នាំ២០១១ ចំនួន ៨៩កន្លែង (៩១ កន្លែងជ្រើសរើសតាមរយៈការប្រឡងប្រជែង) ក្នុងនោះ បានបែងចែកដល់មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ចំនួន ១៨អង្គភាព ស្មើនឹង ២១កន្លែង និងសម្រាប់បម្រើការងារនៅទីស្តីការក្រសួងចំនួន ២៨កន្លែង។

### 3.3. ការងារផ្នែកបុគ្គលិក

*ផ្នែកចាត់តាំងមន្ត្រី*

- តែងតាំង ផ្ទេរសម្រួលភារកិច្ច និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការដោយ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស ចំនួន ៧៦នាក់ ថ្នាក់កណ្តាល ២៩នាក់ ថ្នាក់រាជធានី-ខេត្ត ចំនួន ៤៧នាក់។

- ដើម្បីលើកទឹកចិត្តដល់មន្ត្រីរាជការ ដែលមានស្នាដៃក្នុងការបំពេញការងារក្រសួង បានធ្វើការបំពាក់មេដាយជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការដែលមានស្នាដៃក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១០ ចំនួន ៦៦៨ មេដាយ និងទទួលបានការផ្តល់មេដាយ ដោយឡែកសម្រាប់មន្ត្រីអគ្គនាយកដ្ឋានកាំកុងត្រូល ចំនួន ២១ គ្រឿងផ្សេងទៀត ដែលមានស្នាដៃក្នុងការកសាងបន្ទប់ពិសោធន៍គុណភាពទំនិញថ្មីដែលមានសមត្ថភាពខ្ពស់ជាង។

### 3.4. ការងារផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស

ចំណុចលេចធ្លោសំខាន់គឺ ក្រសួងមានផែនការកសាងនូវមជ្ឈមណ្ឌលបណ្តុះបណ្តាល វិស័យពាណិជ្ជកម្មដ៏ធំមួយនៅក្នុងបរិវេណទីស្តីការក្រសួង ដោយស្នើសុំការគាំទ្រហិរញ្ញប្បទានពីជប៉ុន។ មិនតែប៉ុណ្ណោះ គម្រោងនៃការកសាងយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍ធនធានមនុស្ស ក៏កំពុងត្រូវបានធ្វើការសិក្សាស្រាវជ្រាវ តាក់តែងឲ្យក្លាយទៅជាផែនការមេមួយ មានលក្ខណៈសមស្របទៅនឹងភាពជាក់ស្តែង ក្រោមការគាំទ្រពីគម្រោងកម្មវិធី "គាំទ្រការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម (TDSP)"។

### 3.4.1. ផ្នែកបណ្តុះបណ្តាលក្នុងប្រទេស

ក្នុងឆ្នាំ២០១១ នេះ ក្រសួងបានធ្វើការបណ្តុះបណ្តាលវគ្គខ្លីៗ ធ្វើសិក្ខាសាលានៅទីស្តីការក្រសួង ដោយមានមន្ត្រីថ្នាក់កណ្តាល និងថ្នាក់រាជធានី-ខេត្តចូលរួម និងចាត់មន្ត្រីឲ្យចូលរួមបណ្តុះបណ្តាលវគ្គខ្លីៗ សិក្ខាសាលា នៅក្រៅក្រសួងបាន ១១វគ្គ មានមន្ត្រីចូលរួម ៥០៨នាក់ ក្នុងនោះថ្នាក់កណ្តាល ៤២នាក់ ថ្នាក់រាជធានីខេត្ត ៤៤៦នាក់។ ដោយឡែក ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់មន្ត្រីមន្ទីរពាណិជ្ជកម្ម បានដំណើរការបានចំនួន ៣វគ្គ មានសិក្ខាកាមចូលរួមចំនួន ១៤៨នាក់។

ទន្ទឹមនឹងនេះ មន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាម បានបើកសិក្ខាសាលាលើមុខជំនាញគណនេយ្យ បានចំនួន ២វគ្គ សិក្ខាកាមចូលរួមមានចំនួន ២០៦នាក់ និងនៅមន្ទីរពាណិជ្ជកម្មខេត្តកែបបានបើកសិក្ខាសាលាលើមុខជំនាញកុំព្យូទ័រ និងភាសាអង់គ្លេស បានចំនួន ២វគ្គ សិក្ខាកាមចូលរួមមាន ៩៦នាក់។

- អនុញ្ញាតឲ្យនិស្សិតចំនួន ៣០រូប មកពីសាកលវិទ្យាល័យធនធានមនុស្ស មេគង្គ បៀលប្រាយ និងសាលាភូមិន្ទរដ្ឋបាល ចុះធ្វើកម្មសិក្សាតាមបណ្តានាយកដ្ឋាននានា ក្រោមឱវាទក្រសួង។

- បានរៀបចំវគ្គបណ្តុះបណ្តាល ពង្រីកចំណេះដឹងកម្មសិទ្ធិបញ្ញា ដល់មន្ត្រីរាជការក្រសួង ដើម្បីបំពេញការងារប្រកបដោយប្រសិទ្ធិភាពខ្ពស់។ មិនតែប៉ុណ្ណោះ បានរៀបចំជាកម្មវិធីបណ្តុះបណ្តាលផ្សេងៗទៀតដល់មន្ត្រីជំនាញ ដើម្បីជានាឲ្យការបំពេញសេវាសាធារណៈកាន់តែមានភាពប្រសើរឡើង។

### 3.4.2. ផ្នែកបណ្តុះបណ្តាលក្រៅប្រទេស

ក្រសួងបានចាត់បញ្ជូនមន្ត្រីទៅសិក្សាថ្នាក់អនុបណ្ឌិត ចំនួន ២នាក់ និងចូលរួមសិក្ខាសាលាវគ្គបណ្តុះបណ្តាល រយៈពេលខ្លី និងរយៈពេលវែង នៅបណ្តាប្រទេសមួយចំនួនដូចជា កូរ៉េ ឥណ្ឌា ជប៉ុន ស្វីស ចិន អាល្លឺម៉ង់ ញូវហ្សេលែន សហរដ្ឋអាមេរិក លើប្រធានបទ ការត្រួតពិនិត្យទំនិញសម្គាល់ភូមិសាស្ត្រទំនិញ ផ្នែកពាណិជ្ជកម្មអន្តរជាតិ និងធុរកិច្ចអន្តរជាតិ គោលនយោបាយពាណិជ្ជកម្មរបស់ WTO កម្មវិធីបណ្តុះបណ្តាលអ្នកដឹកនាំវ័យក្មេងរបស់ អាស៊ីឆ្នាំ២០១១ បញ្ហាថ្មីៗនៅក្នុងគោលនយោបាយពាណិជ្ជកម្ម ការប្រណាំងប្រជែង និងប្រធានបទដទៃទៀត។ ការបណ្តុះបណ្តាលក្រៅប្រទេសមានចំនួន ៤៥វគ្គ មានមន្ត្រីចូលរួម ៨៧នាក់ នៅ ១៤ប្រទេស។

## 4. ការងារសវនកម្ម និងអធិការកិច្ច

### 4.1. ការងារសវនកម្ម

បានធ្វើសវនកម្មបាន ១០០% ក្នុងផែនការឆ្នាំ២០១១ ចំនួន ១១អង្គភាព ដែលក្នុងនោះមាន មន្ទីរពាណិជ្ជកម្មខេត្ត កំពង់ឆ្នាំង កណ្តាល កំពត ព្រះសីហនុ កែប ពោធិ៍សាត់ ស្វាយរៀង កំពង់ចាម ព្រះវិហារ ឧត្តមមានជ័យ និងនាយកដ្ឋានរដ្ឋបាល ។

ឆ្លងតាមការចុះទៅធ្វើសវនកម្មរយៈកាលកន្លងមក ក្រោយពីបានរកឃើញចំណុចអវិជ្ជមាននៅតាមបណ្តាសវនដ្ឋាន ក្រុមសវនករ បានលើកជាអនុសាសន៍ដើម្បីឲ្យអង្គភាពសាមីធ្វើការកែលម្អនៅពេលបន្ទាប់។ អង្គភាពមួយចំនួន បានធ្វើការកែលម្អ ប៉ុន្តែនៅមានអង្គភាពខ្លះនៅមានការយឺតយ៉ាវក្នុងការកែលម្អ។ ប៉ុន្តែភាគច្រើននៃអង្គភាពដែលត្រូវបានទទួលការចុះធ្វើសវនកម្ម បានកែលម្អនូវបណ្តាចំណុចខ្វះខាត ដូចអ្វីដែលក្រុមសវនករបានផ្តល់អនុសាសន៍។

#### 4.1.1. សវនកម្មលើកិច្ចប្រតិបត្តិការ

តួនាទីរបស់សវនករត្រូវពិនិត្យមើលថា តើការប្រើប្រាស់ធនធានរបស់អង្គភាព ទាំងធនធាន

មនុស្ស ទាំងធនធានហិរញ្ញវត្ថុ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ឬ ទេ? តាមការរកឃើញរបស់ក្រុមសវនករក្នុងឆ្នាំ២០១១នេះ បើធ្វើការប្រៀបធៀបតាមសន្ទស្សន៍ (Indicator) ដូចគ្នាទៅនឹងឆ្នាំកន្លងទៅ ក្រុមសវនករ បានពិនិត្យឃើញថា មានការប្រែប្រួលជាវិជ្ជមាន (Positive Result) ច្រើន។

ធនធានហិរញ្ញវត្ថុដែលទទួលបានពីប្រភពផ្សេងៗគ្នា ជាពិសេសពីថវិកាជាតិ មានកម្រិតមិនទាន់គ្រប់គ្រាន់នៅឡើយ ប៉ុន្តែត្រូវបានថ្នាក់ដឹកនាំមន្ទីរ យកមកចាត់ចែងបានល្អតាមការណែនាំ។ ចំពោះធនធានមនុស្ស នៅតែជាបញ្ហាប្រឈមរបស់អង្គភាពមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត នៅឡើយមកទល់ពេលនេះ ទាំងបរិមាណ និងគុណភាព។

### *4.1.2. សវនកម្មលើកិច្ចការងារហិរញ្ញវត្ថុ*

ផ្ទៀងផ្ទាត់មើលថា តើមានយន្តការគ្រប់គ្រាន់ និងត្រឹមត្រូវ ឬ ទេ ក្នុងការគ្រប់គ្រងសាច់ប្រាក់ និងទ្រព្យប្រហាក់ប្រហែលដ៏ទៃទៀត។ ប្រភពហិរញ្ញវត្ថុ ដែលទទួលបានសម្រាប់ការចំណាយ គឺចេញពីថវិកាជាតិ និងខ្ទង់ចំណូលពីថ្លៃឈ្នួល ដែលទាមទារឲ្យមានការទទួលខុសត្រូវមួយដ៏ខ្ពស់របស់អង្គភាពរងសវនកម្ម។ ឆ្លងតាមការត្រួតពិនិត្យកន្លងមក រកឃើញថាអង្គភាពទាំង ១១ ដែលត្រូវបានធ្វើសវនកម្មក្នុងឆ្នាំ២០១១ នេះ ពុំមានការខ្លោះខ្លាយដែលនាំទៅដល់ការបាត់បង់សាច់ប្រាក់ទេ ទាំងសាច់ប្រាក់សម្រាប់បង់ចូលថវិការដ្ឋ និងទាំងសាច់ប្រាក់សម្រាប់ចំណាយ។

### *4.1.3. សវនកម្មលើអនុលោមភាព*

សវនកម្មលើអនុលោមភាព គឺត្រួតពិនិត្យទៅលើការអនុវត្តច្បាប់ និងបទបញ្ញត្តិផ្សេងៗ របស់ថ្នាក់លើ។ សវនករត្រូវរកឲ្យឃើញថា តើអង្គភាពរងសវនកម្មអនុវត្តបានកម្រិតណា ទៅលើការអនុវត្តច្បាប់ដែលថ្នាក់លើបានដាក់ចុះ។ ការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅតែជួបបញ្ហាប្រឈមខ្លាំងនៅឡើយ។ អង្គភាព ដែលមានឃ្លាំងចាស់ៗសល់ជាច្រើន នៅតែពុំទាន់អាចទទួលបាននូវប័ណ្ណកម្មសិទ្ធិស្របច្បាប់នៅឡើយ ការរំលោភចូលស្នាក់នៅដោយខុសច្បាប់នៅតែបន្តកើតមាន។ ការដោះស្រាយតាមរយៈពាក្យបណ្តឹងរបស់មន្ទីរពាណិជ្ជកម្មមួយចំនួន នៅតែពុំទាន់បានទទួលលទ្ធផល។ លទ្ធភាពរបស់មន្ទីរពាណិជ្ជកម្មក្នុងការតតាំងតាមរយៈការប្តឹងផ្តល់នៅមានកម្រិត ដោយសារការប្រមូលរកឯកសារ និងភស្តុតាងនានានៅមានការខ្វះខាត។

### *4.1.4. ការងារពង្រឹងសមត្ថភាពអង្គភាព*

បានអនុវត្តគោលការណ៍ពង្រឹងសមត្ថភាពមន្ត្រីរបស់ខ្លួន តាមរយៈជំនួយរបស់ TDSP ដោយបានផ្តល់ទីប្រឹក្សាចំនួន ២នាក់ គឺបរទេស ១នាក់ និងខ្មែរ ១នាក់។ ភារកិច្ចចម្បងរបស់គម្រោងនេះ គឺរៀបចំវគ្គបណ្តុះបណ្តាល រៀបចំសៀវភៅណែនាំ បង្កើតយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុង និងបង្កើតទម្រង់របាយការណ៍សវនកម្ម។

### 4.2. អធិការកិច្ច

ក្រុមការងារអធិការកិច្ចរបស់ក្រសួង បានចុះធ្វើអធិការកិច្ចនៅមន្ទីរពាណិជ្ជកម្មខេត្ត ស្វាយរៀង តាកែវ និងខេត្តស្ទឹងត្រែង ពាក់ព័ន្ធលើការងារ រួមមាន ៖

+ការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

+ការងារវិវាទ

ជាលទ្ធផលឃើញថា ការខ្វះខាតនៅបន្តកើតមានដដែលៗ ដូចជា ៖

ក- បញ្ជីបេឡាមិនមានការបិទប្រចាំខែ។ មិនមានសរុបតួលេខកំណើនឡើង។ មិនមាន

ត្លលេខបូកយោង

ខ- ការទូទាត់ចំណាយបេសកកម្ម ចំណាយប្រជុំ មិនមានលិខិតយុត្តិការគ្រប់គ្រាន់ភ្ជាប់តាម

គ- ការបញ្ចេញសំភារៈប្រើប្រាស់ មិនមានប័ណ្ណបញ្ចេញឃ្លាំង មិនមានការស្នើសុំ។

## IV. ទិសដៅអនុវត្តការងារពាណិជ្ជកម្មបន្ត

❖ *កំណែទម្រង់ដើម្បីអភិបាលកិច្ចល្អ និងការបម្រើសេវាសាធារណៈ*

- រៀបចំសេចក្តីព្រាងច្បាប់ស្តីពី ព័ត៌មានសម្ងាត់ពាណិជ្ជកម្ម ។

- ឆ្លងសេចក្តីព្រាងច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

- រៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការការពារអ្នកប្រើប្រាស់

- រៀបចំអនុក្រឹត្យ ស្តីពីការបង្កើតអនុគណៈកម្មាធិការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា និងអនុគណៈកម្មាធិការអប់រំ និងផ្សព្វផ្សាយ។

- រៀបចំអនុក្រឹត្យ ស្តីពីវិធានការណ៍តាមព្រំដែន លើវិស័យកម្មសិទ្ធិបញ្ញា។

- រៀបចំអនុក្រឹត្យ ស្តីពីការពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា (Sub-Decree on Enforcement of IPRs)

- កែសម្រួលឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ៨៧ អនក្រ.បក ចុះថ្ងៃ ទី ១២ ខែ មិថុនា ឆ្នាំ២០០៣ ស្តីពីអនាម័យនៃម្ហូបអាហារសម្រាប់មនុស្ស

- រៀបចំប្រកាស ស្តីពីការប្រមូលម្ហូបអាហារត្រឡប់មកវិញ (Food Recall)

- កសាងលិខិតបទដ្ឋាន ដែលជាទិសដៅការពារទីផ្សារនាំចេញរបស់កម្ពុជា ឲ្យចៀសផុតពីការជាប់ពាក់ព័ន្ធទៅនឹងពលកម្មដែលហាមឃាត់។

- បន្តចូលរួមធ្វើបច្ចុប្បន្នភាពសៀវភៅកម្រងព័ត៌មានស្តីពី សេវាសាធារណៈ ដើម្បីដាក់ឲ្យអនុវត្តទូទាំងប្រទេស តាមការណែនាំរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ។

- ដាក់ឲ្យអនុវត្តនីតិវិធីចុះបញ្ជីម៉ាក និងគ្រប់គ្រងម៉ាកតាម Trade Mark Manual។

- សហការរៀបចំកម្មវិធីសិក្សាពីកម្មសិទ្ធិបញ្ញាសម្រាប់ថ្នាក់មហាវិទ្យាល័យ ជាមួយក្រសួងអប់រំ។

- សិក្សាពីគុណសម្បត្តិ និងគុណវិបត្តិនៃការចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិតាមប្រព័ន្ធ MADRID SYSTEM។

- រៀបចំនីតិវិធីដែលពាក់ព័ន្ធ ស្តីពីការចុះបញ្ជីម៉ាកសមូហភាព (Collective Mark)។

- ត្រៀមរៀបចំធ្វើកិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារបារាំងដើម្បីការអភិវឌ្ឍន៍ (Agence Française de Développement, AFD) និងអង្គការស្បៀងអាហារ និងកសិកម្មពិភពលោក (FAO, Food and Agriculture of the United Nation) ដើម្បីអនុវត្តគម្រោងថ្នាក់តំបន់ ស្តីពីការសម្គាល់ភូមិសាស្ត្រទំនិញ ដែលមានសមាជិកចំនួន ០៤ប្រទេស គឺ កម្ពុជា វៀតណាម ឡាវ និងថៃឡង់ដ៍ ក្នុងគោលបំណងផ្លាស់ប្តូរចំណេះដឹងរវាងប្រទេសជាសមាជិកក្នុងវិស័យសម្គាល់ភូមិសាស្ត្រទំនិញ។

- បន្តសហការជាមួយអាជ្ញាធរដែនដី និង ក្រសួងជំនាញដែលមានការពាក់ព័ន្ធ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងការកំណត់តំបន់ភូមិសាស្ត្រផលិតផលដែលមានសក្តានុពល ដើម្បីឈានដល់ការចុះបញ្ជីការពារជាផលិតផលសម្គាល់ភូមិសាស្ត្រ (ស្ករត្នោតកំពង់ស្ពឺ ទូរេនកំពត និងអង្ករ...)។

- ពង្រឹងកិច្ចសហការឲ្យកាន់តែជិតស្និទ្ធ និងមានលក្ខណៈកាន់តែប្រសើរឡើងថែមទៀតជាមួយអង្គភាពពាក់ព័ន្ធ និងស្ថាប័នមានសមត្ថកិច្ចនានា ដើម្បីកាត់បន្ថយការ រំលោភបំពានកម្មសិទ្ធិបញ្ញាឲ្យបានជាអតិបរិមា។

- សហការជាមួយ WIPO ដើម្បីរៀបចំបន្ទប់ដាក់ឯកសារចុះបញ្ជីម៉ាក។

- បន្តតាមដានលក្ខខ័ណ្ឌដល់ការចុះបញ្ជីម៉ាក ដែលមានវិភាគក្នុងប្រព័ន្ធ IPAS ដើម្បីធានាដល់ប្រសិទ្ធិភាពការងាររបស់ការិយាល័យចំណុះនាយកដ្ឋានកម្មសិទ្ធិបញ្ញា។

- ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រង និងចុះបញ្ជីពាណិជ្ជសញ្ញាតាមប្រព័ន្ធ IPAS ។

- រៀបចំការត្រួតពិនិត្យម៉ាកដោយស្វ័យប្រវត្តិតាមរយៈ Computer ចំពោះម៉ាកជារូបភាព

- បន្តជូនដំណឹងដល់អតិថិជន ឲ្យមកចុះបញ្ជីម៉ាករបស់ខ្លួនសាជាថ្មី បន្ទាប់ពីបានចុះបញ្ជីរយៈពេល ១០ ឆ្នាំរួច។

- រៀបចំមជ្ឈមណ្ឌលព័ត៌មានកម្មសិទ្ធិបញ្ញាមួយ សម្រាប់បម្រើដល់អតិថិជន ដែលមានបំណងចង់ស្វែងយល់ពីកម្មសិទ្ធិបញ្ញា ពីម៉ាកដែលបានចុះបញ្ជីរួចហើយ ឬឯកសារនានាដែលទាក់ទងនឹងការចុះបញ្ជីម៉ាក និងវិវាទនានានៅកម្ពុជា។

- រៀបចំទំនើបកម្មរូបនីយកម្មប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្ម ដោយធ្វើឲ្យកាន់តែ ប្រសើរឡើងនូវប្រព័ន្ធ Database។

- បន្តអភិវឌ្ឍន៍មណ្ឌលឃ្លាំងតម្កល់ឯកសារចុះបញ្ជីពាណិជ្ជកម្ម ឲ្យមានសុវត្ថិភាព មានភាពទំនើបកម្ម និងមានលក្ខណៈងាយស្រួលក្នុងការស្វែងរកឯកសារ។

- សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តការសន្យា និងកាតព្វកិច្ចនានា ក្រោមក្របខ័ណ្ឌអនុតំបន់ និងតំបន់។

- រៀបចំសៀវភៅព្រឹត្តិប័ត្រពាណិជ្ជកម្ម ឲ្យមានទិន្នន័យពាណិជ្ជកម្មសម្បូរបែបមាន ពីរភាសា គឺភាសាខ្មែរ និង អង់គ្លេស

- ធ្វើឲ្យគេហទំព័រក្រសួងពាណិជ្ជកម្មមានធនធានព័ត៌មានទិន្នន័យពាណិជ្ជកម្មសម្បូរបែប និងតម្រូវតាមស្តង់ដារអន្តរជាតិ។

❖ *សកម្មភាពវិស័យពាណិជ្ជកម្មដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណ*

- ធ្វើការចរចាក្នុងក្របខ័ណ្ឌអនុតំបន់ និងតំបន់ដើម្បីធ្វើឲ្យលក្ខខ័ណ្ឌនៃប្រភពដើមទំនិញរបស់កម្ពុជាមានភាពល្អប្រសើរសម្រាប់នាំចេញ។

- ត្រៀមរៀបចំកិច្ចប្រជុំលើកទី៥ ស្តីពីកិច្ចសហប្រតិបត្តការអភិវឌ្ឍន៍ពាណិជ្ជកម្មកម្ពុជា-វៀតណាម

- ការសាងបញ្ចប់ផែនការមេ ស្តីពីការអភិវឌ្ឍន៍បណ្តាញផ្សារព្រំដែន កម្ពុជា-វៀតណាម តាមទិសដៅអភិវឌ្ឍន៍ ឆ្នាំ២០១០ ដល់ឆ្នាំ២០២០។

- ត្រៀមរៀបចំកិច្ចប្រជុំកំពូលធុរកិច្ចអាស៊ាន-សហភាពអឺរ៉ុបលើកទី២ នៅរាជធានីភ្នំពេញ ក្នុងខែមេសា ឆ្នាំ២០១២។

- ណែនាំដល់ក្រុមហ៊ុនកាត់ដេរ ដើម្បីជំរុញការនាំចេញសំលៀកបំពាក់ទៅកាន់ប្រទេស កាណាដា ក្នុងពេលដែលប្រទេសកម្ពុជាទទួលបាន Duty Free និង Quota Free ដោយគោរពឲ្យ បានត្រឹមត្រូវតាមវិធានប្រភពដើមកែសម្រួលថ្មី។

- រៀបចំអនុវត្តគម្រោង ផ្តល់វិញ្ញាបនប័ត្រប្រភពដើម តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម (Application Online)។

- ត្រៀមលក្ខណៈចូលរួមអនុវត្តការងារគ្រប់គ្រងកិច្ចសន្យាជូលផលិតបន្ត។

- សិក្សា និងកំណត់ ពីមុខទំនិញផលិតផលកសិផល និងមុខទំនិញផ្សេងៗទៀត ដើម្បីត្រៀមស្នើសុំការនាំចូលដោយអត្រាពន្ធស្មើសូន្យភាគរយ (0%) ទៅវិញទៅមករវាងកម្ពុជា និងវៀតណាមសម្រាប់អនុវត្តឆ្នាំបន្តបន្ទាប់។

- ផ្សព្វផ្សាយ ណែនាំ និងអនុវត្តតាមវិធាន បទបញ្ញត្តិថ្មី របស់សហភាពអឺរ៉ុបដល់ ក្រុមហ៊ុន រោងចក្រសិប្បកម្ម និងស្ថាប័នពាក់ព័ន្ធដែលធ្វើការនាំចេញទំនិញទៅបណ្តាប្រទេសនៅសហភាពអឺរ៉ុបដោយរួចពន្ធ។

- រៀបចំ និងចូលរួមពិពរណ៍ពាណិជ្ជកម្មក្នុង និងក្រៅប្រទេស

- បំពេញការងារជាលេខាធិការដ្ឋាន ដើម្បីចូលរួម និងរៀបចំពិព័រណ៍អន្តរជាតិ និងពិភពលោក និងបំពេញការងារការិយាល័យពិព័រណ៍អន្តរជាតិ (BIE)

- រៀបចំ និងគ្រប់គ្រងគេហទំព័រ (Home Page) ថ្មីសម្រាប់ការងារជំរុញពាណិជ្ជកម្ម និងការងារមួយចំនួនទៀត ។

- រៀបចំក្រុមការងារផលិតផល ហាឡាល់ (Halal) និងជំរុញឱ្យមានច្បាប់ហាឡាល់មួយ ដែលទទួលស្គាល់ជាអន្តរជាតិ។

- សហការជាមួយក្រុមហ៊ុន Intertek រៀបចំបែបបទត្រួតពិនិត្យគុណភាពផលិតផលលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ។

- ណែនាំអាជីវករ ឲ្យចេះប្រើប្រាស់ប្រព័ន្ធ EMCS ក្នុងការទទួលព័ត៌មានទីផ្សារ

- ត្រួតពិនិត្យ និងណែនាំការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មខ្នាតតូចដល់ ការិយាល័យច្រកចេញចូលតែមួយតាមស្រុក-ក្រុង។

- សិក្សាស្រាវជ្រាវលើផលិតផលថ្មីៗ និងអភិវឌ្ឍផលិតផលដែលជាសក្តានុពលសម្រាប់បម្រើទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញ។

- បោះពុម្ពព័ត៌មានពាក់ពន្ធ័ដល់ការជំរុញពាណិជ្ជកម្ម និងជំរុញទីផ្សារក្នុង និងក្រៅប្រទេស។

- សិក្សាស្រាវជ្រាវបន្ថែមទៀតទៅលើ Value Chain Unit លើមុខទំនិញដែលមានសក្តានុពលនាំចេញ

- ជំរុញចលនាភូមិ១ផលិតផល១ ឬ ខេត្ត១ ផលិតផល១ ឱ្យបានប្រសើរ សំដៅពង្រីកការយល់ដឹង និងបង្កើនការយកចិត្តទុកដាក់ដល់ផលិតករ សិប្បករ ឱ្យខិតខំកែលម្អផលិតផលរបស់ខ្លួន។

- រៀបចំកិច្ចសហប្រតិបត្តិការ និងដំណើរការនៃសភាពាណិជ្ជកម្មរាជធានី-ខេត្ត។

- ពង្រឹងប្រសិទ្ធភាពនៃការឃ្លាំពិនិត្យទីផ្សារ ពាក់ព័ន្ធនឹងផ្នែកសុខុមាលភាព ព្រមទាំងផ្នែកបង្ក្រាបការក្លែងបន្លំ ការពារផលប្រយោជន៍សេដ្ឋកិច្ចរបស់អ្នកប្រើ។

- ធ្វើការគ្រប់គ្រងអាជីវកម្ម (នាំចូលនិងចែកចាយ) សារធាតុបន្ថែមសម្រាប់ម្ហូបអាហារ (food additives)

- ដំណើរការអនុវត្តកម្មវិធីពិនិត្យតាមដានតាមបណ្តាផ្សារ ដោយផ្តល់អាទិភាពលើផ្សាររាជធានីភ្នំពេញ និងបណ្តាខេត្ត ជាទិសដៅទេសចរណ៍។

- ស្រាវជ្រាវទប់ស្កាត់រាល់ការបន្លំ ប៉ុនប៉ងបន្លំលើផលិតផល ទំនិញ ។

- រៀបចំបទបញ្ញត្តិ ស្តីពីស្លាកសញ្ញាម្ហូបអាហារវេចខ្ចប់ស្រេច។

- ពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យ ការនាំចេញ-នាំចូលតាមច្រកបណ្តាព្រំដែន លើមូលដ្ឋាននៃគោលការណ៍គ្រប់គ្រងហានិភ័យ សំដៅឲ្យមានតុល្យភាពរវាងសកម្មភាពត្រួតពិនិត្យ និងកិច្ចសម្រួលពាណិជ្ជកម្ម។

- កសាងផែនការយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ តាមកម្មវិធីភាពអនុលោម។

- ពង្រឹងសមត្ថភាពវិភាគរបស់មន្ទីរពិសោធន៍ ឲ្យមានលក្ខណៈសមស្របតាមលក្ខខណ្ឌតម្រូវ នៃស្តង់ដារអន្តរជាតិ ដើម្បីឈានដល់ការទទួលស្គាល់ជាលក្ខណៈសកល (Accreditation)។

- ដាក់ឲ្យអនុវត្ត នូវនីតិវិធីស្របតាមប្រព័ន្ធធានាគុណភាព ក្នុងសកម្មភាព វិភាគរបស់មន្ទីរពិសោធន៍

- កសាងខ្លឹមសារកម្មវិធី និងដំណើរការអនុវត្តការលើកកម្ពស់នៃការយល់ដឹងសាធារណៈ តាមទីសាធារណៈ សាលារៀន និងបណ្តាញព័ត៌មានអំពី ៖

+បញ្ហាអនាម័យនិងបញ្ហាសុវត្ថិភាពម្ហូបអាហារ

+បញ្ហាគ្រោះថ្នាក់ដល់សុខភាពពាក់ព័ន្ធនឹងផលិតផលគីមីមួយចំនួន (រួមទាំងគ្រឿងញៀន)

+សិទ្ធិ និងកាតព្វកិច្ចអ្នកប្រើប្រាស់

- ជំរុញការធ្វើបច្ចុប្បន្នភាពនៃផែនទី ចង្អុលផ្លូវរបស់សសរស្តម្ភទាំង៣។

- អនុវត្តគម្រោង EIF Tier 2 និងលើកគម្រោង EIF Tier 2 ជំហានទី២។

- ជំរុញដំណើរការអនុវត្តគម្រោង TDSP តាមផែនការគ្រោងទុក។

- បន្តអនុវត្តនូវផែនការសកម្មភាពបញ្ជ្រាបយេនឌ័រក្នុងវិស័យពាណិជ្ជកម្ម ឲ្យស្របតាមអនុសាសន៍របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានដាក់ចេញក្នុងកិច្ចប្រជុំបូកសរុបការងារប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។

- ពង្រឹងខ្សែរយៈក្រុមការងារយេនឌ័រនៅតាមមន្ទីរពាណិជ្ជកម្ម។

❖ *ការងាររដ្ឋបាល ហិរញ្ញវត្ថុ គ្រប់គ្រងធនធានមនុស្ស និងអធិការកិច្ច*

- ជំរុញអនុវត្តការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធលើអចលនទ្រព្យនៅតាមមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត

- ខិតខំកៀគរប្រមូលចំណូលចូលថវិការរដ្ឋតាមផែនការដែលបានអនុម័ត ពិសេសការប្រមូលចំណូលពីការអនុវត្តកម្រៃសេវាសាធារណៈផ្សេងៗ ដែលនឹងត្រូវបានកំណត់ជាបទដ្ឋានថ្មីនៅពេលខាងមុខនេះ។

- ពង្រឹងការអនុវត្តវិធីសាស្ត្រគ្រប់គ្រងមន្ត្រីរាជការតាមព័ត៌មានវិទ្យា
និងរៀបចំការធ្វើនីយ័តកម្មជំរឿនមន្ត្រីរាជការដែលពុំទាន់បានបញ្ចប់
ដំណើរការបញ្ចូលទិន្នន័យក្នុងជំហានមុន ពិសេសនៅថ្នាក់រាជធានី-ខេត្ត។

- ដំណើរការជ្រើសរើសក្របខ័ណ្ឌថ្មីចំនួន ៦៩កន្លែង តាមរយៈការប្រឡងប្រជែង ដើម្បីបំពេញកង្វះខាតខាងធនធានមនុស្ស។

- ធ្វើបច្ចុប្បន្នភាពតម្រូវការក្របខ័ណ្ឌតាមវិធីសាស្ត្រវិភាគមុខងារ និងរចនាសម្ព័ន្ធនៃអង្គភាពនីមួយៗ

